# សង្កេតការណ៍

៩

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# អង្គជំនុំជម្រះតុលាការកំពូល ៖ ឧក្រិដ្ឋកម្មរបស់ ឌុច ជាឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ

ខែមេសា ឆ្នាំ២០១២

## មាតិកា


ប្រវត្តិនីតិវិធី ១

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ២

ប្រតិកម្មរបស់ជនរងគ្រោះ និងដើមបណ្តឹង... ១០

ប្រវត្តិដំណើររឿងនៃជនរងគ្រោះ... ១១

សាលក្រមសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូង ២១



ក្រុមសង្កេតការណ៍ ៖

ឆាយ ឈុនលី, ឌី សុជាតា,

លឹម ជ័យទត្ត និង ចាន់ ប្រាថ្នា


ឌុច នៅថ្ងៃប្រកាសសាលដីកាបណ្តឹងឧទ្ធរណ៍ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២

(រូបថត ៖ អ.វ.ត.ក)

មជ្ឈមណ្ឌលឯកសារកម្ពុជា ◆ ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌ ◆ www.dccam.org



ឌុច ក្នុងបន្ទប់សវនាការ ឆ្នាំ២០១២ (រូបថត ៖ អ.វ.ត.ក)

# អង្គជំនុំជម្រះតុលាការកំពូល ៖ ឧក្រិដ្ឋកម្មរបស់ ឌុច ជាឧក្រិដ្ឋកម្ម ដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ

## ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២

*ឆាយ ឈុនលី, ឌី សុជាតា, ចាន ប្រាថ្នា និង លីម ជ័យទ័ត្ត*

## សេចក្តីផ្តើម

នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានសមាសភាពចៅក្រមចំនួនប្រាំពីររូប (ខ្មែរបួនរូប និងបរទេសបីរូប) បានប្រកាសសាលដីកាលើសំណុំរឿង០០១ទាក់ទងនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុច ដែលជាអតីតប្រធានមន្ទីរស-២១ឬគុកទួលស្លែងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ប៉ុន្តែមានចៅក្រមបរទេសពីររូបបានជំទាស់នឹងការសម្រេចដាក់ទោស ឌុច ឲ្យជាប់គុកអស់មួយជីវិត ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលធ្វើឡើងដោយមានពាក្យបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ ឌុច ខ្លួនឯងនិងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។ ពាក្យបណ្តឹងសាទុក្ខបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលពិនិត្យលើបញ្ហាយុត្តាធិការបុគ្គលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិការប្រកាសទោសភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។

## ១) ប្រវត្តិនីតិវិធី

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគាររយៈពេល៣៥ឆ្នាំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ ក៏ប៉ុន្តែទោសនេះត្រូវបានកាត់បន្ថយរយៈពេល៥ឆ្នាំ ដើម្បីជាការទូទាត់ចំពោះការឃុំឃាំងខ្លួន ឌុច ខុសនីតិវិធីច្បាប់នៅពន្ធនាគារតុលាការយោធាដោយមិនមានការជំនុំជម្រះក្តីនិងកាត់បន្ថយរយៈពេល១១ឆ្នាំផ្សេងទៀតចំពោះរយៈកាលដែល ឌុច ជាប់នៅក្នុងពន្ធនាគារចាប់តាំងពីឆ្នាំ១៩៩៩រហូតដល់ថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងប្រកាសសាលក្រម ។ ភាគីទាំងអស់នៅក្នុងសំណុំរឿងនេះបានសម្រេចដាក់ពាក្យបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការ



ការ សាវុត្ថ (ឆ្វេង) និង កង ឫទ្ធារី សហមេធាវីរបស់ ឌុច (រូបថត ៖ អ.វ.ត.ក)

កំពូលប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានជូនដំណឹងអំពីការដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដោយសម្អាងថាអង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ស្ថានទម្ងន់ឲ្យបានគ្រប់គ្រាន់ក្នុងការផ្តន្ទាទោសលើជនជាប់ចោទនិងបានផ្តល់ស្ថានសម្រាលទោសហួសហេតុ ។ តាមគំនិតរបស់សហព្រះរាជអាជ្ញា ឌុច គួរតែត្រូវបានផ្តន្ទាទោសបន្ថែមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអាទិ៍ការដាក់ឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការសម្លាប់រង្គាលនិងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀតដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ ។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ មេធាវីការពារក្តីឲ្យជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងគោលបំណងចង់ឲ្យអង្គជំនុំជម្រះតុលាការកំពូលលើកលែងការចោទប្រកាន់លើកូនក្តីរបស់ខ្លួនដោយអះអាងថា ឌុច មិនស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ សហមេធាវីការពារក្តី ឌុច អះអាងថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរស-២១ដែរ ។ មេធាវីយល់ឃើញទៀតថា ការផ្តន្ទាទោស ឌុចគួរតែអនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ។

រីឯដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីក្រុមក្នុងចំណោមបួនក្រុមបានដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានច្រានចោលសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន និងស្នើសុំឲ្យមានការផ្តល់នូវសំណងផ្លូវចិត្តនិងសំណងសមូហភាពដែលមានលក្ខណៈសមរម្យទៅតាមការចង់បានរបស់ជនរងគ្រោះ ។

ថ្ងៃទី២៨-៣០ ខែមីនា ឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបើកសវនាការលើបណ្តឹងសាទុក្ខនេះ ។ គួរកត់សម្គាល់ថាអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចតែចំពោះបញ្ហាទាំងឡាយណាដែលមានក្នុងកម្មវត្ថុនៃបណ្តឹងសាទុក្ខដែលធ្វើឡើងដោយភាគីតែប៉ុណ្ណោះ ។

## ២) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល

នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង១០ព្រឹក បន្ទាប់ពីការពិចារណាអស់រយៈពេល៣១០ថ្ងៃ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចប្រកាសសាលដីកាស្ថាពរជាសាធារណៈលើសំណុំរឿង០០១ប្រឆាំងនឹងជនជាប់ចោទ ឌុច ។ ដោយសារតែសាលដីកាមិនទាន់ត្រូវបានចងក្រងចប់សព្វគ្រប់ទាំងស្រុងនិងមានលក្ខណៈវែងឆ្ងាយ លោកចៅក្រមប្រធាន គង់ ស្រ៊ឹម សូមអាននូវសេចក្តីសង្ខេបនៃសាលដីកាដែលមានចំនួន៣៥ទំព័រជាភាសាខ្មែរ ដោយផ្តល់នូវសេចក្តីសង្ខេបលើសម្អាងហេតុនិងការសម្រេចផ្សេងៗចំពោះបញ្ហាដែលមានចំពោះមុខ ។ មានជាអាទិ៍យុត្តាធិការបុគ្គល, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ការប្រកាសទោស, ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។

### ក) យុត្តាធិការបុគ្គល

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលទាំងស្រុងចំពោះបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ឌុច ទាក់ទងនឹងបញ្ហា "យុត្តាធិការបុគ្គល" ។ បណ្តឹងសាទុក្ខរបស់ ឌុច ដែលបានលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការបុគ្គលចំពោះខ្លួនទេ និងស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចពីពិរុទ្ធភាពនិងការផ្តន្ទាទោសមកលើរូបខ្លួន ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថាចំពោះបញ្ហាកំណត់ថាតើជនជាប់ចោទគឺជាមេដឹកនាំជាន់ខ្ពស់ ឬជាជនដែលទទួលខុសត្រូវខ្ពស់បំផុតឬយ៉ាងណានោះគឺជាការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតពុំមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះឡើយ ។ គួរកត់សម្គាល់ថា ពាក្យថា "យុត្តាធិការបុគ្គល" ដែលប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺមានន័យថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចអនុវត្តសិទ្ធិអំណាចឬមានដែនសមត្ថកិច្ចក្នុងការនាំយកបុគ្គលណាម្នាក់ដែលស្ថិតក្រោមអំណាចរបស់ខ្លួនមកជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះបាន ។ បុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានកំណត់ដោយមាត្រា១នៃច្បាប់ស្តីពីការ

បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានជាអាទិ៍ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។

អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ទៅលើពាក្យថា «មេដឹកនាំជាន់ខ្ពស់និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» គឺសំដៅទៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទខុសគ្នា ប៉ុន្តែប្រភេទទាំងពីរនេះមានទំនាក់ទំនងគ្នា ។ ប្រភេទទីមួយគឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនផ្អែកតែទៅលើតួនាទីជាមេដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ ។ ចំពោះប្រភេទទីពីរគឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកដែលស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ ជនទាំងពីរប្រភេទនេះគឺជា «ជនសង្ស័យ» ដែលជាកម្មវត្ថុនៃការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាការបកស្រាយទៅលើពាក្យពេចន៍ «មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» ចាំបាច់ត្រូវតែមានការពិចារណាទៅលើលទ្ធផលនៃការបកស្រាយ និងថាតើការបកស្រាយនោះស្របទៅនឹងគោលបំណងនៃកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិដែរឬយ៉ាងណា ។ ពាក្យថា «ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត» មិនមែនជាបញ្ហាដែលអាចធ្វើការវិនិច្ឆ័យបាននោះទេ ប៉ុន្តែគឺជាគោលការណ៍ណែនាំដល់សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនទាក់ទងនឹងវិសាលភាពនៃការចោទប្រកាន់និងការស៊ើបអង្កេត ។ ចំពោះ «មេដឹកនាំជាន់ខ្ពស់» ក៏មិនមែនជាកម្មវត្ថុដែលអាចធ្វើការវាយតម្លៃបានដែរ ប៉ុន្តែគឺជាគោលការណ៍ណែនាំដោយសារតែការកំណត់និយមន័យនៃពាក្យនេះមានភាពបត់បែនទៅ តាមហេតុផលផ្សេងៗ ។

នៅក្នុងករណីដែលមានភស្តុតាងបញ្ជាក់ថា សហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដោយអសុទ្ធចិត្តឬការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈទាក់ទងនឹងគោលបំណង នៃការចោទប្រកាន់ និងការស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូងមានអំណាចក្នុងការពិនិត្យឡើងវិញអំពីបញ្ហារំលោភឆន្ទានុសិទ្ធិនេះបាន ។ ដូច្នេះការកំណត់ឲ្យបានជាក់លាក់អំពីពាក្យ «មេដឹកនាំជាន់ខ្ពស់» និង «អ្នកទទួលខុសត្រូវខ្ពស់បំផុត» មិនត្រូវបានផ្តល់ជានិយមន័យច្បាស់លាស់ឡើយ ។

## ខ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលភាគីបានប្តឹងប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចបញ្ហាមួយចំនួនដូចជា ទី១) គោលការណ៍ច្បាប់ ទី២) អត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទី៣) បទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម និងការរំលោភផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ) និង ទី៤) ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា ។

### ១) គោលការណ៍ច្បាប់

អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ជាបឋមថា ដើម្បីដោះស្រាយលើបណ្តឹងសាទុក្ខរបស់ភាគីខ្លួនត្រូវតែពិចារណាអំពីយុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូងលើបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជា ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ និងការធ្វើទុក្ខបុកម្នេញ ។

អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញនូវជំហរយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងដែលអះអាងថាដើម្បីឲ្យបទល្មើសដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការចូលរួមស្ថិតនៅក្នុងយុត្តាធិការលើរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បទល្មើស និងទម្រង់នៃការចូលរួមនោះត្រូវតែមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយច្បាស់លាស់ឬដោយប្រយោល ។ ប៉ុន្តែដោយសារតែច្បាប់នេះត្រូវបានអនុម័តក្រោយការប្រព្រឹត្តអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដូចនេះអង្គជំនុំជម្រះតុលាការកំពូលត្រូវតែ

ពិចារណាលើបទឧក្រិដ្ឋទាំងនោះដោយផ្អែកលើគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង ។ ទន្ទឹមនឹងនេះដែរ អង្គជំនុំជម្រះតុលាការកំពូលតម្រូវថារាល់បទល្មើសឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវមានចែងក្នុងច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ហើយជនជាប់ចោទត្រូវតែអាចយល់ដឹងជាមុនថាការប្រព្រឹត្តរបស់ខ្លួនគឺជាបទល្មើសនិងដឹងជាមុនថាបទល្មើសទាំងនោះមានច្បាប់ចែងទៀតផង ។

### ២) អត្ថិភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

ទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាឧក្រិដ្ឋកម្មអន្តរជាតិដែលស្ថិតនៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថានិយមន័យទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងគោលការណ៍នូរិមបឺកឆ្នាំ១៩៥០ ពិតជាឆ្លុះបញ្ចាំងឲ្យឃើញពីស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះ ។

### ៣) បទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

អង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើការសម្រេចទាក់ទងនឹងបទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរួមមាន ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម និងការរំលោភផ្លូវភេទ និងការធ្វើទុក្ខបុកម្នេញ ។

#### ◆ ការធ្វើឲ្យទៅជាទាសករ

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលនូវអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលលើកឡើងថា "អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយមិនបានសម្រេចដាក់ពិរុទ្ធភាពលើ ឌុច ពីបទធ្វើឲ្យទៅជាទាសករចំពោះអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ ព្រោះអង្គជំនុំជម្រះសាលាដំបូងបានតម្រូវឲ្យមានធាតុផ្សំនៃពលកម្មដោយបង្ខំនៅក្នុងនិយមន័យនៃការធ្វើឲ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ហេតុផលថាអង្គជំនុំជម្រះសាលាដំបូងពុំបានកំណត់អំពីការធ្វើពលកម្មដោយបង្ខំថាជាធាតុផ្សំចាំបាច់មួយនៅក្នុងនិយមន័យនៃការធ្វើឲ្យទៅជាទាសករឡើយ ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ការធ្វើពលកម្មដោយបង្ខំគ្រាន់តែជាកត្តាមួយដែលត្រូវយកមកពិចារណាតែប៉ុណ្ណោះ ។ ដូចនេះការណ៍ដែលសហព្រះរាជអាជ្ញាលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យមានធាតុផ្សំនៃការដាក់ឲ្យធ្វើការដោយបង្ខំ ជាធាតុផ្សំចាំបាច់ដើម្បីចោទប្រកាន់ពីបទធ្វើទៅជាទាសករ គឺមិនមានមូលដ្ឋានត្រឹមត្រូវទេ ។

អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា និយមន័យនៃអំពើធ្វើឲ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជា ១) ការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ (ធាតុផ្សំសត្យានុម័ត) និង ២) ចេតនាក្នុងការបង្កើតផលចំណេញ តាមរយៈការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់ (ធាតុផ្សំអត្តនោម័ត) ។ ដោយយោងលើនិយមន័យនេះអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ពុំមានភស្តុតាងបង្ហាញអំពីចេតនារបស់ ឌុច នៅក្នុងការទទួលផលចំណេញសម្រាប់ខ្លួនពីអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ ឡើយ ។ ដូច្នេះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការធ្វើឲ្យទៅជាទាសករមិនមានកំហុសនោះទេ ។

#### ◆ ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ

ទាក់ទងនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញាឲ្យសម្រេចដាក់ពិរុទ្ធភាពលើជនជាប់ចោទ ឌុច ពីបទរំលោភលើផ្លូវភេទ និងការធ្វើទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបទល្មើសត្រួតអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថាសំណើរបស់សហព្រះរាជអាជ្ញាត្រូវបានបដិសេធដោយស្វ័យប្រវត្តិ ។ ការបដិសេធនេះ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលផ្តល់ហេតុផលថាដោយសារពុំមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថាការរំលោភលើផ្លូវភេទដែលជាបទឧក្រិដ្ឋមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពិតជាស្ថិតនៅក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថាហេតុការណ៍ដែលបានកើតឡើងនៅមន្ទីរស-២១ គឺជាការរំលោភលើផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប៉ុន្តែយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងក្នុងការស្រូបបញ្ចូលអំពើរំលោភលើផ្លូវភេទទៅក្នុងនិយមន័យនៃអំពើធ្វើទារុណកម្ម នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ អំពើធ្វើទារុណកម្មដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាសារវន្តរបស់បុគ្គលនៅពេលដែលជនជាប់ចោទបានប្រព្រឹត្តអំពើឧក្រិដ្ឋនេះ ។

◆ **ការធ្វើទុកបុកម្នេញ**

អង្គជំនុំជម្រះតុលាការកំពូលបានចាត់ទុកថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសចំពោះការសន្និដ្ឋានថាអ្នកជាប់ឃុំឃាំងទាំងអស់នៅមន្ទីរស-២១ បានក្លាយទៅជាជនរងគ្រោះនៃការធ្វើទុកបុកម្នេញ ព្រោះអ្នកទាំងនោះត្រូវបានកំណត់ជាគោលដៅដោយមូលហេតុនយោបាយ ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ហេតុផលថា «នៅក្នុងអំឡុងពេលនៃរបបគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាមានក្រុមមនុស្សខុសៗគ្នាត្រូវបានកំណត់ជាគោលដៅថាជាខ្មាំងនយោបាយពិតប្រាកដ ឬដោយសន្មតហើយត្រូវបានបោសសម្អាតដោយមិនរើសមុខនិងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផលដោយមូលហេតុនយោបាយនោះទេ។ សកម្មភាពបែបនេះមិនមែនជាការធ្វើទុកបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែបង្កើតឲ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្តែងឲ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ ។ ជនជាប់ចោទទទួលខុសត្រូវលើការឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម ការធ្វើឲ្យទៅជា ទាសករ និងការសម្លាប់បុគ្គលជាច្រើនដែលមិនមែនជាខ្មាំងនយោបាយនោះទេ» ។

អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងអង្គជំនុំជម្រះសាលាដំបូងដែលថាបទឧក្រិដ្ឋ ការធ្វើទុកបុកម្នេញត្រូវតែមានធាតុផ្សំពីរគឺទី១ ធាតុផ្សំអត្តនោម័តដែលជាការប្រព្រឹត្តអំពើសកម្ម ឬ អកម្ម «ដោយមានចេតនា» ក្នុងការធ្វើទុកបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ។ ទី២ គឺធាតុសត្យានុម័តដែលបង្កើតបានជាការប្រព្រឹត្តអំពើសកម្ម ឬ អកម្ម ដែលដកហូត ឬរំលោភទៅលើសិទ្ធិជាសារវន្តដែលមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា ។

**៤) ការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា**

អង្គជំនុំជម្រះតុលាការកំពូលបានយល់ស្របជាមួយនឹងការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយធ្វើការស្រូបបញ្ចូលនូវរាល់បទឧក្រិដ្ឋមូលដ្ឋាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងបទឧក្រិដ្ឋនៃការធ្វើទុកបុកម្នេញដែលបទល្មើសទាំងនេះគប្បីត្រូវបានផ្តន្ទាទោសដាច់ដោយឡែកពីគ្នា ព្រោះអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថាជនជាប់ចោទជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ ។ អង្គជំនុំជម្រះតុលាការកំពូលបានអះអាងថាអង្គជំនុំជម្រះសាលាដំបូងពុំបានផ្តោតការវិភាគរបស់ខ្លួនឲ្យបានត្រឹមត្រូវទៅលើការសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះអំពើដែលជាមូលដ្ឋាននៃបទចោទនិងពុំបានសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសច្រើនចំពោះអំពើធ្វើទុកបុកម្នេញនិងចំពោះបទឧក្រិដ្ឋមូលដ្ឋានដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលជនជាប់ចោទមានការទទួលខុសត្រូវ ។

ដូចនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចដាក់បន្ថែមពិរុទ្ធភាពដាច់ដោយឡែកលើជនជាប់ ចោទ ឌុច ចំពោះការសម្លាប់រង្គាលដោយរួមបញ្ចូល (ការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀតបន្ថែមលើបទធ្វើទុកបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

**គ) ការប្រកាសទោស**

ពាក់ព័ន្ធនឹងការប្រកាសទោសអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិតដោយធ្វើការបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានផ្តន្ទាទោស ឌុច ត្រឹមតែរយៈពេល៣៥ឆ្នាំ ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ហេតុផលថាអង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយមានកំហុសក្នុងការប្រកាសទោសដែលមិនមានលក្ខណៈគ្រប់គ្រាន់និងមិនបានឆ្លុះបញ្ចាំងឲ្យបានសមរម្យទៅនឹងទម្ងន់នៃឧក្រិដ្ឋកម្មដែលនិងស្ថានភាពបុគ្គលរបស់ ឌុច ។

សូមបញ្ជាក់ថាទាក់ទងនឹងការប្រកាសទោសនេះនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដែលបានដាក់ជូនអង្គជំនុំជម្រះតុលាការកំពូលនាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលផ្តន្ទាទោស ឌុច ឲ្យដល់កម្រិតជាប់ពន្ធនាគារអស់មួយជីវិត ។ ប៉ុន្តែសហព្រះរាជអាជ្ញាបានស្នើសុំឲ្យកាត់បន្ថយមកត្រឹមរយៈពេល ៤៥ឆ្នាំវិញ ដើម្បីជាដំណោះស្រាយដ៏សមស្របមួយសម្រាប់ការឃុំខ្លួន ឌុច ដោយខុសនីតិវិធីច្បាប់នៅមុនពេលមានការឃុំខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ការសម្រេចផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារអស់មួយជីវិតរបស់អង្គជំនុំជម្រះតុលាការកំពូលគឺយោងទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាច្បាប់ព្រហ្មទណ្ឌមានចរិតពិសេស “ដែលមានចែងនៅក្នុងមាត្រា៦៦៨ (៣) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ។ មាត្រា៣៩ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងអំពីរយៈពេលនៃទោសជាប់ពន្ធនាគារពី៥ឆ្នាំរហូតដល់មួយជីវិត ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់សហមេធាវីការពាររបស់ ឌុច ដែលអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសម្រេចផ្តន្ទាទោសកូនក្តីរបស់ខ្លួនដោយខកខានពុំបានពិចារណាទៅលើមាត្រា៩៥នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ។ មាត្រា៩៥ដែលចែងពីកម្រិតនៃទោស ក្រោយពេលទទួលបានស្ថានសម្រាលទោស គឺស្ថិតនៅចន្លោះពី១៥ទៅ ៣០ឆ្នាំ ។

អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ហេតុផលទាក់ទងនឹងការបន្ថែមទម្ងន់ទោសលើរូប ឌុច រហូតដល់កម្រិតជាប់ពន្ធនាគារអស់មួយជីវិត គឺដោយសារអង្គជំនុំជម្រះបានពិនិត្យឃើញពីតួនាទីដឹកនាំរបស់ ឌុច និងការប្រព្រឹត្តខ្រិដ្ឋកម្មដោយភាពឃោរឃៅ និងដោយពេញចិត្ត ។ អង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា ខ្រិដ្ឋកម្មដែល ឌុច បានប្រព្រឹត្តនៅក្នុងរឿងក្តីនេះគឺពិតជាខ្រិដ្ឋកម្មមួយនៅក្នុងចំណោមខ្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។ ខ្រិដ្ឋកម្មទាំងនេះសមនឹងទទួលនូវទណ្ឌកម្មធ្ងន់ធ្ងរបំផុតដើម្បីជាការឆ្លើយតបដោយយុត្តិធម៌និងគ្រប់គ្រាន់ចំពោះអំពើសាហាវឃោរឃៅដែលខ្រិដ្ឋកម្មទាំងនោះបង្កឡើងទៅលើជនរងគ្រោះក្រុមគ្រួសារ និងសាច់ញាតិ ក៏ដូចជាប្រជាជនកម្ពុជា និងមនុស្សជាតិទាំងមូល ។

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការសាលាដំបូងដែលផ្តល់សំណងជំងឺចិត្តដល់ជនជាប់ចោទ ឌុច ចំពោះការឃុំឃាំងខ្លួនហួសនីតិវិធីច្បាប់នៅក្នុងតុលាការយោធា ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ហេតុផលថាការរំលោភសិទ្ធិរបស់ជនជាប់ចោទ ឌុច មិនគួរត្រូវយកទូទាត់សងដោយអង្គជំនុំជម្រះឡើយ ប្រសិនបើពុំមានភស្តុតាងបង្ហាញថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាអ្នករំលោភកិច្ចដំណើរការនីតិវិធី ឬជាអ្នកទទួលខុសត្រូវចំពោះការរំលោភសិទ្ធិទាំងនោះ ។ ប៉ុន្តែការសម្រេចដូច្នេះរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានចៅក្រម ក្លូវីកា មីឡាត និងចៅក្រម ចាយ៉ាស៊ីងហេ មានមតិជំទាស់ចំពោះការយល់ឃើញនេះ ដោយចៅក្រមទាំងពីររូបបានលើកឡើងពីមូលដ្ឋានយុត្តិធម៌និងសមធម៌ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការចម្រុះពិសេសគប្បី


អ្នកចូលរួមក្នុងថ្ងៃប្រកាសសាលដីកា ឌុច

ទទួលខុសត្រូវចំពោះការឃុំខ្លួនមុនអង្គសេចក្ដីហួសរយៈពេលកំណត់ដោយតុលាការជាតិ ។ ដូច្នេះ ឌុច គួរតែត្រូវបានកាត់បន្ថយការប្រកាសទោសពីការដាក់ពន្ធនាគារអស់មួយជីវិតមកត្រឹមការដាក់ពន្ធនាគារមានរយៈពេលកំណត់៣០ឆ្នាំវិញ ។

ទាក់ទងនឹងការគិតបញ្ចូលថិរវេលានៃការឃុំឃាំងខ្លួនបណ្ដោះអាសន្ននៅក្នុងពន្ធនាគាររបស់តុលាការយោធានិងនៅក្នុងពន្ធនាគារនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ឌុច មានសិទ្ធិទទួលបានការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នទាំងស្រុងគឺចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ មក ។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលសម្រេចអនុវត្តការគិតបញ្ចូលទៅក្នុងថិរវេលានៃការផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះ ឌុច ដែលធ្លាប់បានទទួលរងទោសរបស់ខ្លួនអស់រយៈពេល១២ឆ្នាំ និង២៩៦ថ្ងៃរួចហើយ ដែលជារយៈពេល ឌុច ស្ថិតក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ។

**ឃ) ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

ទាក់ទងនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទទួលយកដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១០រូបក្នុងចំណោម២២រូបដែលត្រូវបានច្រានចោលនូវឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីដោយអង្គជំនុំជម្រះសាលាដំបូង ។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំង១០រូបដែលទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលរួមមាន៖

១) លី ហ៊ា ហៅ អ៊ា ហ៊ារ

២) ហ៊ឹម មុំ

៣) ឆាយ កន

៤) ហុង សាវ៉ាត

៥) ភោគ ខន

៦) ម៉ែន សុធា

៧) ឈឹម ស៊ីថា

៨) ណាំ ម៉ុន

៩) ROTHSCHILD Joshua

១០) JAMES Jeffrey

អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់ហេតុផលថាដើមបណ្ដឹងរដ្ឋប្បវេណីទាំង១០រូបនេះពិតជាបានបង្ហាញភស្តុតាងគ្រប់គ្រាន់នៅក្នុងបណ្ដឹងសាទុក្ខ ។ រីឯពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតត្រូវបានបដិសេធ ។

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលលើកឡើងពីកំហុសអង្គច្បាប់និងកង្វះភាពអាចយល់ដឹងជាមុនដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងកន្លងមក ។ ក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីយល់ថាអង្គជំនុំជម្រះសាលាដំបូងបានអនុម័តតាមទំនើងចិត្តនូវលក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃសេចក្ដីស្រលាញ់ ឬការរស់នៅក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់នៅក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះមិនផ្ទាល់ ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថាសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានរំលោភសិទ្ធិរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងនោះទេដោយបានផ្ដល់ហេតុផលថាការបង្កើតការសន្មតទុកជាមុននូវនិយមន័យនៃគ្រួសារសាច់ញាតិផ្ទាល់ដោយគិតអំពីប្រភេទព្យសនកម្មដែលទាមទារនៅក្នុងបរិបទនៃចំណងគ្រួសារក្នុងសង្គមកម្ពុជាគឺផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការមិនមែនផ្អែកលើសិទ្ធិរបស់ភាគីដើម្បីទទួលបានអត្ថប្រយោជន៍ពីការសន្មតទុកជាមុននោះទេ ។ សូមបញ្ជាក់ថានៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងបីក្រុមបានលើកឡើងថាអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តសកម្មភាពក្រៅដែនដីនៃអំណាចរបស់ខ្លួនដោយប្រើនិតិវិធីទទួលស្គាល់ឋានៈរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ការទទួលស្គាល់នេះធ្វើឡើងរហូតដល់ទៅពីរដំណាក់កាលគឺការទទួលស្គាល់ដំបូងនៅពេលសវនាការបឋមនិងក្រោយមកនៅពេលប្រកាសសាលក្រមដែលវិធីសាស្ត្រនេះមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងនោះទេ ។ អង្គជំនុំជម្រះសាលាដំបូងយក វិធីសាស្ត្រនេះមកប្រើដោយយោងទៅលើវិធាន១០០(១) នៃវិធានផ្ទៃក្នុងដែលមានចែងថា "អង្គជំនុំ ជម្រះនឹងធ្វើសេចក្ដីសម្រេចចិត្តចំពោះការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុង

សាលក្រមរបស់ខ្លួន» ។ នៅក្នុងបណ្តឹងសាទុក្ខដដែលនោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមថាអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានជូនដំណឹងឲ្យទាន់ពេលវេលាទៅដល់ភាគីទាំងឡាយដែលថាឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេនឹងត្រូវយកទៅពិចារណានៅពេលចុងបញ្ចប់នៃដំណើរការនីតិវិធីនិងប្រើប្រាស់បទដ្ឋានខ្ពស់ហួសហេតុទៅលើការពិនិត្យនិងបង្ហាញភស្តុតាងសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ចំពោះបណ្តឹងខាងលើដែលថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការទទួលយកប្រព័ន្ធនៃការពិនិត្យពីរដំណាក់កាលទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងគឺមានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការសម្រេចអំពីលក្ខណៈសម្បត្តិនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះនៅក្នុងសាលក្រមរបស់ខ្លួន ។ ចំពោះការលើកឡើងពាក់ព័ន្ធនឹងការខកខានមិនបានជូនដំណឹងជាមុនអង្គជំនុំជម្រះតុលាការកំពូលយល់ថាមិនបានធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ដោយហេតុថាដើមបណ្តឹងរដ្ឋប្បវេណីមានបន្ទុកក្នុងការបង្ហាញភស្តុតាងអំពីព្យសនកម្ម ។ ដូចនេះអង្គជំនុំជម្រះតុលាការកំពូលសម្រេចថាអង្គជំនុំជម្រះសាលាដំបូងពុំមានកំហុសអង្គច្បាប់ក្នុងការវាយតម្លៃនៅក្នុងសាលក្រមរបស់ខ្លួនអំពីថាតើភាពរងគ្រោះពិតប្រាកដត្រូវបានបង្ហាញគ្រប់គ្រាន់នៅក្នុងដំណាក់កាលសម្រេចរបស់ខ្លួនអំពីសំណង ដែរឬយ៉ាងណា ។

អង្គជំនុំជម្រះតុលាការកំពូល ក៏បានធ្វើការកែតម្រូវកំហុសទាក់ទងនឹងការភ្លេចបញ្ចូលអ្នកស្រី គឹម សុវណ្ណារី និងកូនរបស់គាត់ទៅក្នុងបញ្ជីឈ្មោះនៃជនរងគ្រោះក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទៅតាមបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជុំ ស៊ីរ៉ាត ។

### ខ) សំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

ចំពោះសំណងរដ្ឋប្បវេណី អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចចងក្រងនិងផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវរាល់សេចក្តីថ្លែងសុំអភ័យទោសនិងការទទួលស្គាល់ការទទួលខុសត្រូវដែលធ្វើឡើងដោយ ឌុច ក្នុងអំឡុងពេលដំណើរការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងនិងនៅអង្គជំនុំជម្រះតុលាការកំពូល ។ រីឯសំណើសុំទាមទារសំណងផ្សេងទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធដោយសារតែសំណើទាំងអស់នោះមិនអាចអនុវត្តបាននិងទាមទារឲ្យមានការចំណាយធនធានហិរញ្ញវត្ថុរបស់ ឌុច ដែលមិនមានលទ្ធភាពអាចចេញសងបាន ហើយសំណើមួយចំនួនក៏ជាការបង្គាប់ចំពោះរដ្ឋរបស់កម្ពុជា ។ គួរកត់សម្គាល់ថាសំណើដែលដើមបណ្តឹងរដ្ឋប្បវេណីក្រុម២បានស្នើសុំទៅអង្គជំនុំជម្រះតុលាការកំពូលមានប្រាំបួនចំណុចរួមមាន ៖

១) ការចែកផ្សាយយោបល់របស់ជនរងគ្រោះទៅលើពាក្យសុំអភ័យទោសរបស់ ឌុច ។

២) ការបង្គាប់ឲ្យ ឌុច សរសេរលិខិតទៅរដ្ឋាភិបាលកម្ពុជាស្នើសុំឲ្យធ្វើការសុំទោសជនរងគ្រោះក្នុងនាមជារដ្ឋ ។

៣) ផ្នែកខ្លះនៃចំណូលដែលបានមកពីការលក់សំបុត្រចូលសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងសារមន្ទីរប្រល័យពូជសាសន៍ជើងឯកត្រូវយកមកចំណាយសម្រាប់ជាសំណងជំងឺចិត្តផ្សេងៗ ។

៤) សាងសង់បូជនីយដ្ឋាននៅមន្ទីរស-២១ និងមន្ទីរស-២៤ ។

៥) កែប្រែគុកព្រៃសមកជាកន្លែងសម្រាប់រំឮកការចងចាំ ។

៦) ផ្គត់ផ្គង់មូលនិធិសម្រាប់ទស្សនកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់បូជនីយដ្ឋានទាំងឡាយ ។

៧) ផ្តល់សេវាសុខភាពផ្លូវកាយនិងផ្លូវចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

៨) ចែកចាយឯកសារតុលាការជាសំឡេង និងវីដេអូ ។

៩) ដាក់ឈ្មោះអគារសាធារណៈចំនួន១៧ ដោយប្រើប្រាស់ឈ្មោះជនរងគ្រោះនិងប្រារព្ធពិធី ផ្សេងៗ ។

ចំណែកដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣បានប្តឹងទាមទារសំណងទៅអង្គជំនុំជម្រះតុលាការកំពូលនូវសំណើចំនួន១៤ចំណុចដូចជា ៖

១) ផ្សព្វផ្សាយព័ត៌មានអំពីដំណើរការជំនុំជម្រះក្តីនៅតាមបណ្តាខេត្តនីមួយៗនៃព្រះរាជាណាចក្រកម្ពុជាដោយធ្វើការតាំងពិព័ណ៌នៅតាមទីធ្លាសាធារណៈ ។

២) ចងក្រង និងបោះពុម្ពផ្សាយពាក្យសំដីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ក្នុងអំឡុងពេលសវនាការដោយទទួលស្គាល់នូវការឈឺចាប់នានាដែលជនរងគ្រោះបានទទួលរងរួមជាមួយនឹងមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ។

៣) ផ្តល់ជូនជនរងគ្រោះនូវជំនួយផ្នែកសេវាថែទាំសុខភាពដោយឥតគិតថ្លៃដោយរួមបញ្ចូលទាំងការថែទាំវេជ្ជសាស្ត្រផ្នែករាងកាយនិងផ្លូវចិត្តនិងទទួលបាននូវការរ៉ាប់រងលើថ្លៃធ្វើដំណើរទៅនិងត្រឡប់ពីមណ្ឌលសុខភាព ។

៤) ផ្តល់ហិរញ្ញប្បទានដល់កម្មវិធីអប់រំនៅតាមសាលារៀននិងសារមន្ទីរនានាដើម្បីផ្សព្វផ្សាយដល់ពលរដ្ឋកម្ពុជាឲ្យដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហមជាពិសេសនៅសារមន្ទីរទួលស្លែង និងជើងឯក ។

៥) សាងសង់បូជនីយដ្ឋាននៅជើងឯក និងព្រៃស ។

៦) ឆ្លាក់ឈ្មោះជនរងគ្រោះទាំងឡាយដែលជាប់ឃុំឃាំងនៅមន្ទីរស-២១ នៅលើជញ្ជាំងខាងក្រោយនៃមន្ទីរស-២១ ។

៧) សាងសង់ស្លាកមួយដើម្បីជាការរំឭកដល់ជនរងគ្រោះដែលគេមិនស្គាល់អត្តសញ្ញាណ ។

៨) សាងសង់ផ្លូវដើរមួយអមជញ្ជាំងខាងក្រៅនៃមន្ទីរស-២១ ។

៩) ថែរក្សាអគារនិងបន្ទប់ឃុំឃាំងនៃមន្ទីរស-២១ឲ្យស្ថិតនៅក្នុងស្ថានភាពដើមនិងរក្សាទុកឲ្យបានគង់វង្សនូវឧបករណ៍ធ្វើទារុណកម្មនានាដែលនៅសេសសល់នៅទីនោះ ។

១០) ថែរក្សាបណ្ណសារទាំងឡាយដែលមាននៅមន្ទីរស-២១ រួមទាំងបណ្ណសារដែលបើកទូលាយដល់សាធារណជនប្រើប្រាស់ ។

១១) ថែរក្សាផ្ទាំងគំនូរដែលគូរដោយ វ៉ាន់ ណាត ដែលដាក់បង្ហាញនៅមន្ទីរស-២១ ។

១២) ថែរក្សាការពារសារមន្ទីរជើងឯក ។

១៣) បញ្ចូលក្នុងសាលក្រមស្តាពរនូវឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ព្រមទាំងការបញ្ជាក់អំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងមន្ទីរស-២១ ។ និង

១៤) ចុះផ្សាយផ្នែកនៃសាលក្រមអំពីអង្គហេតុទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទក៏ដូចជាផ្នែកសម្រេចសេចក្តីទៅក្នុងរាជកិច្ចនិងសារព័ត៌មានជាតិផ្សេងទៀតក្នុងរយៈពេលចាប់ពី៦ខែទៅមួយឆ្នាំបន្ទាប់ពីមានការជូនដំណឹងអំពីសាលក្រមនោះនិងធានាឲ្យមានការចាក់ផ្សាយសាលក្រមនេះជាប្រចាំនៅតាមបណ្តាញទូរទស្សន៍ និងវិទ្យុជាតិ ។

ការបដិសេធសំណើទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអង្គជំនុំជម្រះតុលាការកំពូលផ្តល់ហេតុផលថាខ្លួនពុំមានយុត្តាធិការក្នុងការសម្រេចផ្តល់សំណងទៅតាមសំណើសុំទាំងឡាយណាដែលតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីអាជ្ញាធរកម្ពុជាសម្រាប់អនុវត្តវិធានការនានាក្នុងការផ្តល់សំណងឡើយ ។ ទោះបីជា កាតព្វកិច្ចដែលមានកំណត់ច្បាស់លាស់ក្តីឬគ្រាន់តែជាភាពចាំបាច់ក្តី ។ ម្យ៉ាងវិញទៀត ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពិតជាមានសមត្ថកិច្ចក្នុងការផ្តល់សំណងក៏ដោយ ក៏សមត្ថកិច្ចនេះត្រូវតែបកស្រាយទៅតាមអាណត្តិការងារនិងគោលបំណងក្នុងន័យចង្អៀត ។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការបកស្រាយវិធាន២៣នៃវិធានផ្ទៃក្នុងដែលចែងថា «សំណងកំហិតត្រឹមតែសំណងជាសមូហភាពនិងផ្លូវចិត្ត ។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់បន្ថែមអំពីពាក្យថា "ផ្លូវចិត្ត" គឺជាបង្ហាញពីគោលដៅនៃព្យសនកម្មផ្លូវចិត្តដែលអាចជួសជុលបានហើយពុំមែនជាសម្ភារៈទេ ។ ចំណែកឯពាក្យថា "សមូហភាព" គឺមិនរាប់បញ្ចូលសំណងជាបុគ្គលទេ ទោះបីពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនឹងស្ថានភាពបុគ្គលក៏ដោយ ។ បន្ថែមពីលើនេះពាក្យថា "សមូហភាព" ក៏ជាវិធានការសម្រាប់ផ្តល់ប្រយោជន៍ដល់ជនរងគ្រោះដែលមានចំនួនច្រើនតាមដែលអាចធ្វើទៅបាន» ។

## សន្និដ្ឋាន

ទោះបីជា ឌុច ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ប៉ុន្តែសំណើសុំសំណងរបស់ជនរងគ្រោះស្ទើរតែទាំងអស់បានត្រូវអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលហើយ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនទៀតក៏ត្រូវ

បានច្រានចោលដែរ ។

ចំណែកឯពាក្យថា “មេដឹកនាំជាន់ខ្ពស់” និង“អ្នកទទួលខុសត្រូវខ្ពស់បំផុត” អង្គជំនុំជម្រះតុលាការកំពូលនៅតែពុំទាន់បានកំណត់ឲ្យច្បាស់លាស់ពីនិយមន័យនៃពាក្យទាំងពីរនេះទេ ដោយទុកសមត្ថកិច្ចក្នុងការកំណត់ថាតើនរណាជា “មេដឹកនាំជាន់ខ្ពស់” និង“អ្នកទទួលខុសត្រូវខ្ពស់បំផុត” ឲ្យសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតជាអ្នកទទួលខុសត្រូវ ។

ជារួមឃើញថា សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលបានក្លាយទៅជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយសម្រាប់ប្រទេសកម្ពុជាហើយក៏ជាសេចក្តីសម្រេចស្ថាពរលើកដំបូងបង្អស់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលសម្រេចពីជោគវាសនារបស់អ្នកទទួលខុសត្រូវមួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

## ប្រតិកម្មរបស់ជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីជុំវិញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល

នៅថ្ងៃដែលអង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីកាលើករណីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច មានប្រជាជនជាច្រើនមកពីកន្លែងផ្សេងៗគ្នាបានចូលរួមតាមដាននៅក្នុងបន្ទប់សវនាការនិងនៅពីខាងក្រៅនៃបន្ទប់សវនាការ ។ អ្នកកាសែតជាតិនិងអន្តរជាតិបានរង់ចាំស្តាប់លទ្ធផលនៃសាលដីកានៅក្នុងបន្ទប់អ្នកសារព័ត៌មានយ៉ាងច្រើនកុះករ ដើម្បីសរសេរអត្ថបទចុះផ្សាយនៅតាមបណ្តាស្ថាប័នរបស់គេរៀងៗខ្លួន ។ ជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមផ្តល់បទសម្ភាសន៍បង្ហាញពីអារម្មណ៍និងមតិយល់ឃើញរបស់ខ្លួនទៅលើលទ្ធផលនៃការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល ។

***១) ង៉ែត អ៊ុយ, ភេទស្រី,*** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងក្នុងសំណុំរឿង០០១ដោយឃើញ ឌុច ត្រូវបានកាត់ទោសឲ្យជាប់ទោសអស់មួយជីវិតខ្ញុំមានអារម្មណ៍សប្បាយរីករាយហើយពេញចិត្តជាមួយនឹងសាលក្រមចុងក្រោយនេះ ។ ប៉ុន្តែនៅពេលជាមួយគ្នាដែរ ខ្ញុំខកចិត្តជាមួយសាលាក្តីដែលបានបដិសេធលក្ខខណ្ឌជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំ ។ នៅចុងបញ្ចប់នៃថ្ងៃនោះ ឈ្មោះរបស់ខ្ញុំមិនមាននៅក្នុងបញ្ជីទេ ដោយសារខ្ញុំមិនមានឯកសារគ្រប់គ្រាន់ដើម្បីបង្ហាញ ។ ខ្ញុំមិនចង់ឈប់ត្រឹមនេះទេ ដូច្នេះខ្ញុំបន្តដាក់ពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណីនេះនៅក្នុងសំណុំរឿង០០២ទៀត ។ នៅពេលខ្ញុំដាក់ពាក្យដំបូងអ្វីដែលខ្ញុំចង់បាន គឺសំណងជាហិរញ្ញវត្ថុដើម្បីធ្វើបុណ្យឧទ្ទិសកុសលឲ្យប្តីរបស់ខ្ញុំ ប៉ុន្តែរយៈពេល៣-៤ឆ្នាំក្រោយមក ខ្ញុំដឹងច្បាស់ថាអ្វីដែលខ្ញុំត្រូវការគឺយុត្តិធម៌ ។ ឥឡូវនេះ ឌុច ទទួលបានការដាក់ទោសអស់មួយជីវិតដែលនេះមានន័យថាខ្ញុំអាចមានអ្វីមួយដើម្បីផ្តល់ទៅឲ្យព្រលឹងប្តីរបស់ខ្ញុំ ។ ខ្ញុំមានអារម្មណ៍ធូរស្បើយមួយកម្រិត ។ ជាពិសេសខ្ញុំពេញចិត្តនឹងការចូលរួមរបស់ខ្ញុំនៅក្នុង ដំណើរការនេះអស់រយៈពេលជាច្រើនឆ្នាំ ។ ខ្ញុំមិនគិតថា ខ្ញុំខឹងនឹង ឌុច ទៀតទេ ពីព្រោះឥឡូវនេះគាត់បានជាប់ទោស ហើយគង់តែស្លាប់នៅក្នុងគុក ។ គាត់នឹងទទួលរងដូចដែលប្តីរបស់ខ្ញុំបានទទួលរង ។

***២) នង សាវ៉ាត, ភេទប្រុស,*** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងក្នុងសំណុំរឿង០០១ខ្ញុំពិតជាមានការអន់ចិត្តខ្លាំងណាស់នៅពេលដែលបែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំត្រូវបានបដិសេធម្តងទៀតតាំងពីសាលាដំបូងរហូតដល់តុលាការកំពូល ។ ចំពោះការកាត់ទោស ឌុច នេះ គឺខ្ញុំពេញចិត្តជាខ្លាំង ប៉ុន្តែខ្ញុំចង់ឲ្យតុលាការពិចារណាលើសំណុំរឿងរបស់ខ្ញុំម្តងទៀតចំពោះការឈឺចាប់របស់ខ្ញុំ ។ ពូរបស់ខ្ញុំទាំងពីរនាក់ពិតជាត្រូវបានយកមកសម្លាប់នៅគុកទួលស្លែងប្រាកដមែន ។ ខ្ញុំសម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការនេះគឺដើម្បីស្វែងរកយុត្តិធម៌សម្រាប់ពូជាទីស្រឡាញ់របស់ខ្ញុំ ។ យុត្តិធម៌ចំពោះខ្ញុំគឺមានន័យថាការឈឺចាប់របស់ខ្ញុំត្រូវបានទទួលស្គាល់ ។

***៣) នង ចាន់ផល, ភេទប្រុស, ជាជនរងគ្រោះពីមន្ទីរស-២១***

ខ្ញុំពេញចិត្តនឹងសាលដីកាស្ថាពរនេះណាស់ ដោយសារតែសាលដីកានេះ គឺដូចអ្វីដែលខ្ញុំរំពឹងទុកអ៊ីចឹង ។ ខុសពីសាលក្រមពីមុនសាលដីកាស្ថាពរនេះបានផ្តល់នូវសេចក្តីសង្ឃឹមដល់ខ្ញុំថាយុត្តិធម៌ពិតជាបានផ្តល់មកឲ្យខ្ញុំពិតមែន ក៏ដូចជាជនរងគ្រោះដទៃទៀតផងដែរនៅស-២១នេះ ។ កន្លងមកនេះ គ្រួសាររបស់ខ្ញុំបានជួយសម្រាលការឈឺចាប់របស់ខ្ញុំ ។ ហើយសាលដីកាស្ថាពរនេះនឹងជួយកាត់បន្ថយអតីតកាលឈឺចាប់របស់ខ្ញុំបាន ។ ខ្ញុំយល់ឃើញថាតុលាការបានផ្តល់នូវយុត្តិធម'ដល់ខ្ញុំក៏ដូចជាប្រជាជន

កម្ពុជាទាំងអស់ផងដែរ ។ ខ្ញុំមិនស្តីបន្ទោសដល់កម្មាភិបាលថ្នាក់ក្រោមចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើងនៅគុកទួលស្លែងនោះទេ ។ ទោះបីជាពួកគេមានតួនាទីជាជនដៃដល់ផ្ទាល់ក៏ដោយឧក្រិដ្ឋកម្មដ៏ធំសម្បើមដែលកើតមានឡើងនៅទួលស្លែងគឺវាធំធេងនិងធ្ងន់ធ្ងរខ្លាំងពេកដែលយើងមិនអាចធ្វើការបន្ទោសតែកម្មាភិបាលថ្នាក់ក្រោមតែឯងបាននោះទេ ។

### ៤) ពេត ស៊ុក, អាយុ៨០ឆ្នាំ, មកពីតាខ្មៅ ខេត្តកណ្តាល

ខ្ញុំគិនថា ឌុច សក្តិសមនឹងទទួលការដាក់ទោសក្នុងគុកអស់មួយជីវិត ដោយសារតែមានមនុស្សជាច្រើនរងគ្រោះនៅក្នុងរបបនោះ ។ សាលដីកានេះមិនបានជួយឲ្យខ្ញុំមានអារម្មណ៍ធូរស្បើយពីការឈឺចាប់ដែលខ្ញុំទទួលរងដោយការបាត់បង់សាច់ញាតិនៅក្នុងរបបនោះទេ ។ ខ្ញុំនៅតែគិតថា វាជាការចាំបាច់បំផុតដែលមេដឹកនាំខ្មែរក្រហមត្រូវបានកាត់ទោសដើម្បីរកយុត្តិធម៌ជូនចំពោះអ្នកដែលត្រូវបានកម្ទេចនៅក្រោមរបបខ្មែរក្រហម ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមចាប់ដាក់គុក ធ្វើទារុណកម្ម និងសួរចម្លើយដែរ ។ ខ្ញុំក៏ត្រូវបានខ្មែរក្រហមដាក់ខ្នោះជើងជាមួយអ្នកជាប់ឃុំឃាំងដទៃទៀតដែរ ។

### ៥) ហ្សេង ស៊ីន, អាយុ៦៧ឆ្នាំ, មកពីតាខ្មៅ ខេត្តកណ្តាល

ខ្ញុំពេញចិត្តនឹងសាលដីកានេះ ។ ឌុច បានធ្វើឲ្យមនុស្សជាច្រើនស្លាប់បាត់បង់ជីវិតនៅមន្ទីរសន្តិសុខនោះ ។ ដូច្នេះគាត់ស័ក្កសមនឹងទទួលនូវការកាត់ទោសនេះ ។ ខ្ញុំគិតថានេះជាសំណាងមួយសម្រាប់យើងទាំងអស់គ្នាដែលទទួលបានយុត្តិធម៌បន្ទាប់ពីភាពសាហាវឃោរឃៅនៃរបបនេះបានកន្លងផុតទៅអស់រយៈពេលជាង៣០ឆ្នាំ ។ ប្រសិនបើតុលាការខកខានមិនបានកាត់ទោសគាត់ខ្ញុំនឹងមាកការសោកស្តាយដោយហេតុថាយុត្តិធម៌មិនអាចសម្រេចបានសម្រាប់កម្ពុជា ។ ការដាក់ទោសមួយជីវិតគឺគ្រប់គ្រាន់ទៅនឹងទង្វើដែលគាត់បានប្រព្រឹត្តនៅក្នុងរបបនោះ ។ ខ្ញុំមិនចង់ប្រើអំពើហិង្សាទៅលើរូបគាត់ឬក៏កម្មាភិបាលខ្មែរក្រហមដទៃទៀតនោះទេ ។ យើងទាំងអស់គ្នារស់នៅក្រោមច្បាប់ ។

### ៦) អ៊ុយ ប៊ុណ្ណារិន, ភេទប្រុស, អាយុ៥១ឆ្នាំ មកពីទីក្រុងភ្នំពេញ

ខ្ញុំគាំទ្រសាលដីកាបណ្តឹងឧទ្ធរណ៍នេះមួយរយភាគរយ ។ ខ្ញុំគិតថាសាលដីកាដែលចេញកាលពីមុនដែលសម្រេចដាក់ទោសឌុច រយៈពេល៣៥ឆ្នាំ ហើយបន្ថយសល់ត្រឹម១៩ឆ្នាំ គឺវាមិនគ្រប់គ្រាន់នោះទេ បើប្រៀបធៀបទៅនឹងឧក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្ត ។ ខ្ញុំគិតថាការដាក់ឃុំឃាំងមួយជីវិតអាចជួយឲ្យគាត់ដឹងពីកំហុសដែលគាត់បានប្រព្រឹត្ត ។ សាលដីកានេះវាមានអត្ថន័យណាស់សម្រាប់រូបខ្ញុំ ក្រុមគ្រួសាររបស់ខ្ញុំ ហើយនិងក្មេងជំនាន់ក្រោយ ។ វាគឺជាឧទាហរណ៍មួយសម្រាប់បញ្ជាក់ប្រាប់ក្មេងជំនាន់ក្រោយឲ្យដឹងថាគ្មាននរណាម្នាក់អាចគេចផុតពីកំហុសដែលខ្លួនបានប្រព្រឹត្តនោះទេ ។ វានឹងជួយឲ្យកូនៗរបស់ខ្ញុំ បានយល់ដឹងថាមេដឹកនាំប្រទេសគ្រប់រូបនឹងមិនអាចគេចផុតពីការផ្តន្ទាទោសតាមច្បាប់បាននោះទេ នៅ ពេលដែលគេប្រព្រឹត្តខុស ។

### ៧) ស្មាន រស់, ភេទប្រុស, អាយុ៦៧ឆ្នាំ មកពីស្រុកពញាឮ ខេត្តកណ្តាល

ខ្ញុំក៏មានសាច់ញាតិស្លាប់នៅគុកទួលស្លែងដែរ ។ ខ្ញុំបានឮពីសវនាការកាត់ទោសមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ។ ខ្ញុំមិនបានដឹងពិតប្រាកដថា ឌុច ត្រូវបានដាក់ឃុំឃាំងប៉ុន្មានឆ្នាំនោះទេ ។ ទើបតែថ្ងៃនេះទេដែលខ្ញុំដឹងច្បាស់ថា ឌុច ត្រូវបានដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ដោយសារតែវាជាការដាក់ទោសរយៈពេលវែងបំផុតនិងធ្ងន់ធ្ងរបំផុតនៃអំពើឧក្រិដ្ឋកម្ម ខ្ញុំពេញចិត្តនឹងការសម្រេចចិត្តបែបនេះ ។ ប្រសិនបើចៅក្រមសម្រេចចិត្តបន្ធូរបន្ថយការដាក់ទោសត្រឹមតែរយៈពេល១៥ទៅ២០ឆ្នាំនោះវានឹងមិនមានយុត្តិធម៌ទេ ។ ខ្ញុំគិតថាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ជាពិសេសគឺរឿងរ៉ាវ របស់ ឌុច និងសវនាការកាត់ទោសគាត់គួរតែរក្សាទុកដើម្បីយកមកបង្រៀនក្មេងជំនាន់ក្រោយ និងជន ជាតិដទៃទៀត ។

**ប្រវត្តិដំណើររឿងនៃជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលរងគ្រោះដោយសារឧក្រិដ្ឋកម្មនៅគុកទួលស្លែង :**

## ខ្ញុំចង់ដឹងថា ឌុច មានអារម្មណ៍បែបណា បើសិនជាគាត់មានកូនជាប់នៅមន្ទីរ ស-២១?

### ម៉ែន ឡាយ

នៅក្នុងរបប ប៉ុល ពត ខ្ញុំរស់នៅភូមិព្រែកប៉ែ ឃុំកោះធំ

ស្រុកកោះដាច់ ខេត្តកណ្តាល ។ ដូចគ្នា នឹងអ្នករស់រានមានជីវិតរាប់លាននាក់ផ្សេងទៀត ខ្ញុំបានបាត់បង់កូនប្រុសម្នាក់ឈ្មោះ មីន កន នៅពេលដែលខ្មែរក្រហមបាននាំកូនខ្ញុំយកទៅកាលពីឆ្នាំ១៩៧៥ ។

មីន កន បានចូលបម្រើកងទ័ពខ្មែរក្រហមនៅអាយុ១៦ឆ្នាំ ។ កូនខ្ញុំបានចេញពីផ្ទះទៅធ្វើសង្រ្គាមប្រឆាំងទាហាន លន់ នល់ ជាមួយនឹងកម្មាភិបាលផ្សេងទៀតប្រដាប់ដោយអាវុធ ។ ខ្ញុំបានបន្តរស់នៅនិងធ្វើការក្នុងភូមិដដែល ហើយក៏មិនបានឮដំណឹងអ្វីសោះពីកូនខ្ញុំ ។ នៅឆ្នាំ១៩៧៥ មីន កន បានមកលេងផ្ទះម្តងដោយស្លៀកពាក់ជានាយទាហាន ។ ក្រោយពេលដែលយើងនិយាយគ្នាបានមួយភ្លេតប្រធានភូមិក៏បានមកដល់ ហើយបានចាប់ខ្លួនកូនខ្ញុំយកទៅដោយនិយាយថាអង្គការចោទកូនខ្ញុំថាបានចាកចេញពីមូលដ្ឋានដោយគ្មានការអនុញ្ញាត ។ ក្រុមគ្រួសារខ្ញុំមិនអាចជួយអ្វីបានទេពីព្រោះកម្មាភិបាលថ្នាក់ឃុំគឺផ្តាច់ការ ។

កូនខ្ញុំបានមកលេងផ្ទះជាមួយសមមិត្តរួមការងារជាមួយគ្នាបីនាក់ទៀតដែលជាអ្នកភូមិព្រែកប៉ែ ។ យ៉ាងណាមិញ ខ្ញុំមិនប្រាកដថាតើសមមិត្តទាំងបីនាក់នោះត្រូវបានចាប់ខ្លួនបុបញ្ជូនទេមូលដ្ឋានវិញដែរឬយ៉ាងណានោះទេ ។ កូនប្រុសខ្ញុំមិនដឹងថាបាត់ខ្លួនទៅដល់ទីណាទេចាប់តាំងពីត្រូវបានចាប់ខ្លួនមក ។ ក្នុងរបបខ្មែរក្រហមបើទោះបីជាប្រជាជនគ្រប់គ្នាត្រូវបានបង្ខំឲ្យធ្វើការងារពេញមួយថ្ងៃដោយគ្មានពេលសម្រាកក៏ដោយ ក៏ក្រុមគ្រួសារខ្ញុំនៅតែព្យាយាមស្វែងរកដំណឹងកូនខ្ញុំ ។ ជាអកុសល យើងមិនទទួលបានព័ត៌មានអ្វីទាល់តែសោះដោយបានត្រឹមតែដឹងថាកូនខ្ញុំត្រូវបាននាំទៅមន្ទីរ១៥ ដោយមេបញ្ជាការរបស់គេប៉ុណ្ណោះ ។

នៅខែកញ្ញាឆ្នាំ២០០៨ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគល់ប្រវត្តិរូបកូនប្រុសខ្ញុំដែលរក្សាទុកនៅគុកទួលស្លែងមកឲ្យខ្ញុំ ។ ខ្ញុំមានអារម្មណ៍រន្ធត់នៅពេលដែលបានដឹងថាកូនប្រុសខ្ញុំត្រូវបានចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែងដ៏សាហាវព្រៃផ្សៃនោះដែលជាកន្លែងធ្វើទារុណកម្មលើអ្នកទោសដ៏សាហាវមុនពេលដែលអ្នកទាំងនោះត្រូវបានសម្លាប់ ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបរាប់ពីដំណើរប្រតិបត្តិការរបស់គុកទួលស្លែងដូចជាការចាប់ខ្លួននិងសម្លាប់អ្នកទោសជាលក្ខណៈប្រព័ន្ធហើយក៏បានប្រាប់ខ្ញុំថា ឌុច ដែលជាប្រធានគុកទួលស្លែងនោះត្រូវបានកាត់ទោសក្នុងសំណុំរឿង០០១ ដោយសាលាក្តីខ្មែរក្រហម ។

មុននឹងទទួលបានការអះអាងពីការស្លាប់របស់កូនប្រុសខ្ញុំ ខ្ញុំតែងតែសង្ឃឹមថាកូនខ្ញុំនៅរស់ហើយនឹង វិលត្រឡប់មកផ្ទះវិញនៅថ្ងៃណាមួយជាមិនខាន ។ ជាញឹកញាប់ខ្ញុំដេកមិនលក់ហើយតែងតែឈឺក្បាលរាល់ពេលដែលខ្ញុំគិតពីកូនប្រុសខ្ញុំ ។ ការស្រមើស្រមៃពីការធ្វើទារុណកម្ម និងការសម្លាប់មកលើកូនប្រុសគាត់បានធ្វើឲ្យខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ។ បើសិនជាតើ ឌុច មានអារម្មណ៍យ៉ាងដូចម្តេចនៅពេលកូនប្រុសស្រីរបស់ ឌុច ត្រូវបានចាប់ខ្លួនទៅទួលស្លែង ។

ដើម្បីជាការគោរពវិញ្ញាណកូនប្រុសខ្ញុំ ខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់រឿងក្តី០០១នៅឯសាលាក្តីខ្មែរក្រហម ។ សេចក្តីសម្រេចនេះបានធ្វើឲ្យខ្ញុំធូរស្បើយខ្លះ ដោយសារតែខ្ញុំបានចូលរួមក្នុងសវនាការ ហើយមានឱកាសចែករំលែកការឈឺចាប់ជាមួយនឹងអ្នករស់រានមានជីវិតផ្សេងទៀត ។ ខ្ញុំក៏សង្ឃឹមថា ឌុច នឹងទទួលបានការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។


ម៉ែន ឡាយ

## ម្តាយដែលជាវីរៈនារីរបស់ខ្ញុំ

*ហាវ សោភា*

“មុនពេលដែលឪពុកឯងចាកចេញទៅ គាត់បានប្រាប់ម៉ែថាឲ្យដាក់ឈ្មោះកូនថា សោភា បើ សិនម៉ែកើតបានកូនស្រី ។ បើសិនកូននោះជាកូនប្រុសគាត់និយាយថា “ចាំគាត់ត្រឡប់មកវិញសិនទើបដាក់ឈ្មោះឲ្យកូននេះ” ។ ជាសំណាង កូនឯងគឺជាកូនស្រីបើមិនមែនកូនស្រីទេ ម៉ែនឹងដាក់ឈ្មោះកូននោះថាចាំសន្យា ។ ជាអកុសល ការសន្ទនារវាងម៉ែ និងពុកឯងនេះគឺជាការសន្ទនាលើកចុងក្រោយបង្អស់របស់យើង ។ ចាប់តាំងពីពេលនោះមកពុកឯងមិនត្រឡប់មកវិញឡើយ” ។ នេះគឺជាពាក្យសម្តី ដែលម្តាយខ្ញុំបានប្រាប់ខ្ញុំឪម្តាយខ្ញុំបានទទួលមរណៈភាពក្លាម ៗ ក្រោយ ពេលដែល ឌុច ត្រូវបានកាត់ ទោសឲ្យជាប់ពន្ធធានាគារអស់មួយជីវិត ។


ហាវ សោភា

ដោយសារតែខ្ញុំធំដឹងក្តីឡើងដោយគ្មានឪពុក ខ្ញុំបានរំពឹងចង់ឃើញមុខពុកទទួលបានការថ្នាក់ថ្នមពីពុក និងចង់ហៅគាត់ថា“ពុក” ។ ម្តាយខ្ញុំ និងខ្ញុំបានសង្ឃឹមថាពុកនៅរស់រានមានជីវិត ហើយគាត់នឹងត្រឡប់មកផ្ទះនៅថ្ងៃណាមួយមិនខាន ។ ប៉ុន្តែពុកបាត់ខ្លួនរហូត ហើយខ្ញុំបានត្រឹមតែដឹងពីរឿងរ៉ាវខ្លះៗរបស់ពុកតាមរយៈម្តាយខ្ញុំតែប៉ុណ្ណោះ ។ កាលពីខ្ញុំមានប្រហែល៦ និង៧ឆ្នាំ ម្តាយខ្ញុំតែងតែនិយាយពីពុក និងខ្សែជីវិតរបស់គាត់កាលពីរបបខ្មែរក្រហម ។ ម៉ែបានប្រាប់ថា ពុកជាមនុស្សស្លូតបូត ចេះជួយយកអាសាររួសរាយរាក់ទាក់និងខស្សរាប់ព្យាយាម ។ អ្នកភូមិចូលចិត្តពុកគ្រប់គ្នា ។ រឿងរ៉ាវទាំងនេះបានធ្វើឲ្យខ្ញុំស្រឡាញ់និងគោរពពុក បើទោះបីជាខ្ញុំមិនដែលឃើញមុខគាត់ក៏ដោយ ។ ខ្ញុំតែងតែសង្ឃឹមថានឹងបានជួយពុកនៅថ្ងៃណាមួយជាមិនខាន ។ ខ្ញុំបានកើតភ្លាមៗក្រោយពេលដែលឪពុកខ្ញុំបានបាត់ខ្លួន ។ ពុកបានចូលបំរើចលនាខ្មែរក្រហមនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ ហើយគាត់ត្រូវបានបញ្ជូនទៅប្រទេសវៀតណាម ហើយត្រឡប់មកប្រទេសកម្ពុជាវិញនៅទសវត្សរ៍ឆ្នាំ១៩៦០ ។ ម៉ែនិយាយថា ពុកបានធ្វើការងារពលីដើម្បីប្រទេសជាតិ ។ ពុកតែងតែនិយាយប្រាប់ម៉ែថា គាត់នឹងលាលែងឈប់ធ្វើយោធា ហើយនឹងត្រឡប់មករស់នៅជាមួយម៉ែក្នុងជីវភាពសាមញ្ញបំផុតនៅពេលដែលប្រទេសជាតិទទួលបានសន្តិភាព ។ ប៉ុន្តែនៅពាក់កណ្តាលឆ្នាំ១៩៧៥ ពុកនិងម៉ែត្រូវបានបញ្ជូនទៅបឹងត្របែកនៅភ្នំពេញជាមួយនឹងយោធាជាច្រើននាក់ទៀតដែលទើបតែនឹងត្រឡប់មកពីប្រទេសវៀតណាម ។ នៅបឹងត្របែកម៉ែបានធ្វើជាអ្នកថែទាំក្មេងនិងជាចុងភៅ ។ ចំណែក ឯពុកវិញគាត់នៅតែធ្វើជាយោធាដដែល ។ ពុកជាមនុស្សដ៏ស្លូតបំផុតហើយគាត់មិនដែលសំឡុតប្តូនិយាយដោយអាងអំណាច បើទោះបីជាម៉ែខឹងនឹងគាត់ក៏ដោយ ។ ម៉ែបាននិយាយថា ពុកជាមនុស្សមានហេតុផល និងស្ងប់ស្ងាត់ ។ ដូច្នេះអ្នកទាំងពីរតែងតែគោរពគ្នាទៅវិញទៅមក ។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ គឺជាថ្ងៃដ៏ជូរចត់ និងអាប់អួរបំផុតក្នុងជីវិតរបស់ម្តាយខ្ញុំ ។ នៅថ្ងៃនោះ ពុកបានប្រាប់ម៉ែថាគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការ ប៉ុន្តែតាមពិតម៉ែមិនបានដឹងថាការចាត់តាំងនោះមានន័យថាពុកនឹងត្រូវយកទៅសម្លាប់ទេ ។ ម៉ែបានប្រាប់ខ្ញុំថា បើសិនជាម៉ែបានដឹងមុននោះគាត់នឹងឃាត់ពុកឬតាមពុករហូតបើទោះបីជាម៉ែត្រូវស្លាប់ជាមួយពុកក៏ដោយ ។ ប៉ុន្តែ ម៉ែមិនបានគិតសង្ស័យថាពុកអាចនឹងមានគ្រោះថ្នាក់ឡើយ ។ ក្រោយពេលដែលពុកចាកចេញទៅ ម៉ែត្រូវបានបញ្ជូនទៅក្បាលជ្រោយ ។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ម៉ែកើតបានខ្ញុំ ។ ប៉ុន្មានសប្តាហ៍ក្រោយមក ម៉ែត្រូវបានបង្ខំឲ្យដងទឹកពីទន្លេមកស្រោចដំណាំ ទោះបីជាសុខភាពគាត់នៅទន់ខ្សោយក៏

ដោយ ។ រហូតដល់រយៈពេល៩ខែក្រោយមកទៀតទើបកម្មាភិបាលខ្មែរក្រហមបានប្រាប់ម៉ែថាពុកត្រូវបានចាប់ខ្លួន ។ ព្រួដូច្នោះម៉ែមានអារម្មណ៍រន្ធត់ចិត្ត ហើយនិយាយមិនចេញទាល់តែសោះ ។ ទោះជាយ៉ាងណាក្តី ម៉ែនៅតែមានជំនឿថាពុកនៅរស់រានមានជីវិត ពីព្រោះពុកគឺជាមនុស្សឆ្លាត ហើយអាចនឹងរស់គេចខ្លួនទៅវៀតណាមក៏ថាបាន ។ យ៉ាងណាមិញ ម៉ែមិនអនុញ្ញាតឲ្យយំទេ ហើយត្រូវតែនៅស្ងៀមគ្មានប្រតិកម្មអ្វីក្រៅពីបន្តធ្វើការងារដូចធម្មតា ។ ប៉ុន្តែ ម៉ែនៅតែគិតពីពុកក្នុងចិត្តរហូត ។

នៅក្នុងអំឡុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសម៉ែនិងខ្ញុំទៅស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម ។ ម៉ែត្រូវបានចាត់តាំងឲ្យជីករណ្តៅចំនួន៦០ក្នុងមួយថ្ងៃដើម្បីដាំដើមចេក ។ ចំណែកខ្ញុំវិញត្រូវបានចាត់តាំងឲ្យចូលក្នុងកងកុមារ ។ ម៉ែបានប្រាប់ខ្ញុំថាម៉ែបានលួចបង្រៀនខ្ញុំឲ្យហៅគាត់ថា "ម៉ែ" មិនមែន"មីង" ដូចដែលអ្នកថែទាំងក្មេងបានបង្គាប់ខ្ញុំទេ ។ ស្ថានភាពរស់នៅតាមតំបន់ភ្នំនៅស្រុកស្ទឹងត្រង់គឺពិតជាលំបាកហើយម៉ែបានប្រាប់ខ្ញុំថា ខ្ញុំគឺជាមូលហេតុតែមួយគត់ដែលគាត់ត្រូវតែតស៊ូរស់ ។

នៅពេលដែលកងទ័ពវៀតណាមបានវាយចូលប្រទេសកម្ពុជា ខ្មែរក្រហមបានព្យាយាមជម្លៀសយើងទាំងពីរនាក់តែម៉ែបានរត់គេចខ្លួនហើយបានធ្វើដំណើរត្រឡប់មកកាន់ភូមិកំណើតរបស់គាត់វិញ ។ នៅតាមផ្លូវខណៈពេលដែលយើងទាំងពីរនាក់កំពុងតែគេចគ្រាប់កាំភ្លើងនិងគ្រាប់បែក ម៉ែស្ទើរតែសន្លប់បាត់ស្មារតីនៅពេលដែលគាត់បានឮខ្ញុំសួរថា "ឯណាពុក?" នៅពេលដែលយើងមកដល់ភូមិវិញ គ្រួសារសាច់ញាតិរបស់ម៉ែ និងអ្នកភូមិផ្សេងទៀតភ្ញាក់ផ្អើលនៅពេលដែលឃើញម៉ែមានរូបរាងស្គមស្គាំង និងស្លៀកសំលៀកបំពាក់ដាច់រហែក ។ ម៉ែគ្មានបានយកអ្វីមកជាមួយទេក្រៅពីស្លាបព្រាមួយ និងរូបខ្ញុំតែប៉ុណ្ណោះ ។ ក្រោយមក ម៉ែបានសម្រេចចិត្តសង់ខ្ទមតូចមួយនៅដាច់ស្រយាលពីគេដែលម៉ែនិងខ្ញុំអាចរស់នៅដោយស្ងប់ស្ងាត់ ។ ម៉ែធ្វើការងារគ្រប់បែបយ៉ាងទាំងអស់ ហើយខ្ញុំបានជួយរែកដី និងលក់បន្លែ ។ ខ្ញុំចាំថា ខ្ញុំពិតជាចង់ទៅរៀនខ្លាំងណាស់កាលពីនៅក្មេង ប៉ុន្តែម៉ែបានបដិសេធ ដោយសារតែគាត់បារម្ភពីសុវត្ថិភាពខ្ញុំ ។ ប៉ុន្តែគាត់បានបង្រៀនស្រះ និងព្យញ្ជនៈដល់ខ្ញុំរាល់យប់ ដើម្បីឲ្យខ្ញុំអាចចូលរៀនថ្នាក់ធំជាមួយនឹងមីងខ្ញុំបាន ។



ហាវ សោភា ចូលរួមប្រារព្ធព្រះពុទ្ធសាសនានៅវាលពិឃាដជើងឯក

នៅពាក់កណ្តាលទសវត្សរ៍៨០ ម៉ែនៅតែជឿជាក់ថាពុកនៅរស់នៅឡើយ ។ រាល់ល្ងាចម៉ែតែងតែនាំខ្ញុំទៅទំនប់១មករាដើម្បីស៊ើបសួររកដំណឹងពុក ។ អ្នកខ្លះបាននិយាយថាធ្លាប់បានឃើញពុក ចំណែកឯអ្នកខ្លះទៀតនិយាយថាពុកត្រូវបានចាប់ខ្លួន ។ បើទោះបីជាមានសង្ឃឹមតិចតួចក៏ដោយ ក៏ម៉ែនៅតែព្យាយាមស៊ើបដំណឹងពីពុកបន្ថែមទៀត ។ រាល់ពេលដែលដឹងថាមានមនុស្សវិលត្រឡប់មកភូមិវិញម៉ែតែងតែនាំខ្ញុំទៅភូមិដោយសង្ឃឹមថាក្រុមគ្រួសារយើងនឹងបានជួបជុំគ្នាវិញ ។ យើងទាំងពីរនាក់ខកចិត្តម្តងហើយម្តងទៀតមិនចេះចប់ ។ នៅឆ្នាំ១៩៩២ បន្ទាប់ពីការព្យាយាមជាច្រើនលើកជាច្រើនសារយើងមិនអាចបន្តស៊ើបរកដំណឹងពុកតទៅទៀតឡើយ ហេតុដូច្នេះ ម៉ែក៏សម្រេចចិត្តឈប់តាមរកពុក ។ ប៉ុន្តែម៉ែមិនដែលបំភ្លេចពុកឡើយ ។ របស់របបដែលធ្វើឲ្យម៉ែចងចាំពុកដែលរួមមានខ្សែក្រវ៉ាត់ដែលពុកឲ្យម៉ែពេលដែលអ្នកទាំងពីរទើបតែរៀបការថ្មីៗ ប្រអប់បាយរបស់ទាហានដែលម៉ែបានយកមកប្រើត្រីវិស័យបែកមួយនិងភ្លើងម៉ូតូត្រូវបានរក្សាទុកយ៉ាងប្រយ័ត្ន ។

ដោយបានថែរក្សាវត្ថុតាងទាំងអស់នេះម៉ែមានអារម្មណ៍ថាការចងចាំរបស់គាត់ពីពុកនឹងមិនសាបសូន្យឡើយ ។ ដោយសារតែជីវភាពរស់នៅខ្វត់ខ្សោយខ្ញុំបានឈប់រៀន ហើយជួយម៉ែរកលុយ បើទោះបីជាខ្ញុំចង់រៀនបន្តក៏ដោយ ។ មូលហេតុដែលខ្ញុំចង់ឲ្យពុកត្រឡប់មកវិញគឺដើម្បីជួយឲ្យខ្ញុំបានទទួលការអប់រំល្អ ។ ខ្ញុំមានក្តីស្រមៃមួយគឺថាខ្ញុំចង់ធ្វើជាមេធាវីឬជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ ។ ជាអកុសល ខ្ញុំមិនអាចសម្រេចក្តីស្រមៃរបស់ខ្ញុំបានឡើយ ។ ជីវិតយើងទាំងពីរនាក់ហាក់បីដូចជាមានតែកាយតែគ្មានវិញ្ញាណ ។ យើងរស់នៅដោយស្ងៀមស្ងាត់ឯកោនិងគ្មានសង្ឃឹម ។ នេះគឺជាលទ្ធផលដែលរបបខ្មែរក្រហមបានប្រែក្លាយជីវិតគ្រួសារខ្ញុំ ។

ខណៈពេលដែលពេលវេលាចេះតែកន្លងផុតទៅ យើងនៅតែបន្តរង់ចាំដំណឹងពីពុកថាតើពុកនៅរស់ឬក៏ស្លាប់ដើម្បីឲ្យយើងបានសប់ចិត្តខ្លះ ។ ប៉ុន្តែ យើងមិនទទួលបានដំណឹងអ្វីទាល់តែសោះ ។ ការរង់ចាំដោយគ្មានក្តីសង្ឃឹមគឺឈឺចាប់ណាស់ ប៉ុន្តែម៉ែមិនដែលរអ៊ូឡើយ ។ ក្រៅពីរងទុក្ខផ្លូវចិត្តម៉ែ ត្រូវប្រឹងធ្វើការធ្ងន់ដើម្បីជីវភាព ហើយម៉ែមិនដែលបានដេកគ្រប់គ្រាន់ឡើយ ។ រាល់យប់ ម៉ែតែងតែសម្លឹងមើលមេឃមើលផ្កាយតាមបង្អួច ។ គាត់គិតតែម្នាក់ឯង ហើយឈឺចាប់ក្នុងចិត្ត ។ ម៉ែមិនចូលចិត្តទៅណាហើយក៏មិនសូវដើរតាមភូមិដែរ បើទោះបីជាខ្ញុំបានជំរុញលើកទឹកចិត្តគាត់ជាច្រើនលើកក៏ដោយ ។ រាល់លើកម៉ែតែងតែឆ្លើយថា «មិនថាកន្លែងណាដែលម៉ែទៅ កន្លែងនោះគឺគ្មានន័យអ្វីសម្រាប់ជីវិតម៉ែឡើយ ។ ម៉ែមិនដឹងជាប្រាប់ឯងយ៉ាងម៉េចទេ ។ ខ្លួនម៉ែដូចជាគ្មានវិញ្ញាណអ្វីទាំងអស់ចាប់តាំងពីការបាត់ខ្លួនរបស់ពុកឯង ។ វាបានបន្កជារបួសដ៏ធំមួយក្នុងជីវិតរបស់ម៉ែ ។ របួសនេះអាចព្យាបាលបាននៅពេលដែលម៉ែស្លាប់ទៅប៉ុណ្ណោះ» ។

ក្រោយពីបានចាំអស់រយៈពេលសាមសិបឆ្នាំជាចុងក្រោយ យើងបានដឹងថាការរង់ចាំរបស់យើងគឺគ្មានអ្វីក្រៅពីដំណឹងនៃការស្លាប់របស់ពុកនៅគុកទួលស្លែងឡើយ ។ នៅចុងឆ្នាំ២០០៦ ខ្ញុំបានទៅសួរសុខទុក្ខបងប្អូនជីដូនមួយរបស់ខ្ញុំនៅទីក្រុងភ្នំពេញ ហើយនៅពេលនោះហើយដែលខ្ញុំបានទទួលដំណឹងពីការបាត់ខ្លួនរបស់ពុក ។ បងប្អូនជីដូនមួយរបស់ខ្ញុំបានប្រគល់ឯកសារពីរបីសន្លឹកដែលគាត់បានទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅចុងឆ្នាំ២០០៥នៅខេត្តស្វាយរៀងមកឲ្យខ្ញុំ ។ ឯកសារនោះគឺជាប្រវត្តិរូបអ្នកទោសរបស់ពុក ។ ខ្ញុំមានអារម្មណ៍តានតឹងនៅពេលដែលដឹងថាពុកបានស្លាប់នៅក្នុងគុកដ៏ សាហាវព្រៃផ្សៃនោះ ហើយភ្លាមៗនោះខ្ញុំក៏បានវិលត្រឡប់មកផ្ទះវិញដើម្បីប្រាប់ម៉ែពីដំណឹងដ៏អកុសល នេះ ។

ក្រោយពីសម្រួលអារម្មណ៍ ម្តាយខ្ញុំបានសម្រេចថាមកទស្សនាគុកទួលស្លែងនិងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីសួររករូបថតរបស់ពុក ។ ម៉ែស្ទើរតែដួលសន្លប់បាត់ស្មារតីនៅពេលដែលបានឃើញរូបថតពុកនិងឃើញទីកន្លែងដែលពុកត្រូវបានឃុំខ្លួន ។ ម៉ែមិននិយាយមួយម៉ាត់សោះក្រៅពីយំ ។ ខ្ញុំអាចដឹងពីការឈឺចាប់របស់ម៉ែហើយដោយសារតែភាពឈឺចាប់នេះហើយដែលខ្ញុំត្រូវតែធ្វើអ្វីម្យ៉ាង ។ ក្រោយពីទទួលបានការសម្របសម្រួលពីមជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំបានសម្រេចចិត្តដាក់ពាក្យស្នើសុំធ្វើជាជនរងគ្រោះជូនដល់សាលាក្តីខ្មែរក្រហម ។ ខ្ញុំជឿជាក់ថា ដំណើរការស្វែងរកយុត្តិធម៌អាចនឹងជួយព្យាបាលរបួសផ្លូវចិត្តរបស់ម៉ែបានមួយកម្រិត ។ ជាពិសេស ដំណើរការនេះនឹងផ្តល់កត្តិយសដល់ពុកនិងជនរងគ្រោះជាច្រើននាក់ទៀតសម្រាប់ការទទួលរងនូវអំពើសហាវឃោរឃៅនោះ ។ ក្រោយពីការទទួលបាននិទ្ទណ្ឌភាពជាច្រើនឆ្នាំវាដល់ពេលដែលមេដឹកនាំខ្មែរក្រហមត្រូវតែកាត់ទោសឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន ។

ទោះបីជាម៉ែមានភាពស្ទាក់ស្ទើរយ៉ាងណាក្តី ក៏ខ្ញុំបានជម្នះចូលរួមក្នុងដំណើរការរបស់តុលាការ ។ ម៉ែចង់កប់ទុកការចងចាំរបស់គាត់នៅក្នុងចិត្តដើម្បីរំសាយភាពឈឺចាប់របស់គាត់ ។ ប៉ុន្តែខ្ញុំជឿថាម៉ែគួរតែទម្លាយភាពស្ងប់ស្ងាត់របស់គាត់ ហើយប្រាប់រឿងរ៉ាវទាំងនោះទៅកាន់ពិភពលោក ។ ទីបំផុតខ្ញុំត្រូវបានចៅក្រមកោះហៅឲ្យផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការកាត់ទោស ឌុច ។ ខ្ញុំអាចនិយាយនូវអារម្មណ៍របស់ខ្ញុំ និងចោទសួរសំណួរទៅកាន់ជនជាប់ចោទ ។ នៅថ្ងៃនោះ ខ្ញុំមានជំនឿជឿជាក់ ពីព្រោះខ្ញុំជឿថាពុកនឹងផ្តល់កម្លាំងចិត្តឲ្យខ្ញុំ ។ មុនថ្ងៃឡើងធ្វើសក្ខីកម្មនៅតុលាការខ្ញុំបានយល់សប្តិឃើញពុក ហើយពុកបានសុំឲ្យខ្ញុំផ្ញើសម្លៀកបំពាក់ទៅឲ្យគាត់ ។ នេះគឺជាលើកទីមួយហើយដែលខ្ញុំបានយល់សប្តិ

ឃើញពុក ។

ឌុច បានទទួលស្គាល់ការស្លាប់របស់ពុកខ្ញុំ ប៉ុន្តែ ឌុច បានអះអាងថាការស្លាប់របស់ពុកមិនមែនជាបញ្ជាពីគណៈមជ្ឈិមទេ ។ ក្នុងអំឡុងដំណើរការនីតិវិធីនោះ ឌុច បានទទួលស្គាល់ឧក្រិដ្ឋកម្មរបស់ខ្លួន ហើយតែងតែសុំការអត់ឱនទោសពីជនរងគ្រោះ ។ ប៉ុន្តែខ្ញុំបានភ្ញាក់ផ្អើលចំពោះសេចក្តីថ្លែងចុងក្រោយ របស់ ឌុច ដែល ឌុច បានសុំឲ្យតុលាការដោះលែង ។ តាមពិត ឌុច មិនមែនជាមនុស្សដែលគួរឲ្យទុកចិត្តឡើយ ។ យ៉ាងណាមិញ តាមរយៈការចូលរួមក្នុងដំណើរការផ្លូវច្បាប់របស់តុលាការខ្ញុំបានទទួលការស្ងប់ចិត្តខ្លះ ។ ទីបំផុតម៉ែក៏បាននិយាយថា“ម៉ែមានអារម្មណ៍ថាធូរស្បើយបន្តិចនៅពេលដែលដឹងថាមានមនុស្សចង់ដឹងពីរឿងរ៉ាវរបស់យើង” ។ ប៉ុន្តែភាពឈឺចាប់ផ្លូវចិត្តរបស់ម៉ែនៅតែតាមយាយីគាត់ ហើយម៉ែនឹងមិនរួចផុតពីភាពឈឺចាប់នេះឡើយ ។

ចាប់តាំងពីយើងបានដឹងពីកាលបរិច្ឆេទនៃការស្លាប់របស់ពុកមក យើងតែងតែរៀបចំម្ហូបអាហារដើម្បីប្រគេនព្រះសង្ឃរាល់ថ្ងៃទី១៥ខែឧសភា ។ យើងសង្ឃឹមថាការវេរបុណ្យកុសលតាមបែបព្រះពុទ្ធសាសនានឹងជួយឲ្យពុកទៅកាន់សុគតិភព ។ ពុក ថ្ងៃនេះគឺជាថ្ងៃចុងបញ្ចប់នៃអង្គសវនាការរបស់ ឌុច ។ ខ្ញុំសង្ឃឹមថាពុកនឹងទទួលបានយុត្តិធម៌ ។ ខ្ញុំដឹងថា ឌុច សមនឹងទទួលបានជោគវាសនាអាក្រក់ជាងការដាក់ទោសនេះ ប៉ុន្តែយ៉ាងហោចណាស់ទណ្ឌកម្មដែល ឌុច បានទទួលនឹងជួយរារាំងសោកនាដកម្មនេះកុំឲ្យកើតឡើងម្តងទៀត ។ ម៉ែ និងខ្ញុំនឹងចងចាំពុកជារៀងរហូត, ពុក! សូមឲ្យវិញ្ញាណក្ខន្ធពុកទៅកាន់សុគតិភព ។

## អ្វីដែលខ្ញុំចង់បាន គឺយុត្តិធម៌សម្រាប់កូនខ្ញុំ

***ម៉ាន សូត***

ខ្ញុំឈ្មោះ ម៉ាន សូត អាយុ ៧៨ ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិរស្មីសាមគ្គីកណ្តាល ឃុំស្រឡៅ ស្រុកបារាយ ខេត្តកំពង់ធំ ។ ខ្ញុំជាកសិករម្នាក់ ។ “...ករណីច្បាស់លាស់ណាស់ដែលថា មេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺគេទេ មិនមែនខ្ញុំទេ ... អចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាគឺ ...បុគ្គលទាំងឡាយណាដែលមានសិទ្ធិសម្រេចកម្ទេចខ្មាំង ... នោះក៏គេ មិនមែនខ្ញុំ ...ខ្ញុំដែលរស់បានមានជីវិតរហូតថ្ងៃនេះ គឺដោយសារខ្ញុំគោរពគោលការណ៍នេះតាំងពីថ្ងៃ២០ កក្កដា ១៩៧១ យ៉ាងម៉ឺងម៉ាត់ ... គោលការណ៍របស់បក្សភារកិច្ចអ្វីដែលបក្សប្រគល់ឲ្យត្រូវតែធ្វើ អ្នកឯងមិនធ្វើមិនបានទេ ... ខ្ញុំម សារដែលខ្ញុំលើកឡើងគឺឧក្រិដ្ឋកម្មទាំងអស់ឧក្រិដ្ឋកម្មទាំងអស់នៅកម្ពុជាជាឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបងទី១ ប៉ុល ពត ជាលេខា បងទី២ នួន ជា ជាអនុលេខា បងទី៣ អ៊ុង ជឿន ហៅ ម៉ុក ជាអនុលេខាទីបី បន្ទាប់មកអនុលេខាទីពីរ ...” ។

ពាក្យពេចន៍របស់ ឌុច នៅក្នុងសេចក្តីថ្លែងការណ៍ចុងក្រោយរបស់ខ្លួនទៅកាន់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១១ ។ ធ្វើឲ្យខ្ញុំឈឺក្បាលឡើងខ្លាំង ។ ខ្ញុំមិនអាចទទួលយកបានទេ ចំពោះការទទូចសុំថាខ្លួនគ្មានកំហុសនោះ ។ ការលើកឡើងរបស់ ឌុច គឺដូចជាចង់បញ្ជាក់ថាខ្លួនគ្រាន់តែធ្វើតាមបញ្ជាគេតែប៉ុណ្ណោះ ។ ឌុច ចេះតែនិយាយអ្វីក៏ដោយឲ្យខ្លួនអាចរួចផុតពីការចោទប្រកាន់ ។ ចំពោះ ទស្សនរបស់ខ្ញុំ ឌុច គឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់និងដោយប្រយោលចំពោះការស្លាប់របស់ប្រជាជនជាច្រើននាក់នៅក្នុងប្រទេសកម្ពុជា ។ ឌុច គឺជាប្រធានមន្ទីរគុកទួលស្លែង (ស-២១) ហើយ នៅក្នុងចំណោមជនរងគ្រោះដែលស្លាប់ជាង ១៤០០០នាក់ នៅទីនោះ គឺមានម្នាក់ជាកូនរបស់ខ្ញុំ ។ កូនខ្ញុំខិតខំប្រឹងប្រែងបូជាលះបង់ដើម្បីការពារប្រទេសជាតិតែហេតុអ្វីបានជាកូនខ្ញុំត្រូវបានចាប់ខ្លួននិងសម្លាប់ដោយអយុត្តិធម៌បែបនេះ?



ម៉ាន សូត

តើនរណាជាអ្នកទទួលខុសត្រូវ? ប៉ុល ពត? តាម៉ុក? ឌុច?

កូនច្បងរបស់ខ្ញុំឈ្មោះ ម៉ាន ស៊ីម ត្រូវបានសម្លាប់នៅទួលស្លែងនៅក្នុងឆ្នាំ១៩៧៦ ។ កូនស៊ីម គឺជាកូនកត្តញ្ញូម្នាក់និងចេះជួយយកអាសារគេណាស់ ។ ពេលអាយុបាន១៥ឆ្នាំ កូនស៊ីមត្រូវបានគេជ្រើសតាំងឲ្យចូលរួមក្នុងក្រុមសម្តែងសិល្បៈក្នុងភូមិអស់រយៈពេលមួយឆ្នាំ ។ បន្ទាប់មកប្រហែលជាក្នុងឆ្នាំ១៩៧៣ កូនស៊ីមត្រូវបានមេឃុំឈ្មោះ រឿង និង ហំ ណែនាំឲ្យចូលធ្វើទ័ពខ្មែរក្រហម ។ ក្នុងនាមជាឪពុកម្តាយគេយើងពិតជាមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការសម្រេចចិត្តដ៏គ្រោះថ្នាក់នេះ ប៉ុន្តែ យើងមិនអាចធ្វើអ្វីបានទាំងអស់ក្រៅពីខិតខំធ្វើការយ៉ាងលំបាកវេទនាដើម្បីផ្គត់ផ្គង់ខ្លួនឯង ។ ពេលនោះទៀតគឺយើងកំពុងត្រូវបានបង្ខំឲ្យរត់គេចពីការទម្លាក់គ្រាប់បែកក្នុងភូមិ ។

កូនស៊ីមបានមកលេងផ្ទះប៉ុន្មានដងដែរ ហើយបានប្រាប់ថាវាមិនអាចអត់ទ្រាំទៅនឹងការស៊ីអត់ស៊ីឃ្លាននិងការរស់នៅយ៉ាងវេទនានៅសមភូមិបានទេ ។ ប្រពន្ធរបស់ខ្ញុំព្រួយដំណឹងបែបនេះហើយគឺគិតតែយំរហូត ។ តែទោះបីជាមិនសប្បាយចិត្តយ៉ាងនេះក្តីកូនស៊ីមនៅតែបន្តធ្វើទ័ពហ្នឹងរហូតនៅខេត្តកំពង់ធំ ។ ប៉ុន្មានថ្ងៃបន្ទាប់ពីថ្ងៃរំដោះទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ កូនស៊ីមបានមកលេងផ្ទះម្តងទៀត ។ កាលនោះ ខ្ញុំគ្រុនក្តៅខ្លាំងហើយ កូនស៊ីមហ្នឹងបានយកថ្នាំមួយកញ្ចប់ធំមកជាមួយ ។ កូនស៊ីមបានចាក់ថ្នាំឲ្យខ្ញុំមួយម្ជុលហើយខ្ញុំក៏ជាសះស្បើយ ។ ពួកកម្មាភិបាលខ្មែរក្រហមផ្សេងទៀតតែងតែហៅកូនស៊ីមថា ពេទ្យ រៀម ព្រោះកូនខ្ញុំចេះព្យាបាលជំងឺដោយប្រើថ្នាំ ។ ពេលខ្លះអ្នកភូមិៗតែងតែហៅកូនខ្ញុំហ្នឹងឲ្យជួយមើលជំងឺដែរ ។ នៅផ្ទះបានតែប៉ុន្មានថ្ងៃ កូនស៊ីមត្រូវដល់ពេលត្រឡប់ទៅភ្នំពេញវិញ ។ កូនស៊ីម ធ្វើទ័ពនៅកងពល៣១០ ។ ប្រហែលប៉ុន្មានខែក្រោយមក កូនស៊ីមបានសរសេរសំបុត្រផ្តាំផ្ញើឲ្យខ្ញុំទៅលេងនៅភ្នំពេញ ។ បន្ទាប់មក ខ្ញុំបានទៅស្នើសុំការអនុញ្ញាតពីប្រធានកងរបស់ខ្ញុំដើម្បីទៅភ្នំពេញ ។ ប្រធានកងរបស់ខ្ញុំបានចេញលិខិតធ្វើដំណើរឲ្យខ្ញុំ ហើយខ្ញុំក៏ជិះកង់ទៅជាមួយក្មួយរបស់ខ្ញុំឈ្មោះ ហឺន ដែលធ្វើទ័ពដែរ ។ យើងធ្វើដំណើរអស់ជិតបីថ្ងៃទើបទៅដល់ទីក្រុងភ្នំពេញ ។ នៅតាមផ្លូវខ្ញុំឃើញមានទាហានតែមិនសូវមានអ្នកភូមិដើរហើរទេ ។ ខ្ញុំជិះសាឡាងនៅព្រែកក្តាម ។ ពេលនោះគេអត់មានគិតលុយកាក់អីទេ ព្រោះជំនាន់នោះមិនមានការចាយវាយរូបិយវត្ថុអ្វីនោះទេ ។ ខ្ញុំសំណាក់នៅប្រាំងចំរេះមួយយប់ទៀតមុនពេលធ្វើដំណើរមកកាន់កន្លែងដែលកូនខ្ញុំនៅ ។ ពេលនោះ ខ្ញុំមានការភ្ញាក់ផ្អើល យ៉ាងខ្លាំងចំពោះភាពស្ងាត់ជ្រងំនៅទីក្រុងភ្នំពេញ ។ ផ្ទះស្ទើតែទាំងអស់គឺទទេ ស្អាតគ្មានមនុស្សរស់នៅទេ ។ មានមនុស្សដើរតាមផ្លូវដែរតែតិចតួចណាស់ ។ ខ្ញុំឃើញមានតែឡានដឹកទ័ពជាច្រើន ។ ទីក្រុងភ្នំពេញមើលទៅដូចជាកំពុងលង់លក់អ៊ីចឹង ។ នៅជិតគល់ស្ពានជ្រោយចង្វារដែលបាក់នោះមានស្មៅដុះឡើងពេញ ។ បន្ទាប់ពីស្នាក់នៅជាមួយកូនស៊ីមបានមួយថ្ងៃ ខ្ញុំក៏ធ្វើដំណើរត្រឡប់មកភូមិវិញ ។ ពេលរៀបចេញមកកូនខ្ញុំបានឲ្យឆ្នាំងដាំបាយធំមួយទុកឲ្យខ្ញុំប្រើសព្វថ្ងៃនេះ (ខ្ញុំក៏នៅប្រើឆ្នាំងហ្នឹងដែរ) ។ នៅក្នុងភូមិ ខ្ញុំត្រូវបានចាត់ចែងឲ្យធ្វើការខាងក្រុមភ្ជួររាស់និងលើកទំនប់ ។ ប្រពន្ធខ្ញុំវិញនៅតែធ្វើនៅកងស្ទូងស្រូវដដែរ ។ ប្តីប្រពន្ធយើងធ្វើការបែកគ្នា ហើយមិនមានពេលបានជួបគ្នាញឹកញាប់ទេ ។ ខ្ញុំពេលនោះស្គមស្គាំងណាស់ដោយសារតែអាហារដែលខ្ញុំបានហូបនោះគឺមានតែទឹកបបរតែប៉ុណ្ណោះ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ ក្មួយខ្ញុំឈ្មោះ រឿន បានមកប្រាប់ខ្ញុំថា កូនស៊ីម ត្រូវបានចាប់ខ្លួនដោយសារតែរត់គេចពីកន្លែងធ្វើការ ។ មុនពេលកើតហេតុនេះ រឿន និយាយថា កូនស៊ីម ត្រូវបានគេផ្លាស់ពីកងពល៣១០ឲ្យទៅធ្វើស្រែនៅទំនប់កប់ស្រូវ ។ កូនស៊ីមនិងគ្នីគ្នាពីរនាក់ទៀតបានគេចមកលេងគ្រួសារនៅខេត្តកំពង់ធំ ។ ប៉ុន្តែនៅពេលដែលមកដល់តាំងគោក អ្នកទាំងបីនាក់ត្រូវបានកម្មាភិបាល នៅទីនោះឃាត់ឲ្យនៅហូបបាយនៅទីនោះ ។ មិនយូរប៉ុន្មាន គេក៏ដកហូតកាំភ្លើងពីអ្នកទាំងបី ហើយត្រូវបានកម្មាភិបាលនៅទីនោះបង្ខំឲ្យជួយនៅកិនស្រូវ ។ ពីរថ្ងៃក្រោយមកមានឡានមួយមកដឹក កូនស៊ីម ត្រឡប់ទៅភ្នំពេញវិញ ។ រឿន និយាយថា កូនស៊ីមហ្នឹងដឹងខ្លួនថានឹងមិនមានវាសនារស់មកវិញទេ ដូចនេះកូនស៊ីម ក៏បានហុចនាឡិកាដៃនិងថ្នាំមួយចំនួនដើម្បីទុកឲ្យគេផ្ញើមកឲ្យខ្ញុំ ។ ប៉ុន្តែ ពេលនោះគ្មានរបស់អ្វីផ្ញើមកឲ្យខ្ញុំទេ ក្រៅពីដំណឹងចាប់ខ្លួនរបស់កូនខ្ញុំ ។ ប៉ុន្មានអាទិត្យក្រោយមក ខ្ញុំក៏បានស្នើសុំការអនុញ្ញាតពីប្រធានកងដើម្បីទៅមើលកូននៅភ្នំពេញ ។ តែប្រធានកងខ្ញុំក៏ទៅប្រាប់មេឃុំឈ្មោះ ចាន់ ហើយ ចាន់ ក៏មក

ជួបខ្ញុំហើយ និយាយថា "កុំទៅរវល់នឹងរឿងគេគិតតែពីខ្លួនឯងទៅ" ។ ពាក្យសម្ដីដូច្នេះធ្វើឲ្យខ្ញុំដឹងខ្លួនថាខ្ញុំពិតជាមិនអាចទៅលេងកូនបានទេ ហើយច្បាស់ណាស់ថាមានរឿងអ្វីអាក្រក់កើតឡើងចំពោះកូនខ្ញុំហើយ ។ ទោះបីជាខ្ញុំមានអារម្មណ៍ទុក្ខព្រួយយ៉ាងណាក៏ ខ្ញុំមិនហ៊ានទៅសួរនាំម្ដងទៀតដែរ មានតែខិតខំធ្វើពលកម្មតែប៉ុណ្ណោះ ។ នៅពេលដែលប្រពន្ធរបស់ខ្ញុំបានលឺដំណឹងនេះ គាត់ក៏ចាប់ផ្ដើមព្រួយរហូតដល់ឈឺ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងបញ្ចេញអារម្មណ៍អាណិតអាសូរចំពោះការបាត់បង់នរណាម្នាក់នោះទេ ទោះបីជាកូនរបស់យើងក្ដី ។ បើមិនអីចឹងទេ យើងក៏ត្រូវទទួលដោគវាសនាដូចគ្នាអីចឹងដែរ ។ ទោះជាយ៉ាងនេះក្ដី ប្រពន្ធខ្ញុំនៅតែលួចយំ ។ កម្មាភិបាលខ្មែរក្រហមធ្វើបាបប្រជាជនដូចសត្វធាតុអីចឹង ។ ពេលនោះប្រពន្ធខ្ញុំកំពុងពរពោះ៨ខែហើយ តែត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំងនៅវាលស្រែដោយគ្មានអាហារហូបចុកគ្រប់គ្រាន់ ។

តាំងពីពេលនោះមក ខ្ញុំមិនដែលបានឮដំណឹងអ្វីពីកូនស៊ីមម្ដងទៀតនោះទេ ។ ទោះជាយ៉ាងនេះក្ដី ខ្ញុំនៅតែមានចិត្តចង់ទៅស្វែងរកកូនស៊ីមទៀត ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅខ្ញុំបានឮដំណឹងពីមិត្តភ័ក្ដិរបស់ហឹន ថាកូនស៊ីមរបស់ខ្ញុំដែលគេតែងតែហៅ ថា ពេទ្យរៀម នោះត្រូវបានចាប់ដាក់គុកតាំងពីពាក់កណ្ដាលឆ្នាំ១៩៧៦ពេលដែលគេចាប់ខ្លួនដំបូងមកម្ល៉េះ ។ ចាប់ពីពេលនោះមកខ្ញុំលែងមានសង្ឃឹមថាកូនស៊ីមនៅរស់ទៀតហើយ ។ ខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េចទេ ក្រោពីនៅស្ងៀមហើយព្យាយាមរស់តស៊ូក្នុងជីវិតជាមួយនឹងការចងចាំដ៏គួរឲ្យឈឺចាប់ទាំងអស់នេះ ។ ចំណែកឯប្រពន្ធខ្ញុំវិញ សុខភាពក៏ចាប់ផ្ដើមធ្លាក់ទន់ខ្សោយពីពេលនោះមក ។

នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅដល់ភូមិរបស់ខ្ញុំ ហើយបានបង្ហាញប្រពន្ធខ្ញុំនូវក្រដាសប្រវត្តិរូបអ្នកទោសមួយសន្លឹកដែលជារបស់កូនខ្ញុំ ។ ក្នុងក្រដាសថតចម្លងនោះមានព័ត៌មានផ្ទាល់ខ្លួននិងរូបថតរបស់កូនខ្ញុំដែលបញ្ជាក់យ៉ាងច្បាស់ថា នេះហើយជាកូនរបស់ខ្ញុំ ។ ប្រពន្ធខ្ញុំឃើញបែបនេះគិតតែពីយំយ៉ាងខ្លាំង ។ អស់ពេលជាងម្ភៃឆ្នាំហើយ ទើបយើងបានទទួលដំណឹងយ៉ាងច្បាស់ ប្រាកដបែបនេះថា កូនខ្ញុំ ម៉ាន ស៊ីម ត្រូវបានយកទៅសម្លាប់នៅគុកទួលស្លែង ។ ខ្ញុំនិយាយមិនចេញនោះទេ ។ នៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៨ ខ្ញុំបានដាក់ពាក្យបណ្ដឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ការប្រកាសសាលក្រមនៅថ្ងៃទី ២៦ កក្កដា ឆ្នាំ ២០១០ នោះគឺជាថ្ងៃដែលមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំ ។ ខ្ញុំត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីជាផ្លូវការនៅចំពោះមុខតុលាការ ហើយឌុចក៏បានកាត់ទោសឲ្យជាប់គុក៣៥ឆ្នាំដែរ ។ ប៉ុន្តែ ឌុច នៅតែបដិសេធចំពោះការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជាប្រធានមន្ទីរគុកទួលស្លែងទៀត ។

នៅក្នុងសវនាកាតុលាការកំពូល ឌុច និងមេធាវីការពារក្ដីបានលើកឡើងថា ឌុច គឺគ្មានជម្រើសនោះទេ ក្រៅពីធ្វើតាមការបញ្ជាគ្រប់ពេលវេលា ។ ឌុច ក៏បានអះអាងថា ខ្លួនក៏មិនមែនជាអ្នកដឹកនាំខ្ពស់បំផុតដែរ ដែលដូចនេះហើយមិនគួរត្រូវបានយកមកកាត់ទោសនោះទេ ។ ខ្ញុំពិតជាតូចចិត្តណាស់ នៅពេលស្ដាប់ពាក្យសម្ដីបែបនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ កូនខ្ញុំត្រូវបានយកទៅសម្លាប់បាត់ទៅហើយ គ្មានមធ្យោបាយណាធ្វើឲ្យកូនខ្ញុំរស់ឡើងវិញបាននោះទេ ។ ខ្ញុំក៏ដឹងដែរថា វាមិនអាចទៅរួចទេក្នុងការទទួលបានយុត្តិធម៌ពេញលេញមួយនោះ ។ ប៉ុន្តែយ៉ាងហោចណាស់តាមរយៈតុលាការនេះនិងតាមផ្លូវច្បាប់

បែបនេះអាចធ្វើឲ្យខ្ញុំមានអារម្មណ៍ស្ងប់ចិត្តបាន ។ រីឯផ្ទាល់ខ្លួនខ្ញុំវិញបន្ទាប់ពីដឹងលឺរឿងរ៉ាវនៃការស្លាប់របស់កូនខ្ញុំមក ខ្ញុំតែងតែចង់ធ្វើបុណ្យធ្វើទានខទ្ធិសកុសលឲ្យកូនដើម្បីឲ្យកូនបានទេកាន់សុគតិភព និងបានចាប់កំណើតថ្មី ។ ប៉ុន្តែ ដោយសារជីវភាពរស់នៅរបស់យើងជួបការលំបាកបំណាងប្រាថ្នានេះ មិនបានសម្រេចតាមចិត្តនោះទេ រហូតដល់ខែកុម្ភៈ ឆ្នាំ ២០១១ ទើបយើងមានថវិកាបន្តិចបន្តួចនាំគ្នាធ្វើបុណ្យឲ្យកូន ។ ខ្ញុំបានខិតខំសន្សំលុយកាក់ទាំងនេះអស់ជិតដប់ឆ្នាំហើយបានលក់គោខ្លះទៀតដើម្បីយកលុយមកធ្វើបុណ្យ ។ ពិធីបុណ្យនេះបានធ្វើឲ្យខ្ញុំមានអារម្មណ៍ជ្រះថ្លាស្ងប់ចិត្តសប្បាយរីករាយនិងមានក្ដីសង្ឃឹមឡើងវិញ ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ គឺជាពេលវេលាដ៏សំខាន់មួយទៀតនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នេះរបស់ខ្ញុំ ។ នោះជាពេលដែលខ្ញុំបានរកឃើញរូបថតរបស់កូនខ្ញុំនៅក្នុងបណ្ណសារ

របស់សារៈមន្ទីរទួលស្លែង ។ បន្ទាប់ពីទទួលដំណឹងថាកូនខ្ញុំស្លាប់នៅទួលស្លែង ខ្ញុំបានមកទស្សនាសារៈមន្ទីរនេះជាច្រើនដងច្រើនសារតាមតែអាចធ្វើទៅបានដោយមានបំណងតែមួយគត់គឺស្វែងរករូបថតកូន ។ ឥឡូវខ្ញុំបានសម្រេចបំណងនេះហើយ ហើយវាធ្វើឲ្យខ្ញុំមានអារម្មណ៍ធូរស្បើយយ៉ាងខ្លាំង ។ រូបថតរបស់កូនស៊ីមនៅតែឆ្លុះបញ្ចាំងពីការចងចាំមួយដ៏ល្អមួយរបស់រឿងរ៉ាវគ្រួសារខ្ញុំទោះបីជាការចងចាំនោះមានការឈឺចាប់យ៉ាងណាក្តី ។ យ៉ាងហោចណាស់ ការចូលរួមរបស់ខ្ញុំនៅក្នុងដំណើរការរបស់តុលាការនេះបានធ្វើឲ្យខ្ញុំអាចក្រោកឈរឡើងប្រឈមមុខដោយផ្ទាល់ទៅនឹងជំពូកដ៏ខ្មៅងងឹតមួយនៅក្នុងប្រវត្តិសាស្ត្រគ្រួសារខ្ញុំ ។ អ្វីដែលខ្ញុំចង់បានពីតុលាការ គឺមានតែយុត្តិធម៌តែប៉ុណ្ណោះ ។

## ឪពុករបស់ខ្ញុំស្លាប់នៅគុកទួលស្លែង

*ហេង នុិចហុង*



ហេង នុិចហុង

តើអ្នកនឹងមានអារម្មណ៍បែបណានៅពេលដែលឪពុកជាទីស្រឡាញ់របស់អ្នកត្រូវបានបាត់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ ហើយក្រោយមកទើបអ្នកដឹងថាគាត់ត្រូវបានខ្មែរក្រហមដាក់ឃុំឃាំង ធ្វើទារុណកម្មយ៉ាងឃោរឃៅ និងត្រូវបានសម្លាប់នៅមន្ទីរ ស-២១? រឿងរ៉ាវនេះបានកើតឡើងមកលើរូបខ្ញុំ ហើយខ្ញុំមិនអាចនឹងយកពាក្យពេចន៍អ្វីមកធ្វើការប្រៀបធៀបឲ្យបានត្រឹមត្រូវពីអារម្មណ៍របស់ខ្ញុំបានឡើយ ។

លោកឪពុករបស់ខ្ញុំឈ្មោះ សុខ ហេង ។ គាត់គឺជាបុរសសុភាពរាបសារមួយរូបដែលខិតខំប្រឹងប្រែងធ្វើការងារចេះជួយយកអាសារអ្នកដទៃនិងជាមនុស្សម្នាក់ដែលគួរឲ្យស្រឡាញ់រាប់អាន ។ គាត់ធ្លាប់ រស់នៅឃុំព្រែកកុយ ស្រុកស្អាង ខេត្តកណ្តាល ។ ឪពុកខ្ញុំធ្វើស្រែចម្ការរកស៊ីលក់ដូរបន្តិចបន្តួចនិងជាចុងភៅដ៏ចំណានមួយរូប ។ គាត់បានទិញទំនិញមកពីផ្សារដើម្បីឲ្យម្តាយរបស់ខ្ញុំលក់ដូរនៅផ្ទះដងនឹងមានពេលវេលាគ្រប់គ្រាន់មើលថែកូនចៅនៅផ្ទះផង ។ ទោះបីជាឪពុកខ្ញុំមានពេលខ្លះគាត់មានការមមារញឹកនិងនឿយហត់ពីការងារយ៉ាងណាក៏ដោយច ក៏ឪពុកខ្ញុំតែងតែឆ្លៀតពេលមើលថែកូនៗរបស់គាត់ដែរ ។ ជាពិសេសនៅពេលដែលកូនៗរបស់គាត់ឈឺ ។ ខ្ញុំនៅតែចងចាំមិនភ្លេចនូវរឿងរ៉ាវទាំងឡាយនៅពេលដែលឪពុករបស់ខ្ញុំអង្គុយនៅក្បែរកូនៗរបស់គាត់នៅពេលកណ្តាលអាធ្រាត្រមើលថែយើង ដើម្បីធានាថាកូនរបស់គាត់នឹងឆាប់ជាសះស្បើយពីជំងឺ ។ នៅពេលនោះពួកយើងពិតជាមានសុភមង្គលពីព្រោះតែយើងមានឪពុកម្នាក់ដែលមានការទទួលខុសត្រូវនិងជាមេគ្រួសារដ៏ល្អម្នាក់ ។

ជីវិតរបស់ពួកយើងបានប្រែប្រួលទាំងស្រុងនៅពេលដែលឪពុកជាទីស្រឡាញ់របស់ខ្ញុំត្រូវបានបង្ខំឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាចុងភៅនៅទួលក្រសាំងហើយ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកោះខែល ។ ខ្ញុំតែងតែចង់មករួមរស់ជុំគ្នាជាមួយឪពុកម្តាយនិងបងប្អូនរបស់ខ្ញុំវិញ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាត ។ នៅឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានមកលេងផ្ទះពីរដង ហើយចាប់តាំងពីពេលនោះមកគាត់ក៏បានបាត់ខ្លួនរហូត ។ នៅពេលនោះ ធ្លាប់មានគេមកប្រាប់ម្តាយខ្ញុំថាឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់ទៅដាក់ឃុំឃាំងនៅកោះករ ។ មិនយូរប៉ុន្មាន ម្តាយរបស់ខ្ញុំក៏បានស្លាប់បាត់បង់ជីវិតដោយសារតែគាត់មិនអាចទ្រាំទ្រនឹងការងារលំបាក ហើយនឹងអារម្មណ៍ដ៏ឈឺចាប់ បន្ទាប់ពីការបាត់ខ្លួនរបស់ឪពុកខ្ញុំ ។

ស្ថិតនៅក្រោមការដឹកនាំរបស់ខ្មែរក្រហម ខ្ញុំត្រូវបានបង្ខំឲ្យធ្វើការលើកទំនប់និងរែកដីរៀងរាល់ថ្ងៃ ។ ការងារទាំងនោះលំបាកនិងធ្វើឲ្យខ្ញុំហេវហត់អស់កម្លាំង ។ គ្រួសាររបស់ខ្ញុំត្រូវបានបំបែកចេញពីគ្នា ហើយខ្ញុំមានអារម្មណ៍កណ្តោចកណ្តែងជាខ្លាំង

ដែលធ្វើឲ្យខ្ញុំគ្មានស្មារតីប្រឹងប្រែងតស៊ូរស់តទៅទៀត ។ ខ្ញុំមិនដែលត្រូវបានអនុញ្ញាតឲ្យទៅលេងឪពុកដែលខ្ញុំតែងតែនឹកនោះឡើយ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរំលំ អ្នកជិតខាងផ្ទះរបស់ខ្ញុំបានប្រាប់ខ្ញុំថាធ្លាប់បានឃើញរូបថតឪពុករបស់ខ្ញុំនៅទួលស្លែង ។ នៅពេលនោះខ្ញុំចង់ធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញខ្លាំងណាស់ ប៉ុន្តែដោយសារតែជីវភាពរបស់ខ្ញុំមានភាពខ្វះខាតខ្សោយខ្ញុំមិនមានលុយគ្រប់គ្រាន់សម្រាប់ការធ្វើដំណើរនោះទេ ។ ប៉ុន្តែ បងស្រីរបស់ខ្ញុំបានជិះកង់របស់គាត់ធ្វើដំណើរទៅកាន់គុកទួលស្លែងហើយបានឃើញរូបថតឪពុករបស់យើង ។ គាត់ត្រូវបានអ្នកនៅទីនោះប្រាប់ថារាល់រូបថតទាំងអស់ដែលដាក់តាំងបង្ហាញនៅទីនោះគឺសុទ្ធតែស្លាប់ទាំងអស់ ។ ព័ត៌មានអំពីការបាត់បង់នេះបានធ្វើឲ្យខ្ញុំមានអារម្មណ៍រន្ធត់ជាខ្លាំង ហើយខ្ញុំបានចាប់ផ្ដើមគិតថា ចាប់ពីពេលនេះតទៅខ្ញុំនិងបងស្រីរបស់ខ្ញុំត្រូវតែប្រឹងប្រែងរស់ដោយខ្លួនឯង ពីព្រោះឪពុកម្ដាយរបស់ពួកយើងបានក្លាយទៅជាជនរងគ្រោះនៃរបបខ្មែរក្រហមបាត់ទៅហើយ ។

នៅឆ្នាំ២០០៣បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកជួបខ្ញុំ ហើយបានហុចឲ្យខ្ញុំនូវប្រវត្តិរូបរបស់ឪពុករបស់ខ្ញុំដែលប្រវត្តិរូបនោះមាននៅក្នុងបណ្ណសាររបស់ទួលស្លែង ។ វាគឺជាលើកទីមួយដែលមានមនុស្សមកសួរខ្ញុំអំពីការឈឺចាប់ដែលខ្ញុំបានជួបប្រទះកាលពីរបបខ្មែរក្រហម ។ នៅឆ្នាំ២០០៨បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកជួបខ្ញុំម្ដងទៀត ហើយបានពន្យល់ខ្ញុំអំពីសិទ្ធិដែលខ្ញុំអាចដាក់ពាក្យបណ្ដឹងតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១បាន ។ ខ្ញុំក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងដោយសារតែខ្ញុំចង់ស្វែងរកយុត្តិធម៌ជូនឪពុករបស់ខ្ញុំនិងខ្ញុំចង់ចូលរួមទប់ស្កាត់កុំឲ្យរបបដ៏ឃោរឃៅនេះកើតឡើងម្ដងទៀត ។ ខ្ញុំបានយល់ដឹងកាន់តែច្រើនជាងមុនអំពីប្រតិបត្តិការនៅទួលស្លែងពីមេធាវីរបស់ខ្ញុំ ហើយនឹងទទួលបានព័ត៌មានពីកាសែតក្នុងស្រុក ។ ខ្ញុំប្រាកដថាឪពុករបស់ខ្ញុំមិនមែនជាភ្នាក់ងាររបស់សេ.អ៊ី.អា កា.ហ្ស.បេ


I08812
( 06បប... )
76
លេខរៀង :
មកពី :
ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង
១- ឈ្មោះដើម
- ឈ្មោះថ្មី
២- អាយុ ៥១ ឆ្នាំ ជនជាតិ ខ្មែរ ភេទ ប្រុស
៣- ទីលំនៅកំណើតកើតនៅភូមិ
ឃុំ ស្រុក ៧០ ខេត្ត កណ្ដាល
៤- ក្រសួងមុខងារទី មុនថ្ងៃរំដោះភ្នំពេញ ( ក្នុងឆ្នាំ ១៩៧៥ )
៥- ក្រសួងមុខងារទី បច្ចុប្បន្ន
៦- ឪពុកឈ្មោះ ម្ដាយឈ្មោះ
៧- ប្រពន្ធ ឬ ប្ដី ឈ្មោះដើម ឈ្មោះថ្មី
៨- ទីលំនៅកំណើតកើតនៅភូមិ ឃុំ
ស្រុក ៧០ ខេត្ត កណ្ដាល ។
៩- បច្ចុប្បន្ន នៅ
១០- មានកូនប្រុសចំនួន នាក់ កូនស្រី ៤ នាក់
១១- ទីកន្លែងចាប់ខ្លួន
១២- ចាប់ខ្លួន ថ្ងៃទី ៧ ខែ ៣ ឆ្នាំ ១៩៧ ។ ផ្ទះ បន្ទប់ធំ តូច

វៀតណាមអតីតមន្ត្រីរបស់ លន់ នល់ ទាហាន ឬសត្រូវរបស់អង្គការនោះទេ ។ គាត់មិនដែលនិយាយរិះគន់និងពាក់ព័ន្ធនៅក្នុងរឿងនយោបាយណាមួយនោះទេ ។ គាត់គ្រាន់តែជាឪពុកដ៏ស្លូតត្រង់មួយរូបជាអ្នកលក់ដូរតូចតាចមួយរូប និងជាចុងភៅមួយរូបប៉ុណ្ណោះ ។ ប៉ុន្តែខ្មែរក្រហមបែរជាបំបែកគាត់ចេញពីគ្រួសាររបស់យើង ។

បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានដួលរំលំ ខ្ញុំនិងបងប្អូនរបស់ខ្ញុំខិតខំប្រឹងប្រែងកសាងគ្រួសារឡើងវិញ ។ ខ្ញុំតែងតែច្រណែនអ្នកដទៃដែលមានឪពុកម្ដាយនៅរស់មកដល់សព្វថ្ងៃ ។ ការច្រណែននេះក៏ព្រោះ តែវាធ្វើឲ្យខ្ញុំនឹកឃើញពីឪពុកម្ដាយដែលខ្ញុំបានបាត់បង់ ។ ខ្ញុំតែងតែគិតថា ជីវភាពគ្រួសាររបស់ខ្ញុំនឹងល្អប្រសើរជាងនេះប្រសិនបើឪពុករបស់ខ្ញុំនៅរស់ ។ ខ្ញុំចង់ឃើញ ឌុច ទទួលបានការដាក់គុកអស់មួយជីវិតដើម្បីជាយុត្តិធម៌មួយសម្រាប់ការស្លាប់របស់ឪពុកខ្ញុំ ហើយនឹងអ្នកទោសដទៃទៀតដែលត្រូវបានសម្លាប់នៅក្រោមការគ្រប់គ្រងរបស់គាត់ ។

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**

ខាងក្រោមនេះជាសេចក្ដីសង្ខេបនៃសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្ដីសង្ខេបនៃសាលក្រម

**សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ ករណី កាំង ហ្គេកអ៊ាវ *ហៅ* ឌុច**
**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០**

### ក. <u>សេចក្ដីផ្ដើម</u>

១. ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបផ្នែកសំអាងហេតុនៃសាលក្រម។ សំអាងហេតុពិស្ដារនៃបទល្មើសមាននៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ ដែលនឹងត្រូវផ្សព្វផ្សាយជាភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស បន្ទាប់ពីសវនាការប្រកាសសាលក្រមនេះ។

២. ជាបឋម អង្គជំនុំជម្រះសូមថ្លែងអំណរគុណដល់ភាគី អ្នកបកប្រែភាសា មន្ត្រីតុលាការ បុគ្គលិកប្រតិចារឹក បុគ្គលិករដ្ឋបាលរបស់ អ.វ.ត.ក បុគ្គលិកសន្តិសុខ បុគ្គលិកផ្នែកសោតទស្សន៍ បុគ្គលិករបស់អង្គជំនុំជម្រះសាលាដំបូង និងបុគ្គលិកផ្នែកផ្សេងៗទៀត ដែលបានចូលរួមចំណែកធ្វើឱ្យកិច្ចដំណើរការសវនាការនេះ ប្រព្រឹត្តទៅបានយ៉ាងរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

៣. កិច្ចដំណើរការសវនាការរឿងក្ដីនេះ បានចាប់ផ្ដើមនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងបានបញ្ចប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងអំឡុងសវនាការលើអង្គសេចក្ដីរយៈពេល ៧២ថ្ងៃ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មរបស់សាក្សីចំនួន ២៤នាក់ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២២ នាក់ និងអ្នកជំនាញចំនួន ០៩ នាក់។ ឯកសារប្រហែល ១.០០០ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាកម្មវត្ថុនៃការពិនិត្យ។ រយៈពេលនៃកិច្ចដំណើរការ

១

នីតិវិធី និងទំហំនៃសាលក្រម បានឆ្លុះបញ្ចាំងនូវការជំនុំជម្រះជាប្រវត្តិសាស្ត្រ ដែលជាលើកដំបូងនៅចំពោះមុខ អ.វ.ត.ក ផង និងវិសាលភាពនៃការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាប់ចោទផង។

៤. ជនជាប់ចោទ ត្រូវបានចោទប្រកាន់តាមទម្រង់ទាំងអស់នៃការទទួលខុសត្រូវ ដូចដែលមានចែងនៅក្នុងមាត្រា២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក ចំពោះតួនាទីរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលគាត់បានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅមន្ទីរសន្តិសុខស២១។ ជាពិសេស ជនជាប់ចោទត្រូវបានចោទ-ប្រកាន់ថាបានបំពេញការងារជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ និងបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានបទល្មើសការធ្វើមនុស្ស-ឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ គាត់ក៏ត្រូវបានចោទប្រកាន់ផងដែរ ចំពោះការបំពារ-បំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែលមានបទល្មើសការធ្វើ-មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ព្រមទាំងការធ្វើមនុស្សឃាតដោយគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើក្រមព្រហ្ម-ទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

៥. នៅក្នុងសេចក្តីសម្រេចដាច់ដោយឡែករបស់ខ្លួនដែលជា “សេចក្តីសម្រេចស្តីអំពីអញ្ញត្រ-កម្មទាក់ទងនឹងចិររយៈនៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី” ដែលត្រូវចេញនៅថ្ងៃនេះផងដែរ អង្គជំនុំជម្រះបង្ហាញថា អង្គជំនុំជម្រះមិនបានពិនិត្យអំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ចំពោះបទចោទនៃការធ្វើមនុស្ស-ឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលអាចផ្តន្ទាទោសបាននៅចំពោះមុខ អ.វ.ត.ក អនុលោមតាមមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ទេ។ ដូចមានការលើកឡើងនៅក្នុងសេចក្តីសម្រេច គឺចៅក្រមនៃ

២

អង្គជំនុំជម្រះបានមានមតិយោបល់ដាច់ដោយឡែកពីគ្នា អំពីបញ្ហាថាតើមានការទទួល-ខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានផុតរលត់ ឬមិនទាន់ផុតរលត់ថិរវេលានៃអាជ្ញាយុកាល នៅមុនពេលមានការស៊ើបអង្កេតរបស់ អ.វ.ត.ក ទៅលើជនជាប់ចោទដែរ ឬទេ ។ ការមិនមានសំឡេងភាគច្រើននៃចៅក្រមប្អូនរូបយ៉ាងតិចគាំទ្រចំពោះបញ្ហានេះ បានបង្កើតជាឧបសគ្គក្នុងការបន្តការវិនិច្ឆ័យលើជនជាប់ចោទចំពោះបទឧក្រិដ្ឋជាតិ នៅចំពោះមុខអង្គ-ជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ។

៦. នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះបានផ្តល់នូវសំអាងហេតុពិស្តារគាំទ្រដល់ការអនុវត្តយុត្តាធិការរបស់អង្គជំនុំជម្រះលើជនជាប់ចោទ។ អង្គជំនុំជម្រះយល់ស្របជាមួយ-នឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតដែលថា កាំង ហ្កេកអ៊ាវ *ហៅ* ឌុច គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលផ្សេងទៀតដែលត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុស-ត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

៧. ច្បាប់ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក មិនដូចក្របខណ្ឌគតិយុត្តនៃតុលាការអន្តរជាតិដទៃទៀតឡើយ គឺមិនបានចែងអំពីនីតិវិធីសម្រាប់ទទួលយក និងការកត់ត្រាការទទួលស្គាល់ពិរុទ្ធភាពដែលធ្វើឡើងដោយជនជាប់ចោទឡើយ។ ដូច្នេះ ជាទូទៅទោះបីជាជនជាប់ចោទបានយល់ព្រម ឬមិនបានជំទាស់ទៅនឹងអង្គហេតុភាគច្រើន ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែក៏ដោយ ក៏អង្គជំនុំជម្រះត្រូវតែស្តាប់ចម្លើយ និងវាយតម្លៃរាល់ភស្តុតាងទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងបញ្ហាដែលមិនមានការជំទាស់តវ៉ាផងដែរ។

## ខ. <u>បរិបទប្រវត្តិសាស្ត្រ និងនយោបាយ</u>

៨. ជាបឋម អង្គជំនុំជម្រះបានពិនិត្យលើបរិបទដែលរបបកម្ពុជាប្រជាធិបតេយ្យបានឡើងកាន់អំណាច។ អង្គជំនុំជម្រះបានយល់ឃើញថា ការប៉ះទង្គិចគ្នានៅតាមព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម បានកើតឡើងភ្លាមបន្ទាប់ពីទីក្រុងភ្នំពេញធ្លាក់ចូលក្នុងកណ្តាប់ដៃកងទ័ពបក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅស្ទើរតែគ្រប់ពេលទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ កងទ័ពកម្ពុជា និងកងទ័ពវៀតណាមបង្ក

៣

អរិភាពហិង្សាកាន់តែធ្ងន់ធ្ងរឡើងៗ ដែលទីបំផុតនាំឱ្យមានការដួលរលំទីក្រុងភ្នំពេញនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ហើយនាំឱ្យមេដឹកនាំកម្ពុជាប្រជាធិបតេយ្យរត់ភៀសខ្លួនចេញពីទីក្រុងភ្នំពេញ។

៩. អង្គជំនុំជម្រះក៏បានពិនិត្យរចនាសម្ព័ន្ធទូទៅ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលដែលពាក់ព័ន្ធ ជាពិសេស រចនាសម្ព័ន្ធ និងគោលនយោបាយដែលបានអនុវត្តសម្រាប់ប្រតិបត្តិការមន្ទីរស២១។ បក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំនៅឯសមាជបក្សក្នុងខែមករា ឆ្នាំ១៩៧៦ ដើម្បីរៀបចំនូវរចនាសម្ព័ន្ធដ៏ស្មុគស្មាញមួយតាមលក្ខន្តិកៈបក្ស ដែលគ្រប់គ្រងដោយគណៈកម្មាធិការមជ្ឈិម ដែលដាក់បរិធានរដ្ឋាភិបាលទាំងមូល និងកងកម្លាំងប្រដាប់អាវុធឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យទាំងស្រុងរបស់បក្សកុម្មុយនីស្តកម្ពុជា។ តាមការអនុវត្តជាក់ស្តែង អំណាចរបស់កម្ពុជាប្រជាធិបតេយ្យត្រូវអនុវត្តដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាស្ថាប័នប្រតិបត្តិរបស់គណៈកម្មាធិការមជ្ឈិម ដែលសមាជិកភាពរបស់គណៈកម្មាធិការមជ្ឈិមនេះរួមមាន ប៉ុល ពត ជាលេខា និងជានាយករដ្ឋមន្ត្រី និងសមាជិកជាន់ខ្ពស់មួយចំនួនទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានជ្រើសតាំង។ ស្ថាប័នទាំងអស់ រួមទាំងស្ថាប័នយោធា តម្រូវឱ្យរាយការណ៍ទៅគណៈកម្មាធិការមជ្ឈិម តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍។ លើសពីនេះទៀត ប្រជាជនស៊ីវិលទាំងអស់ ត្រូវបានគ្រប់គ្រងដោយបណ្តាញអង្គភាពដែលត្រួតពិនិត្យយ៉ាងហ្មត់ចត់ ដោយគណៈកម្មាធិការមជ្ឈិម តាមរយៈគណៈកម្មាធិការអចិន្ត្រៃយ៍។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានផ្សព្វផ្សាយទូទាំងកម្ពុជាប្រជាធិបតេយ្យតាមរយៈមធ្យោបាយនានា រួមមាន សេចក្តីណែនាំ ការប្រជុំមហាជន ការបណ្តុះបណ្តាល ការផ្សាយតាមវិទ្យុ តាមទស្សនាវដ្តីនានា។ ផ្នែកដ៏សំខាន់បំផុតនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងការជំនុំជម្រះក្តីនេះគឺ “ការកម្ទេច” ជាពាក្យដែលត្រូវបានគេប្រើប្រាស់ដើម្បីពិពណ៌នាអំពីការចាប់ខ្លួន ការសួរចម្លើយ និងការសម្លាប់បុគ្គលដែលត្រូវបានគេយល់ថាជាខ្មាំង ឬគិញ។

១០. អង្គជំនុំជម្រះបានពិនិត្យបទចោទប្រឆាំងនឹង កាំង ហ្គេកអ៊ាវ តាមរយៈការឆ្លុះបញ្ចាំងអំពីស្ថានភាពនយោបាយ និងប្រវត្តិសាស្ត្រទាំងនេះ។

## គ. មន្ទីរស២១ និងតួនាទីរបស់ជនជាប់ចោទ

១១. ជនជាប់ចោទកើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ។ បន្ទាប់ពីគាត់បានបញ្ចប់ការសិក្សា គាត់ត្រូវបានតែងតាំងជាគ្រូបង្រៀនគណិតវិទ្យា នៅអនុវិទ្យាល័យស្គន់ ខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៦៥ មុនពេលគាត់ចូលរួមក្នុងចលនាតស៊ូក្នុងឆ្នាំ១៩៦៧។ នៅឆ្នាំ១៩៧១ ជនជាប់ចោទត្រូវបានប្រគល់ភារកិច្ចឲ្យដឹកនាំមន្ទីរសន្តិសុខម១៣ របស់បក្សកុម្មុយនីស្តកម្ពុជា។ គាត់បានយកវិធីសាស្ត្រ និងគោលនយោបាយដែលគាត់បានប្រើនៅមន្ទីរម១៣ ទៅប្រើប្រាស់នៅមន្ទីរស២១ ដែលរួមបញ្ចូលទាំងការធ្វើទារុណកម្មនៅក្នុងអំឡុងពេលសួរចម្លើយ ការជ្រើសរើសបុគ្គលិក និងការបំពាក់បំប៉នមនោគមវិជ្ជាដល់ក្មេងជំទង់ៗ ដែលជាបុគ្គលិក និងការសម្លាប់អ្នកជាប់ឃុំជាប្រព័ន្ធ ក្រោយពីការសួរចម្លើយអ្នកជាប់ឃុំទាំងនោះបានចប់សព្វគ្រប់។

១២. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែបានចែងថា ជនជាប់ចោទបានបំពេញការងារជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ ដែលជាមន្ទីរសន្តិសុខមានភារកិច្ចក្នុងការសួរចម្លើយ និងសម្លាប់បុគ្គលដែលបក្សកុម្មុយនីស្តកម្ពុជាយល់ថា ជាខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យ ហើយជនជាប់ចោទក៏បានទទួលស្គាល់ដែរ។ មន្ទីរស២១ បានដំណើរការពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

១៣. បន្ទាប់ពីជួបប្រជុំដំបូងជាមួយ សុន សេន ជនជាប់ចោទ ក្នុងឋានៈជាអនុប្រធានមន្ទីរស២១ និង អ៊ិន លន *ហៅ* ណាត ជាប្រធាន បានបង្កើត និងចាប់ផ្តើមគ្រប់គ្រងអង្គភាពសួរចម្លើយមន្ទីរស២១ ក្នុងខែតុលា ឆ្នាំ១៩៧៥។ ក្នុងឋានៈជាប្រធានអង្គភាពសួរចម្លើយ ជនជាប់ចោទមានតួនាទីសំខាន់ចំនួនបួនៈ (i) ចងក្រងឯកសារដែលប្រមូលបានពីស្ថាប័នរបស់រដ្ឋាភិបាល លន់ នល់ (ii) រៀបចំរបាយការណ៍ឲ្យថ្នាក់លើរបស់គាត់ដោយផ្អែកតាមឯកសារទាំងនោះ (iii) បង្រៀនវិធីសាស្ត្រនៃការសួរចម្លើយដល់បុគ្គលិកនៃអង្គភាពសួរ-ចម្លើយ និង (iv) រាយការណ៍អំពីចម្លើយសារភាពរបស់អ្នកជាប់ឃុំទៅថ្នាក់លើរបស់គាត់។ ជនជាប់ចោទបានទទួលស្គាល់ថា ក្នុងឋានៈជាអនុប្រធាន គាត់បានអនុញ្ញាតឲ្យអ្នកសួរចម្លើយនៅមន្ទីរស២១ ធ្វើទារុណកម្ម។ ជនជាប់ចោទក៏បានដឹងផងដែរថា បន្ទាប់ពីការសួរចម្លើយបានចប់សព្វគ្រប់ អ្នកជាប់ឃុំត្រូវបានគេយកទៅសម្លាប់ចោល។

១៤. ក្នុងខែមីនា ឆ្នាំ១៩៧៦ ជនជាប់ចោទបានធ្វើជាប្រធានមន្ទីរស២១ ជំនួស អ៊ិន លន *ហៅ* ណាត។ ក្នុងតួនាទីជាប្រធាន ជនជាប់ចោទបានរាយការណ៍ជូន សុន សេន ចាប់ពីខែមីនា ឆ្នាំ១៩៧៦ រហូតដល់ ខែកញ្ញា ឆ្នាំ១៩៧៧ និងក្រោយមកទៀតរាយការណ៍ជូន នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ ស្របពេលជាមួយនឹងការតែងតាំងគាត់ជាប្រធានមន្ទីរស២១ ជនជាប់ចោទក៏មានតួនាទីជាលេខាគណៈកម្មាធិការមន្ទីរស២១ ផងដែរ។ ក្នុងនាមជាប្រធាន និងជាលេខា ជនជាប់ចោទមានអំណាចពេញលេញលើបុគ្គលិកមន្ទីរស២១ ទាំងអស់ ដែលរួមទាំងសមាជិកពីររូបផ្សេងទៀតរបស់គណៈកម្មាធិការមន្ទីរស២១ គឺ ឃឹម វ៉ាក *ហៅ* ហ៊ី និង នុន ហ៊ុយ *ហៅ* ហ៊ុយ ស្រែ។ តួនាទីរបស់ជនជាប់ចោទក្នុងនាមជាប្រធានមន្ទីរស២១ ដែលមិនត្រូវបានគេជំទាស់ ត្រូវបានបញ្ជាក់ដោយចម្លើយសារភាពរបស់ជនជាប់ចោទខ្លួនឯង សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីព្រមទាំងឯកសារផ្សេងៗដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី។

១៥. នៅខែមេសា ឆ្នាំ១៩៧៦ តាមសេចក្តីសម្រេចរបស់ជនជាប់ចោទ អ្នកជាប់ឃុំនៅមន្ទីរស២១ ត្រូវបានគេយកទៅឃុំឃាំងនៅក្នុងបរិវេណវិទ្យាល័យពញាយ៉ាត ដែលជាវិទ្យាល័យមួយស្ថិតនៅក្នុងទីក្រុងភ្នំពេញ។ មន្ទីរស២១ បានដំណើរការនៅលើទីតាំងនេះរហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលជាបរិវេណនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃនេះ។

១៦. អ្នកជាប់ឃុំនៅមន្ទីរស២១ មានអតីតអ្នករដ្ឋការ និងទាហាននៃរបប លន់ នល់ យុទ្ធជនរបស់កងទ័ពបដិវត្តកម្ពុជា កម្មាភិបាលជាន់ខ្ពស់ និងជាន់ទាបនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជាជាច្រើន សមាជិកគ្រួសារ និងអ្នកដែលធ្លាប់មានទំនាក់ទំនងជាមួយអ្នកទាំងនោះ ដែលរួមមានស្ត្រី កុមារ ជនបរទេសមកពីប្រទេសនានាជាពិសេស ទាហាន និងជនស៊ីវិលវៀតណាម ព្រមទាំងបុគ្គលិកមន្ទីរស២១ និងសាច់ញាតិរបស់ពួកគេផងដែរ។ ទោះបីជាឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញថាមានមនុស្សមិនតិចជាង ១២.២៧៣ នាក់ ត្រូវបានឃុំខ្លួននៅមន្ទីរស២១ ក្តី ក៏ចំនួនអ្នកជាប់ឃុំពិតប្រាកដទំនងជាមានច្រើនជាងចំនួនដែលមាននៅក្នុងបញ្ជីនេះទៅទៀត។

៦

១៧. ជនជាប់ចោទបានរៀបចំមន្ទីរស២១ តាមឋានានុក្រម និងបានបង្កើតប្រព័ន្ធនៃការរាយការណ៍គ្រប់ជាន់ថ្នាក់ ដើម្បីធានាថារាល់បទបញ្ជារបស់គាត់ពិតជាត្រូវបានអនុវត្តភ្លាមៗ និងជាក់លាក់។ មន្ទីរស២១ ត្រូវបានបែងចែកជាអង្គភាពជាច្រើន រួមមាន អង្គភាពឯកសារ អង្គភាពសួរចម្លើយ និងអង្គភាពការពារ ដែលអង្គភាពនីមួយៗប្រតិបត្តិការក្រោមការបញ្ជារបស់ជនជាប់ចោទ។ ក្រៅពីការគ្រប់គ្រងអង្គភាពនានា ដែលបានលើកឡើងខាងលើ ជនជាប់ចោទបានបំពេញភារកិច្ចពិសេសៗមួយចំនួនទៀត នៅក្នុងមន្ទីរស២១។ ភារកិច្ចសំខាន់បំផុតក្នុងចំណោមភារកិច្ចទាំងនោះមានដូចខាងក្រោមនេះ៖

<u>ការជ្រើសរើសបុគ្គលិក</u>៖ ជនជាប់ចោទបានទទួលស្គាល់ថា បុគ្គលិកមន្ទីរស២១ មួយចំនួនគឺជាអតីតអ្នកក្រោមបង្គាប់របស់គាត់នៅមន្ទីរម១៣។ លើសពីនេះទៀត ក្នុងឋានៈជាប្រធានមន្ទីរស២១ គាត់បានបន្តការអនុវត្តវិធីសាស្ត្រដែលបានអនុវត្តនៅមន្ទីរម១៣ក្នុងការជ្រើសរើសបុគ្គលិកជាក្មេងជំទង់ៗដែលងាយនឹងអប់រំឲ្យធ្វើជាអ្នកក្រោមបង្គាប់របស់គាត់។

<u>ការបណ្ដុះបណ្ដាលបុគ្គលិក</u>៖ ការបង្រៀន ជាពិសេសការបណ្ដុះបណ្ដាលនយោបាយ គឺជាភារកិច្ចមួយដ៏ចម្បងបំផុតរបស់ កាំង ហ្កេកអ៊ាវ នៅមន្ទីរស២១ ដែលគាត់បានកត់សម្គាល់ថា មានតែគាត់ម្នាក់ឯងប៉ុណ្ណោះដែលទទួលបន្ទុកអប់រំដល់បុគ្គលិកដែលធ្វើការនៅទីនោះ។ វគ្គបណ្ដុះបណ្ដាលបន្ថែមជាប្រចាំនៅសាលាបណ្ដុះបណ្ដាល រួមបញ្ចូលនូវការបណ្ដុះបណ្ដាលអនុវត្តអំពីវិធីសាស្ត្រសួរចម្លើយ ដែលវគ្គបណ្ដុះបណ្ដាលនោះបានកើនឡើងពីការបណ្ដុះបណ្ដាលប្រចាំឆ្នាំក្នុងឆ្នាំ១៩៧៧ ទៅជាការបណ្ដុះបណ្ដាលប្រចាំខែ និងប្រចាំសប្ដាហ៍វិញក្នុងឆ្នាំ១៩៧៨។ ជនជាប់ចោទ បានបណ្ដុះបណ្ដាលអ្នកសួរចម្លើយរបស់គាត់ឲ្យប្រើអំពើហិង្សាលើរាងកាយ និងផ្លូវចិត្ត ប៉ុន្តែបានបញ្ជាឲ្យអ្នកសួរចម្លើយទុកអ្នកជាប់ឃុំឲ្យនៅរស់រហូតដល់គាត់យល់ថាចម្លើយសារភាពរបស់អ្នកជាប់ឃុំទាំងនោះបានចប់សព្វគ្រប់ហើយ។

<u>តួនាទីក្នុងការចាប់ខ្លួន</u>៖ ជាទូទៅ ថ្នាក់លើរបស់ជនជាប់ចោទជាអ្នកសម្រេចថាតើត្រូវចាប់ខ្លួន និងបញ្ជូនអ្នកណាទៅមន្ទីរស២១។ ប៉ុន្តែ មានភស្តុតាងបញ្ជាក់ថាជនជាប់ចោទមានតួនាទីយ៉ាងសកម្មក្នុងការរៀបចំឲ្យមានការចាប់ខ្លួន និងមានភស្តុតាងបង្ហាញថាថ្នាក់លើរបស់ជនជាប់ចោទបានសុំយោបល់ពីជនជាប់ចោទ ហើយជនជាប់ចោទបានធ្វើតាមបញ្ជា

៧

ថ្នាក់លើរបស់គាត់។ លើសពីនេះទៀត ជនជាប់ចោទមានឥទ្ធិពលយ៉ាងខ្លាំងទាក់ទងទៅនឹងការចាប់ខ្លួនបុគ្គលិកមន្ទីរស២១ និងមានវត្តមានក្នុងពេលចាប់ខ្លួនអ្នកជាប់ឃុំសំខាន់ៗមួយចំនួន។

<u>តួនាទីទាក់ទងនឹងចម្លើយសារភាព៖</u> ជនជាប់ចោទបានពិនិត្យចម្លើយសារភាពរបស់អ្នក-ជាប់ឃុំ និងបញ្ជាជាប់ជាប្រចាំទៅអ្នកសួរចម្លើយ រួមទាំងការឲ្យធ្វើទារុណកម្ម រហូតទាល់តែគាត់គិតថា ចម្លើយសារភាពបានចប់សព្វគ្រប់អស់ហើយ។ ចម្លើយសារភាពមិនអាចចាត់ទុកថាពេញលេញនោះទេ ប្រសិនបើព័ត៌មានដែលទទួលបានមិនទាន់លម្អិតគ្រប់គ្រាន់ ឬមិនទាន់បានឆ្លើយដាក់ឈ្មោះ "ជនក្បត់" ផ្សេងទៀត។ បន្ទាប់ពីការពិនិត្យមើលរួចហើយ ជនជាប់ចោទជាមនុស្សតែម្នាក់គត់ ដែលទទួលខុសត្រូវចំពោះការបញ្ជូនចម្លើយសារភាពរបស់អ្នកជាប់ឃុំ និងបញ្ជីឈ្មោះអ្នកដែលត្រូវបានគេឆ្លើយដាក់ទៅឲ្យថ្នាក់លើរបស់គាត់។ ជនជាប់ចោទបានដឹងថា ព័ត៌មានភាគច្រើននៅក្នុងចម្លើយសារភាព ដែលគាត់បានបញ្ជូនឲ្យថ្នាក់លើរបស់គាត់គឺជាព័ត៌មានប្រឌិត។ ទោះជាបែបនេះក្តី ចម្លើយសារភាពរបស់មន្ទីរស២១ ត្រូវបានយកមកប្រើ ដើម្បីសម្រេចចាប់ខ្លួនអ្នកដែលត្រូវបានឆ្លើយដាក់ថាជាខ្មាំង ហើយជាញឹកញាប់ ចម្លើយសារភាពទាំងនោះត្រូវបានគេប្រើប្រាស់ដើម្បីចាប់ខ្លួនអ្នកផ្សេងជាច្រើននាក់ទៀត ដោយសារតែមានការឆ្លើយដាក់ថាជាជនក្បត់។

<u>តួនាទីក្នុងការសម្លាប់៖</u> ពីដំបូង ជនជាប់ចោទបានអនុញ្ញាតឲ្យ ឃឹម វ៉ាក *ហៅ* ហ៊ី ចាត់ចែងពេលវេលានៃការសម្លាប់អ្នកជាប់ឃុំ។ ប៉ុន្តែក្រោយពីមានឧប្បត្តិហេតុមួយដែលអ្នក-ជាប់ឃុំម្នាក់ត្រូវបានសម្លាប់ មុនពេលគាត់ផ្តល់ចម្លើយសារភាពចប់សព្វគ្រប់មក ជនជាប់-ចោទបានតម្រូវថា គាត់ត្រូវតែបានដឹងថា ការសួរចម្លើយបានចប់សព្វគ្រប់មុននឹងយកអ្នកជាប់ឃុំទៅសម្លាប់ចោល។

១៨. លើសពីនេះទៀត ក្នុងឋានៈជាប្រធានមន្ទីរស២១ ជនជាប់ចោទបានជ្រើសរើសផ្លាស់ទីកន្លែងសម្លាប់ និងទីកន្លែងកប់សាកសពរបស់មន្ទីរស២១ ទៅដាក់នៅជើងឯក ដែលស្ថិតនៅចំងាយប្រហែល១៥គម ភាគនិរតីនៃទីក្រុងភ្នំពេញ។ បន្ទាប់ពីបានចម្លើយសារភាពចប់សព្វគ្រប់ អ្នកជាប់ឃុំនៅក្នុងមន្ទីរស២១ ជាធម្មតា ត្រូវបានដឹកយកទៅជើងឯក ដែលជាទីកន្លែងដែលអ្នកជាប់ឃុំទាំងនោះត្រូវបានគេសម្លាប់យ៉ាងទាន់ហាន់ជាទីបំផុត។

៨

១៩. ជនជាប់ចោទក៏បានអនុវត្តអំណាចទៅលើ ស២៤ ដែលគេស្គាល់ថាជា ព្រៃស ផងដែរ។ ព្រៃសមានទីតាំងស្ថិតនៅក្រៅទីក្រុងភ្នំពេញ ហើយត្រូវបានប្រើប្រាស់ជាមណ្ឌលលត់ដំខ្លួន។ នុន ហ៊ុយ *ហៅ* ហ៊ុយ ស្រែ ធ្វើការតែនៅ ស២៤ ជាអ្នកមើលប្រតិបត្តិការការងារប្រចាំថ្ងៃនៅទីនោះដោយផ្ទាល់។ បន្ទាប់ពីការចាប់ខ្លួន ហ៊ុយ ស្រែ នៅខែធ្នូ ឆ្នាំ១៩៧៨ ផល ត្រូវបានតែងតាំងឲ្យទៅមើលការខុសត្រូវ ស២៤ រហូតដល់ពេលមន្ទីរនេះត្រូវបានបោះបង់ចោលនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ ក្នុងអំឡុងពេលនោះ ជនជាប់ចោទបានទទួលរបាយការណ៍ជាប្រចាំ ទាក់ទងនឹងប្រតិបត្តិការស២៤។ អ្នកជាប់ឃុំនៅ ស២៤ ភាគច្រើនជាសាច់ញាតិ ឬអ្នកនៅក្រោមបង្គាប់របស់អ្នកដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ និងជាយុទ្ធជន និងបុគ្គលិកមកពីក្រសួងមន្ទីរ ឬស្ថាប័នសាធារណៈនានា។ ផ្អែកលើឯកសារផ្សេងៗពីគ្នា និងមានចំនួនតិចតួច ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះយល់ឃើញថា ចំនួនអ្នកជាប់ឃុំសរុបនៅ ស២៤ មានមិនតិចជាង ១.៣០០ នាក់ឡើយ។

## ឃ. <u>អង្គហេតុពាក់ពន្ធ័នឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅមន្ទីរស២១</u>

២០. ក្នុងអំឡុងពេលនៃការជំនុំជម្រះក្តី ភស្តុតាងដូចខាងក្រោមនេះ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅមន្ទីរស២១។ អង្គហេតុផ្សេងៗទៀត ដែលពាក់ព័ន្ធជាពិសេសទៅនឹងឈ្លើយសឹក និងជនស៊ីវិលវៀតណាម ព្រមទាំងអ្នកគាំទ្រវៀតណាម ដែលត្រូវបានជាប់ឃុំនៅមន្ទីរស២១ ក៏ត្រូវបានលើកឡើងផងដែរដោយអង្គជំនុំជម្រះ ដែលទាក់ទងទៅនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។

*<u>ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលៈ</u>* ជនគ្រប់រូបដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ (ទួលស្លែង) សុទ្ធតែរង់ចាំការសម្លាប់ទាំងអស់ អនុលោមទៅតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការ “កម្ទេច” ខ្មាំង។ ក្នុងចំណោមអ្នកទាំងឡាយដែលត្រូវបានសម្លាប់ គឺជាអតីតអ្នកគាំទ្ររបប លន់ នល់ ជនបរទេស កុមារ អ្នកជាប់ឃុំដែលមានឋានៈខ្ពស់ និងអតីតបុគ្គលិកមន្ទីរស២១។ ការសម្លាប់អ្នកជាប់ឃុំជាទ្រង់ទ្រាយធំ ត្រូវបានបញ្ជាដោយគណៈកម្មាធិការមជ្ឈិមបក្ស និងបានធ្វើឡើងជាច្រើនដង។ ក្រៅពីអ្នកទាំង-

ឡាយដែលត្រូវបានសម្លាប់ អ្នកជាប់ឃុំជាច្រើនទៀតបានស្លាប់ដោយសារតែការធ្វើ-ទារុណកម្ម និងស្ថានភាពនៃការឃុំខ្លួន។ លើសពីនេះទៀត យ៉ាងហោចណាស់ ក៏មានអ្នកជាប់ឃុំនៅមន្ទីរស២១ចំនួន ១០០ នាក់ដែរ ដែលបានស្លាប់ បន្ទាប់ពីត្រូវបានគេបូមយកឈាមអស់ដោយអង្គភាពពេទ្យមន្ទីរស២១។ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកជាប់ឃុំដែលបានស្លាប់ ឬត្រូវបានសម្លាប់មានចំនួនច្រើនជាង ១២.២៧៣ នាក់ ដែលមាននៅក្នុងបញ្ជីអ្នកទោសដែលត្រូវបានកែសម្រួល។

*ការធ្វើឱ្យទៅជាទាសករ៖* ជនជាប់ចោទក៏បានយល់ស្របថា ស២៤ គឺជាកន្លែងដែលធ្វើឱ្យទៅជាទាសករ ដែលនៅទីនោះអ្នកជាប់ឃុំដែលត្រូវបានគេស្គាល់ថាជា "ពួកសមាស-ភាព" ត្រូវបានលត់ដំខាងការងារពលកម្ម។ សាក្សី ប៊ូ ថុន និង មាស ប៉េងគ្រី ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត បានពិពណ៌នាអំពីស្ថានភាពការងារធ្ងន់ធ្ងរ ដែលពួកគាត់ត្រូវបានបង្ខំឱ្យប្រឈមក្នុងអំឡុងពេលដែលពួកគាត់ត្រូវបានឃុំខ្លួននៅ ស២៤។ លើសពីនេះទៀត អ្នកជាប់ឃុំមួយចំនួនតូចបំផុត ត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងមន្ទីរស២១។ អ្នកទាំងនោះ រួមមាន សាក្សី វ៉ាន់ ណាត និងដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង និង ជុំ ម៉ី។ ដំបូង អ្នកទាំងនោះត្រូវបានចាប់ខ្លួន ដាក់ខ្នោះ និងឃុំខ្លួននៅមន្ទីរស២១ មុនពេលពួកគាត់ត្រូវបានជ្រើសរើសឱ្យធ្វើការនៅក្នុងមន្ទីរស២១ (ទួលស្លែង)។

*ការដាក់ក្នុងមន្ទីរឃុំឃាំង៖* យ៉ាងហោចណាស់ក៏មានមនុស្សចំនួន ១២.២៧៣ នាក់ ដែលក្នុងនោះរួមមានទាំងបុរស ស្ត្រី និងកុមារ ត្រូវបានឃុំខ្លួននៅមន្ទីរស២១។ បុគ្គលមួយចំនួនដែលត្រូវបានគេកំណត់មុខសញ្ញាឱ្យនាំខ្លួនមកមន្ទីរស២១ ត្រូវបានគេចាប់ខ្លួនជាសម្ងាត់ ចំណែកឯអ្នកផ្សេងទៀត ត្រូវបានគេដាក់ខ្នោះដៃ ចងមុខ បង្ខំឱ្យបំពេញបែបបទមួយចំនួនមុននឹងត្រូវបានគេយកទៅឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងតូចៗ ឬបន្ទប់ឃុំឃាំងរួម ដែលជាកន្លែងអ្នកជាប់ឃុំទាំងនោះ ត្រូវបានគេដាក់ខ្នោះជើងជារនងបន្តជាប់ៗគ្នា។ ស២៤ ក៏បានឃុំខ្លួនមនុស្សរាប់រយនាក់ ដែលរួមមានទាំងបុរស ស្ត្រី និងកុមារនៅក្នុងពេលតែមួយផងដែរ។ អ្នកជាប់ឃុំកម្រនឹងត្រូវបានគេដោះលែងណាស់។ មិនមានការជំនុំជម្រះក្តី ឬក៏យន្តការដទៃទៀត ក្នុងការជំទាស់តវ៉ាទៅនឹងការចាប់ខ្លួន ការឃុំខ្លួន ឬការសម្លាប់ឡើយ។ ជនជាប់ចោទយល់ស្របថា ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ដោយគ្មានការជំនុំជម្រះ គឺជា "[...] វិសមិតភាពជាមួយនឹងអត្ថិភាពនៃតុលាការ និងការធានាផ្នែកនីតិវិធី"។

*<u>ការធ្វើទារុណកម្ម និងការរំលោភលើផ្លូវភេទ៖</u>* បច្ចេកទេសធ្វើទារុណកម្មជាច្រើនត្រូវបានអនុវត្តនៅក្នុងមន្ទីរស២១ (ទួលស្លែង)។ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកសួរចម្លើយត្រូវបានអនុញ្ញាតឱ្យប្រើបច្ចេកទេសសួរចម្លើយ ដោយប្រើហិង្សាចំនួនបួនយ៉ាង គឺ ការវាយ ការឆក់ខ្សែភ្លើង ការច្រកក្បាលក្នុងថង់ប្លាស្ទិក និងការ“បន្តក់ទឹកចូលក្នុងច្រមុះ”។ ក្រៅពីវិធីសាស្ត្រដែលត្រូវបានអនុញ្ញាតទាំងនេះ ជនជាប់ចោទបានទទួលស្គាល់ថា បច្ចេកទេសបន្ថែមទៀតត្រូវបានអនុវត្តដោយអ្នកសួរចម្លើយ រួមមាន មួយករណីដែលបុគ្គលិកមន្ទីរស២១ បានយកឈើរុកចូលទៅក្នុងប្រដាប់ភេទអ្នកជាប់ឃុំស្ត្រីម្នាក់ ក្នុងអំឡុងពេលសួរ-ចម្លើយ។ ការប្រើប្រាស់បច្ចេកទេសនានាក្នុងការសួរចម្លើយ គឺធ្វើឡើងដើម្បីទទួលបានចម្លើយសារភាព ដែលមានរៀបរាប់លម្អិតអំពីជីវប្រវត្តិរបស់អ្នកជាប់ឃុំ ចរិតលក្ខណៈនៃបទឧក្រិដ្ឋ និងសកម្មភាព “ក្បត់” ផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់រវាងអ្នកជាប់ឃុំក្នុងអំពើនោះ និងបណ្តាញ “ជនក្បត់” ដទៃទៀត។

២១. អង្គជំនុំជម្រះបានស្តាប់ការផ្តល់សក្ខីកម្មរបស់អតីតអ្នកជាប់ឃុំម្នាក់នៅមន្ទីរស២១ ដែលបានទទួលរងនូវដំណើរការនៃការសួរចម្លើយរបៀបនេះ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃ ចំនួនពីរសប្តាហ៍ជាប់គ្នា។ គេបានដាក់ខ្នោះជើងគាត់ និងបានបង្ខំគាត់ឱ្យដេកផ្កាប់មុខទៅលើឥដ្ឋ ហើយគេប្រើសម្តីអសុរោះមកលើគាត់។ អ្នកសួរចម្លើយបង្ហាញគាត់នូវឧបករណ៍ធ្វើទារុណកម្ម និងបានប្រាប់គាត់ ឱ្យជ្រើសរើសនូវឧបករណ៍ណាមួយដែលនឹងត្រូវយកមកប្រើសម្រាប់ធ្វើ-ទារុណកម្មលើរូបគាត់។ អ្នកសួរចម្លើយបានប្តូរវេនគ្នាវាយខ្នងគាត់នឹងខ្សែតី រំពាត់ផ្តៅ ដែលបណ្តាលឱ្យមានឈាមហូរពាសពេញលើឥដ្ឋ។ អ្នកសួរចម្លើយក៏បានប្រើខ្សែភ្លើងឆក់គាត់រហូតដល់សន្លប់ផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ម៉េង នៅមានសម្លាកដោយសារតែការវាយទាំងនោះ។ គ្រប់ពេលដែលគេវាយគាត់ គេបានសួរសំណួរគាត់ទាក់ទងនឹងការពាក់ព័ន្ធរបស់គាត់ជាមួយសេអ៊ីអា (CIA) និងកាហ្សេបេ (KGB)។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ដែលជាអតីតអ្នកជាប់ឃុំនៅមន្ទីរស២១ ម្នាក់ទៀតដែរនោះ បាននិយាយថា គេបានសួរចម្លើយគាត់អស់រយៈពេល១២ថ្ងៃ និង១២យប់។ នៅក្នុងអំឡុងពេលសួរចម្លើយ គេបានវាយគាត់នឹងរំពាត់ខ្សែតីជាច្រើនលើកច្រើនសា។ នៅពេលគាត់ព្យាយាមបដិសេធចំពោះការចោទប្រកាន់ថាគាត់មានការពាក់ព័ន្ធជាមួយ សេអ៊ីអា (CIA) ឬកាហ្សេបេ (KGB)

នោះ អ្នកសួរចម្លើយម្នាក់បានដកក្រចកជើងគាត់ទាំងសងខាង ដែលបណ្តាលឱ្យគាត់ "ឈឺញ័រតតាក់"។ គាត់បានទទួលរងនូវការឆក់ខ្សែភ្លើងចំនួនពីរលើក ហើយគាត់បានដួលសន្លប់បន្ទាប់ពីការឆក់មួយលើកៗ។ ការសួរចម្លើយបានបញ្ឈប់ ក្រោយពេលដែលគាត់ "បានសារភាព" ថា ពិតជាបានចូលរួមជាមួយសេអ៊ីអា (CIA) និងកាហ្សេបេ (KGB) មែន។

២២. ការធ្វើទារុណកម្មនៅ ស២១ ត្រូវបានគេយកមកប្រើ ដើម្បីដាក់ទណ្ឌកម្មដល់អ្នកជាប់ឃុំទប់ស្កាត់ពួកគេកុំឱ្យលួចរត់គេចខ្លួន និងនៅក្នុងអំឡុងពេលសួរចម្លើយដែលត្រូវបានគេអនុវត្តម្តងម្កាលនៅស២៤ ។

២៣. បុគ្គលិកមន្ទីរស២១ និងបុគ្គលិក ស២៤ រួមទាំងអ្នកសួរចម្លើយ បានបំពេញតួនាទីតាមឋានានុក្រមដែលត្រូវបានរៀបចំឡើងយ៉ាងច្បាស់លាស់ ក្រោមបញ្ជា ឬអំណាចរបស់ជន-ជាប់ចោទដែលជនជាប់ចោទខ្លួនឯងផ្ទាល់ បានបំពេញតួនាទីនេះ តាមបញ្ជារបស់គណៈ-កម្មាធិការអចិន្ត្រៃយ៍។ ដោយពិចារណាអំពីតួនាទីរបស់បុគ្គលិកទាំងអស់នោះនៅក្នុងបរិធានរដ្ឋាភិបាល អង្គជំនុំជម្រះសន្និដ្ឋានថា អ្នកសួរចម្លើយនៅមន្ទីរស២១ និងបុគ្គលិក ស២៤ ដែលបានប្រព្រឹត្តអំពើទារុណកម្មទាំងឡាយ បានអនុវត្តសមត្ថកិច្ចផ្លូវការរបស់ខ្លួន។

<u>*អំពើអមនុស្សធម៌ផ្សេងទៀត៖*</u> ជនជាប់ចោទបានយល់ស្របថា ស្ថានភាពរស់នៅ ដែលរួមបញ្ចូលទាំងការឃុំខ្លួន ការសួរចម្លើយ និងការបាត់ខ្លួនអ្នកជាប់ឃុំ បានធ្វើឱ្យចុះខ្សោយដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តអ្នកជាប់ឃុំ ហើយថាពួកគេទាំងអស់នោះបានរស់នៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ។ លើសពីនេះទៀត អ្នកជាប់ឃុំបានទទួលរងនូវការខ្វះម្ហូបអាហារ អនាម័យ និងការព្យាបាលផ្នែកវេជ្ជសាស្ត្រ។ គោលបំណងតែមួយគត់ក្នុងការផ្តល់នូវការព្យាបាលផ្នែកវេជ្ជសាស្ត្រ គឺដើម្បីទុកអ្នកជាប់ឃុំឱ្យនៅរស់សម្រាប់ការសួរ-ចម្លើយពួកគេតែប៉ុណ្ណោះ។ ភស្តុតាងទាក់ទងនឹងការធ្វើបាបអ្នកជាប់ឃុំនៅជើងឯក និង ស២៤ ត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះផងដែរ។

<u>*ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖*</u> ការធ្វើទុក្ខបុកម្នេញ ពិពណ៌នាអំពីការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាន ដែលប្រព្រឹត្តឡើងដោយផ្អែកលើមូលដ្ឋាននៃការរើស-អើង។ ក្នុងការអនុវត្តជាក់ស្តែង ការធ្វើទុក្ខបុកម្នេញគឺជាបទល្មើសដែលគ្របដណ្តប់លើបទល្មើសជាក់លាក់មួយចំនួនផ្សេងទៀត ដែលតម្រូវឱ្យបង្ហាញនូវធាតុចេតនានៃការ

១២

រើសអើង។ ការបដិសេធនូវសិទ្ធិជាមូលដ្ឋានដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែបង្ហាញអំពីបទល្មើសការធ្វើទុក្ខបុកម្នេញ ដែលនៅក្នុងនោះ មានបទល្មើសនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់-រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ អង្គជំនុំជម្រះបានបង្ហាញអំពីប្រភេទនៃបទល្មើសនានាដែលបានប្រព្រឹត្តនៅមន្ទីរស២១ ហើយអង្គជំនុំជម្រះនឹងបង្ហាញលម្អិតនូវសំអាងហេតុនៃបទល្មើសនោះថា តើបទល្មើសទាំងនោះបង្កើតបានជាបទល្មើសនៃការធ្វើទុក្ខបុកម្នេញដែរ ឬទេ នៅក្នុងសេចក្តីសង្ខេបខាងក្រោមនេះ។

## ខ. ច្បាប់ជាធរមាន និងសំអាងហេតុទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទ

២៤. ដូចដែលបានរៀបរាប់យ៉ាងពិស្តារនៅក្នុងសាលក្រម អង្គជំនុំជម្រះបានយល់ឃើញថា បទល្មើសទាំងឡាយដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ អនុលោមតាមមាត្រា៥ និងមាត្រា៦ នៃច្បាប់ អ.វ.ត.ក ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់ អនុលោមតាមមាត្រា២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក ត្រូវបានទទួលស្គាល់ថាជាបទល្មើសនៅក្នុងច្បាប់អន្តរជាតិ នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។

២៥. អង្គជំនុំជម្រះយល់ឃើញទៀតថា បុរេលក្ខខណ្ឌចាំបាច់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ពោលគឺអត្ថិភាពនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធ សំដៅប្រឆាំងនឹងជនស៊ីវិល ដោយសារតែមូលហេតុសញ្ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា) បានកើតមាន តាមពេលដែលពាក់ព័ន្ធ។ តាមការយល់ឃើញអំពីសំអាងហេតុនៃបទល្មើសទាក់ទងនឹងមន្ទីរស២១ អង្គជំនុំជម្រះយល់ឃើញថា បទល្មើសដែលត្រូវបានចោទប្រកាន់តាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែពិតជាមានប្រាកដមែន។ អង្គជំនុំជម្រះដោយមតិភាគច្រើន យល់ឃើញផងដែរថា បទល្មើសទាំងនេះ ត្រូវបានចោទប្រកាន់ត្រួតគ្នានៅក្នុងបទល្មើសការធ្វើទុក្ខបុក-ម្នេញដោយផ្អែកលើមូលដ្ឋានថា ជនជាប់ចោទបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ដោយមានចេតនារើសអើងជាក់លាក់ ខាងមូលហេតុនយោបាយ។

២៦. អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ជម្លោះប្រដាប់អាវុធអន្តរជាតិដែលបានកើតឡើងរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម នៅគ្រប់ពេលទាំងអស់នោះ ពិតជាពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ អង្គជំនុំជម្រះបានជឿថា បុរេលក្ខខណ្ឌចាំបាច់សម្រាប់ការកំណត់ពិរុទ្ធភាព អនុលោមតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ដែលទាក់ទងទៅនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ត្រូវបានបំពេញ។ អង្គជំនុំជម្រះបានយល់ឃើញថា ឈ្លើយសឹក និងជនស៊ីវិលវៀតណាម ព្រមទាំងអ្នកគាំទ្រវៀតណាម ដែលត្រូវបានឃុំខ្លួននៅមន្ទីរស២១ បានស្ថិតនៅក្រោមស្ថានភាពនៃការឃុំខ្លួន ដូចគ្នាទៅនឹងអ្នកជាប់ឃុំដទៃទៀតដែរ និងត្រូវបានកំណត់សម្លាប់ចោលដោយជៀសមិនផុត ដោយមិនមានលក្ខខណ្ឌអនុគ្រោះចំពោះឈ្លើយសឹក និងជនស៊ីវិលទាំងនោះ ដោយសារសញ្ជាតិពួកគាត់ ឬឋានៈដែលត្រូវទទួលបានការការពារនោះឡើយ។ តាមការយល់ឃើញលើសំអាងហេតុមុនៗរបស់អង្គជំនុំជម្រះ ទាក់ទងនឹងមន្ទីរស២១ អង្គជំនុំជម្រះយល់ឃើញថា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលមានបទល្មើស ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ដែលអាចផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ អ.វ.ត.ក ពិតជាមានប្រាកដមែន។

២៧. នៅមានបញ្ហាមួយចំនួនទៀត អំពីថា តើមានភស្តុតាងដើម្បីបញ្ជាក់ថា ជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅមន្ទីរស២១ ដែរ ឬទេ។

២៨. ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើការកែប្រែ ចោទប្រកាន់ថា ជនជាប់ចោទបានធ្វើទារុណកម្ម ឬធ្វើបាបទៅលើអ្នកជាប់ឃុំនៅមន្ទីរស២១ ដោយផ្ទាល់ខ្លួនជាច្រើនដង។ អង្គជំនុំជម្រះបានយល់ឃើញថា មិនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទទទួលខុសត្រូវចំពោះអំពើទារុណកម្ម ឬអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើសកម្ម ឬអកម្ម ដែលគាត់បានប្រព្រឹត្តដោយផ្ទាល់ឡើយ។

១៤

២៩. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានសម្រេចថា ការប្រព្រឹត្តិតាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់ដែលអាចយកមកអនុវត្តចំពោះការទទួលខុសត្រូវទាំងនៅ អ.វ.ត.ក និងនៅក្នុងរឿងក្តីនេះ យ៉ាងហោចណាស់ក៏នៅក្នុងទម្រង់មូលដ្ឋាន និងទម្រង់ជាប្រព័ន្ធរបស់សហឧក្រិដ្ឋកម្មរួមដែរ។ ជាពិសេសអង្គជំនុំជម្រះមានសំអាងហេតុជាច្រើនទាក់ទងនឹងឧក្រិដ្ឋកម្មដែលមានលក្ខណៈជាប្រព័ន្ធនៅមន្ទីរស២១ ដែលគ្រប់គ្រងដោយជនជាប់ចោទ។ នេះបង្ហាញឲ្យឃើញច្បាស់នូវទម្រង់ជាប្រព័ន្ធទីពីរនៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានយកមកអនុវត្ត នៅចំពោះមុខតុលាការអន្តរជាតិដទៃទៀត ទាក់ទងនឹងមន្ទីរឃុំឃាំង ឬរចនាសម្ព័ន្ធគ្រប់គ្រងដទៃទៀត ដែលអនុវត្តនូវការរំលោភបំពានជាប្រព័ន្ធប្រឆាំងនឹងអ្នកជាប់ឃុំ។

៣០. អង្គជំនុំជម្រះបានយល់ឃើញថា ក្រោយពេលជួបប្រជុំជាមួយ សុន សេន នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ជនជាប់ចោទបានជួយបង្កើតមន្ទីរស២១ ជាមួយនឹង អ៊ិន លន *ហៅ* ណាត ដែលជាប្រធានមន្ទីរស២១ មុនគេ។ ក្នុងឋានៈជាប្រធាន និងជាលេខាមន្ទីរស២១ ជនជាប់ចោទបានបន្តកែលំអ និងដឹកនាំប្រតិបត្តិការមន្ទីរស២១ ដោយមានការជួយជ្រោមជ្រែងពីសមាជិកគណៈកម្មាធិការមន្ទីរស២១ ដែលមានឈ្មោះ ឃឹម វ៉ាត *ហៅ* ហ៊ោ និង នុន ហ៊ុយ *ហៅ* ហ៊ុយ ស្រែ រហូតដល់បោះបង់ចោលមន្ទីរស២១ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ ជនជាប់ចោទបានបំពេញការងារជាមួយបុគ្គលទាំងនេះ និងតាមរយៈថ្នាក់លើរបស់គាត់ ដើម្បីដំណើរការមន្ទីរស២១ (ទួលស្លែង) ដែលជាកន្លែងមួយសម្រាប់ប្រព្រឹត្តអំពើដោយខុសច្បាប់ក្នុងការឃុំខ្លួន សួរចម្លើយ និងសម្លាប់អ្នកទាំងឡាយណាដែលគេយល់ថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ទាំងជនជាតិខ្មែរ និងជនបរទេស។ ប្រព័ន្ធនៃការធ្វើបាប និងធ្វើទារុណកម្មដែលបានរៀបចំជាមុន ត្រូវបានអនុវត្តដោយមានចេតនាធ្វើឡើង ដើម្បីបង្ក្រាបអ្នកជាប់ឃុំ និងដើម្បីទាញយកចម្លើយសារភាពពីពួកគេ ក្នុងអំឡុងពេលសួរចម្លើយ។ ស២៤ ក៏ត្រូវបានប្រើប្រាស់ផងដែរជាមន្ទីរចំណុះ សម្រាប់លត់ដំការងារពលកម្មដល់អ្នកជាប់ឃុំ ដែលបក្សកុម្មុយនីស្តកម្ពុជាយល់ថា ជាជនសង្ស័យ។ ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធាន និងជាលេខាមន្ទីរស២១ ជនជាប់ចោទបានជាប់ពាក់ព័ន្ធយ៉ាងជ្រៅនៅក្នុងប្រព័ន្ធឧក្រិដ្ឋនេះ និងបានរួមចំណែកយ៉ាងច្រើនដល់ការបង្កើត និងការអនុវត្តប្រព័ន្ធនេះ តាមរយៈការចូលរួមក្នុងប្រតិបត្តិការចាប់ខ្លួនបុគ្គល

សំខាន់ៗមួយចំនួន តាមរយៈការបញ្ជាឲ្យមានការឃុំខ្លួន និងសម្លាប់បុគ្គលិកមន្ទីរស២១ មួយចំនួន និងតាមរយៈការមានវត្តមានផ្ទាល់របស់ជនជាប់ចោទ ក្នុងពេលប្រព្រឹត្តអំពើទាំងនោះ។ លើសពីនេះទៀត ជនជាប់ចោទបានដឹងអំពីលក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្មនៅមន្ទីរស២១ និងបានបំពេញភារកិច្ច ដោយមានចេតនាដើម្បីជួយជ្រោមជ្រែងគោលបំណងឧក្រិដ្ឋទាំងនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានយល់ឃើញថា ជាលទ្ធផលនៃការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួមជាប្រព័ន្ធនៅមន្ទីរស២១ ជនជាប់ចោទត្រូវទទួលខុស-ត្រូវព្រហ្មទណ្ឌជាបុគ្គលចំពោះបទល្មើសទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស២១។

៣១. អង្គជំនុំជម្រះបានយល់ឃើញបន្ថែមទៀតថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងជំរុញ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយនៅមន្ទីរស២១។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ជនជាប់ចោទមានការទទួលខុសត្រូវ ដោយផ្អែកទៅលើការទទួលខុសត្រូវក្នុងនាមគាត់ជាថ្នាក់លើ។ អង្គជំនុំ-ជម្រះបានប្រើសំអាងហេតុបន្ថែមទាំងនេះ នៅពេលផ្តន្ទាទោសនៅក្នុងការសម្រេចអំពីវិសាលភាពពេញលេញនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងបទឧក្រិដ្ឋដែលគាត់ត្រូវទទួលខុសត្រូវ។

៣២. អង្គជំនុំជម្រះបានបដិសេធការទាមទាររបស់មេធាវីការពារក្តីដែលថា ជនជាប់ចោទមិនត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ដោយហេតុថា ជនជាប់ចោទបានប្រព្រឹត្តអំពើទាំងនោះ តាមបញ្ជារបស់ថ្នាក់លើ និងក្រោមការបង្ខិតបង្ខំតែប៉ុណ្ណោះ។ តាមច្បាប់ការប្រព្រឹត្តិតាមបញ្ជារបស់ថ្នាក់លើ មិនបង្កើតបានជាការការពារស្របច្បាប់ចំពោះការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ នៅក្នុងរឿងក្តីនេះ ជនជាប់ចោទក៏បានដឹងថា បទបញ្ជាឲ្យសម្លាប់ ធ្វើទារុណកម្ម និងឃុំឃាំងតាមអំពើចិត្ត នូវបុគ្គលដែលត្រូវទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាអំពើខុសច្បាប់។ លើសពីនេះទៀត ជនជាប់ចោទមិនអាចត្រូវបានចាត់ទុកថាបានប្រព្រឹត្តក្រោមការបង្ខិតបង្ខំ ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស២១ នោះទេ។ ទោះបីជា អង្គជំនុំជម្រះទទួលស្គាល់ថា រហូតដល់ចុងបញ្ចប់នៃអត្ថិភាពរបស់មន្ទីរស២១ ជនជាប់ចោទអាចមានការភ័យខ្លាចថា គាត់ ឬសាច់ញាតិជិតស្និទ្ធរបស់គាត់ នឹងត្រូវគេសម្លាប់ ប្រសិនបើ ថ្នាក់-លើរបស់គាត់មិនពេញចិត្តនឹងអំពើរបស់គាត់ក៏ដោយ ក៏មិនអាចយកការបង្ខិតបង្ខំមកធ្វើ

១៦

ជាសំអាងបានឡើយ ដោយសារជនជាប់ចោទខ្លួនឯងបានចូលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្ត ក្នុងការអនុវត្តគោលនយោបាយប្រកបដោយភាពភ័យរន្ធត់នោះ។ តាមពិត អំពើរបស់ជនជាប់ចោទក្នុងការអនុវត្តតួនាទីទាំងនេះ បានបង្ហាញឱ្យឃើញនូវកម្រិតដ៏ខ្ពស់នៃប្រសិទ្ធភាពការងារ និងការពេញចិត្តចំពោះភារកិច្ចរបស់គាត់។

៣៣. ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលស្របតាមមាត្រា២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចំពោះបទល្មើសខាងក្រោមនេះ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ព្រមទាំងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

៣៤. នៅពេលដែលមានការផ្តន្ទាទោសច្រើនបទល្មើស យុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបានបង្កើតគោលការណ៍សម្រាប់កំណត់ថា តើបទល្មើសមួយណាដែលត្រូវផ្តន្ទាទោស និងបទល្មើសមួយណា ដែលត្រូវយកទៅពិចារណាដាក់បញ្ចូលជាមួយបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរជាង។ អនុលោមទៅតាមគោលការណ៍នេះ អង្គជំនុំជម្រះបាន៖ (ក) ប្រើប្រាស់ការផ្តន្ទាទោសសម្រាប់បទឧក្រិដ្ឋស្រដៀងគ្នា ជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយពិចារណាទៅលើលក្ខណៈខុសគ្នានៃប្រភេទបទឧក្រិដ្ឋទាំងពីរ (ខ) ដាក់បញ្ចូលបទល្មើសការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទៅក្នុងបទល្មើសការសម្លាប់រង្គាលដែលជាឧក្រិដ្ឋ-កម្មប្រឆាំងនឹងមនុស្សជាតិ និង (គ) ដាក់បញ្ចូលការផ្តន្ទាទោសចំពោះបទល្មើសទាំងអស់ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៣៥. អង្គជំនុំជម្រះបានពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវផ្តន្ទាទោសទៅលើជនជាប់ចោទ ព្រមទាំងស្ថានទម្ងន់ និងស្ថានសម្រាលទាំងអស់នៅពេលផ្តន្ទាទោស។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរ លើការវាយតម្លៃអំពីជំងឺវិកលចរិត និងជំងឺផ្លូវចិត្តរបស់ជនជាប់ចោទ ព្រមទាំងលើសាក្សីដែលបានផ្តល់សក្ខីកម្មអំពីអត្តចរិត នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាការបន្ថែមទៅលើតួនាទីរបស់គាត់នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងការកំណត់ទោស អង្គជំនុំជម្រះក៏បានពិចារណាផងដែរ ទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត ដែលសេចក្តីសម្រេចរបស់តុលាការអន្តរជាតិទាំងនោះ បានពិចារណាអំពីការកំណត់ទោសទាក់ទងនឹងបទឧក្រិដ្ឋដែលមានលក្ខណៈទ្រង់ទ្រាយធំ។ ជាចុងក្រោយ អង្គជំនុំជម្រះបានរំឭកឡើងវិញអំពី "សេចក្តីសម្រេចលើសំណើសុំដោះលែងឱ្យនៅក្រៅឃុំ" របស់ខ្លួនចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ដែលសម្រេចថា ជនជាប់ចោទមានសិទ្ធិទទួលបាននូវការកាត់បន្ថយទោស ដែលនឹងត្រូវសម្រេចនៅដំណាក់កាលផ្តន្ទាទោស ដោយសារតែការឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ជាការពិត ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ តម្រូវឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលយូរមែន ក៏ប៉ុន្តែនៅពេលដែលពិចារណាអំពីការផ្តន្ទាទោសសរុបរួម មានកត្តាជាច្រើនបានធ្វើឱ្យអង្គជំនុំជម្រះមិនអាចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមច្បាប់ អ.វ.ត.ក បានឡើយ។

៣៦. ឥឡូវនេះ អង្គជំនុំជម្រះនឹងពិចារណាអំពីសំណងរដ្ឋប្បវេណី មុននឹងការប្រកាសសេចក្តីសម្រេចទាំងមូលនៅក្នុងសាលក្រម។

## ច. សំណងរដ្ឋប្បវេណី

៣៧. អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចអំពីភាពអាចទទួលយកបាន និងខ្លឹមសារនៃការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ស្របតាមវិធាន ១០០ អនុវិធាន១ នៃវិធានផ្ទៃក្នុង។ បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង ដែលទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាំងពីចាប់ផ្តើមសវនាការមក មានការកែសម្រួលជាច្រើនដង។ ក្នុងចំណោមការធ្វើវិសោធនកម្ម ការធ្វើវិសោធនកម្មទាំងនេះ មានគោលបំណងធានាឱ្យ

១៨

ដំណើរការនីតិវិធីរបស់ អ.វ.ត.ក អនុញ្ញាតឲ្យមានការចូលរួមរបស់ជនរងគ្រោះ ប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងបទឧក្រិដ្ឋទ្រង់ទ្រាយធំ និងបរិបទកម្ពុជាជាក់លាក់។ ដោយសារតែមានភាពជឿនលឿននៃដំណើរការនីតិវិធីសំណុំរឿង០០១ ក្នុងពេលដែលវិសោធនកម្មទាំងនេះបានចាប់ផ្តើម បទប្បញ្ញត្តិដែលបានកែលំអទាំងនោះមិនយកមកអនុវត្តចំពោះរឿងក្តីនេះទេ។

៣៨. ការសម្រេចបឋម ទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺផ្អែកលើមូលដ្ឋានបណ្តោះអាសន្នដែលថា ពាក្យសុំអាចទទួលយកបាន នៅពេលលក្ខណៈវិនិច្ឆ័យសម្រាប់ការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបំពេញ។ ដំណើរការនេះគឺខុសពីការសម្រេចរបស់អង្គជំនុំជម្រះលើអង្គសេចក្តី នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសាលក្រម ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាង ដែលបានដាក់ជូននៅក្នុងអំឡុងពេលដំណើរការនីតិវិធី។ នៅពេលប្រកាសទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញដល់អង្គជំនុំជម្រះអំពីខ្លឹមសារនៃការទាមទារ ដូចជា អត្ថិភាពនៃកំហុសរបស់ជនជាប់ចោទ និងទំនាក់ទំនងរវាងព្យសនកម្មផ្ទាល់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងនឹងកំហុសរបស់ជនជាប់ចោទ។

៣៩. វិធាន២៣ អនុវិធាន២ នៃវិធានផ្ទៃក្នុង ចែងថា ដើម្បីឲ្យពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មត្រូវតែជា "ការខូចខាតខាងរាងកាយ សម្ភារៈ ឬ ផ្លូវចិត្ត" និង "ជាផលវិបាកដោយផ្ទាល់ពីបទល្មើស ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន"។ ព្យសនកម្មដែលបានទទួលរង ត្រូវតែកើតចេញដោយផ្ទាល់មកពីអំពើឧក្រិដ្ឋរបស់ជនជាប់ចោទ។ ទោះបីជា សមាជិកគ្រួសារជិតស្និទ្ធរបស់ជនរងគ្រោះ ស្ថិតនៅក្នុងវិសាលភាពនៃវិធាន២៣ អនុវិធាន២ ចំណុច(ខ) ក៏ដោយ ក៏ការខូចខាតផ្ទាល់មានការលំបាកក្នុងការបង្ហាញភស្តុតាងទាក់ទងទៅនឹងទំនាក់ទំនងសមាជិកគ្រួសារសាច់ឆ្ងាយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះពិចារណាថា ព្យសនកម្មដែលសមាជិកគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះ នៅក្នុងកាលៈទេសៈពិសេស អាចជាផលវិបាកដោយផ្ទាល់ និងអាចបញ្ជាក់បានពីបទឧក្រិដ្ឋ ដែលអ្នកដាក់ពាក្យសុំអាច

បង្ហាញភស្តុតាងអំពីភាពជាសាច់ញាតិ និងអត្ថិភាពនៃកាលៈទេសៈដែលបង្កើតឱ្យមានចំណងនៃសេចក្តីស្រលាញ់ពិសេស ឬភាពនៅក្នុងបន្ទុករបស់អ្នកដែលបានស្លាប់ទៅ។

៤០. អង្គជំនុំជម្រះបានពិចារណាថា តើ កាំង ហ្កេកអ៊ាវ អាចត្រូវគេរកឃើញថាមានការទទួលខុសត្រូវដែរ ឬទេ ចំពោះព្យសនកម្មជាក់លាក់ដែលត្រូវបានទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណីពីរប្រភេទគឺ បុគ្គលដែលអះអាងថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ ឬស២៤ និងបុគ្គលដែលអះអាងថាជាសាច់ញាតិ ឬមានចំណងនៃសេចក្តីស្រលាញ់ពិសេស ឬភាពនៅក្នុងបន្ទុកជនរងគ្រោះផ្ទាល់។ ចំពោះហេតុផលដែលបានរៀបរាប់លម្អិតនៅក្នុងសាលក្រម អង្គជំនុំជម្រះបានយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបួននាក់ខាងក្រោមនេះ ដែលបានអះអាងថាជាអ្នកនៅរស់រានមានជីវិតពីមន្ទីរស២១ ឬស២៤ បានបង្ហាញភស្តុតាងបញ្ជាក់អំពីអំណះអំណាងរបស់ពួកគាត់ និងបានបង្ហាញថា ជនជាប់ចោទមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះព្យសនកម្ម ដែលពួកគាត់បានទទួលរង។

- ប៊ូ ម៉េង
- ជុំ ម៉ី
- ជុំ នៅ និង
- ជិន ម៉េត

៤១. អង្គជំនុំជម្រះបានយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៦នាក់ ខាងក្រោមនេះ បានបង្ហាញអំពីអំណះអំណាងថាជាជនរងគ្រោះផ្ទាល់នៃមន្ទីរស២១ ឬស២៤ ឬបានបង្ហាញអំពីអត្ថិភាពនៃភាពជាសាច់ញាតិជិតស្និទ្ធ ឬចំណងនៃសេចក្តីស្រលាញ់ពិសេសជាមួយនឹងជនរងគ្រោះផ្ទាល់នៃមន្ទីរស២១ ឬស២៤ ឬភាពនៅក្នុងបន្ទុករបស់ជនរងគ្រោះទាំងនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញបន្ថែមថា មរណភាពរបស់ជនរងគ្រោះទាំងនោះ ធ្វើឱ្យមានព្យសនកម្មដែលមានចែងនៅក្នុងវិធាន២៣ អនុវិធាន២ នៃវិធានផ្ទៃក្នុង ហើយការខូចខាតនេះ គឺជាផលវិបាកដោយផ្ទាល់នៃកំហុសរបស់ជនជាប់ចោទ។

- ប៊ូ ម៉េង គឺជាអ្នករស់រានមានជីវិតពីមន្ទីរស២១ ហើយគាត់បាត់បង់ប្រពន្ធរបស់គាត់ឈ្មោះ ម៉ា យឿន *ហៅ* ធី។
- ជុំ ម៉ី គឺជាអ្នករស់រានមានជីវិតពីមន្ទីរស២១។

- ជុំ នៅ គឺជាអ្នករស់រានមានជីវិតពី ស២៤ ហើយគាត់បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ នូ សាមឿន និងកូនរបស់គាត់ម្នាក់។
- ជិន ម៉េត គឺជាអ្នករស់រានមានជីវិតពីស២៤។
- ឈិន ណារី បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ ទា ហាវតិក។
- ហាវ សោភា បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ចិន សៀ *ហៅ* ហាវ ហាន។
- ភឹងហួត ស៊ុនថារី និង អ៊ឹម ស៊ុន្នី បានបាត់បង់ឪពុក និងប្ដីរបស់គាត់ឈ្មោះ ភឹង តុន។
- ជុំ ស៊ីរ៉ាត បានបាត់បង់ប្អូនប្រុសពីរនាក់របស់គាត់ឈ្មោះជុំ ណារិត និងជុំ ស៊ីណារ៉េត
- មាសកេត សំភាត់, ជូឡុង អង់តូនីញ៉ា (TIOULONG Antonya), ជូឡុង ណេវ៉ា (TIOULONG-ROHMER Neva), គីម៉ារី ណេវីនកា (KIMARI Nevinka) និង គីម៉ារី វីសាកា (KIMARI Visaka) បានបាត់បង់កូនស្រី ប្អូនស្រី និងម្ដាយឈ្មោះ ជូឡុង រង្សី និងកូនប្រសាប្រុស ប្អូនថ្លៃប្រុស និងឪពុកឈ្មោះ លឹម គីម៉ារី។
- រស់ ម៉េន បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ រស់ ធីម។
- ផៃ ប៉ាប បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ផៃ ហេង។
- ជ្រាំង សំអ៊ាន បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ជ្រាំង សំអុន *ហៅ* សោម សំអុន។
- ស៊ាង វ៉ាន់ឌី បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ស៊ាង ផុន។
- តូច មុនិន្ទ បានបាត់បង់បងប្រុសជីដូនមួយរបស់គាត់ឈ្មោះ ជា ខន ដែលបានចិញ្ចឹមបីបាច់រូបគាត់ ហើយដែលគាត់ជាសាច់ញាតិដែលនៅរស់រានមានជីវិតតែម្នាក់គត់។
- កាន់ ស៊ីន្នវ៉ា បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ជឹម ឡាង និងបងថ្លៃស្រីឈ្មោះ អោម ឃិនដូនី។
- ម៉ាន សូត បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ ម៉ាន ស៊ីម *ហៅ* វៀម។
- គង់ ទេស បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ សេក ឆៀក។
- ង៉ែត សុខ បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ណុប សរ *ហៅ* ណុប ង៉ាន *ហៅ* ចារឹន *ហៅ* ង៉ែត ង៉ែម។
- តាត់ ឡូន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ សុក ស៊ិត *ហៅ* សុក ប៊ុន។

២១

- ធីម៉ូធី សុត ឌីង បានបាត់បង់បងប្រុស របស់គាត់ឈ្មោះ ម៉ៃឃល ឌីង។
- យឹម ឡេង បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ធ្លក លួន *ហៅ* យ៉ន។
- អ៊ុម ពិសិដ្ឋ គឺជាសិទ្ធិវ័ន្តរបស់ប្រពន្ធគាត់ឈ្មោះ សួស សារិន ដែលបានបាត់បង់បងស្រីប្រពន្ធរបស់គាត់ឈ្មោះ សួស សារណ្ណ។
- កែ ខុន និង កែ សាម៉ូត បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ កែ កេងស៊ី។
- អៀម សួយ ដែលបានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ជុក ចយ *ហៅ* ជៀវ។
- អ៊ុល សាយ *ហៅ* រៀម បានបាត់បង់ប្តីរបស់គាត់ឈ្មោះ អេង ម៉ាក *ហៅ* ម៉ែន។
- ស៊ីន លឹមសៀ បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ស៊ីន ឈុនលីម។
- អ៊ូ សាវរិទ្ធ, ញឹក អ៊ូដាវី (NHEK Oudavy) និង អ៊ូ កាមេឡា (OU Kamela) បានបាត់បង់ប្អូនប្រុស ប្តី និងឪពុកឈ្មោះ អ៊ូ វិនឌី។
- រស់ ជួ ស៊ីអ៊ី (ROS Chuorsiy) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ រស់ សារិន។
- ញឹម គឹមហឿន បានបាត់បង់បងប្រុសទាំងពីររបស់គាត់ឈ្មោះ ញឹម គួយ និង ញឹម ចាន់។
- សួន សុខុម៉ាលី (SUON Sokhomaly) បានបាត់បង់ប្តីរបស់គាត់ឈ្មោះ សួន កាសេត។
- ស៊ិន ស៊ីណែត *ហៅ* ស្រ៊ុន បានបាត់បង់ជីតារបស់គាត់ឈ្មោះ ភាច គឹម *ហៅ* ស៊ិន ដែលរូបគាត់បានរស់នៅផ្ទះជាមួយតាំងពីគាត់អាយុ៧ឆ្នាំ។
- រូន ស្រីណុប បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ រូន ម៉ាត់ *ហៅ* សារី។
- អែល លីម៉ះ បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ អ៊ីស្មាអ៊ែល អាម៉ាត់ *ហៅ* សុខ។
- ស្មាន ស និង ស្មាន ណុប បានបាត់បង់ប្អូនប្រុសរបស់គាត់ឈ្មោះ ស្មាន ស្លេះ *ហៅ* ឡេង សុខា និងក្មួយឈ្មោះ សា ម៉ាត់ *ហៅ* សារឿន។
- ម៉ែន ឡាយ បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ មិន កាន។
- ញ៉ែម សុផាន បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ញ៉ែម ផុល *ហៅ* វ៉ា។
- នេត ផល្លី បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ នេត ប៊ុនធី។
- ម៉ាន ម៉ះ *ហៅ* ម៉ាន ម៉ាលីម៉ះ បានបាត់បង់កូនប្រុសរបស់គាត់ឈ្មោះ តា ឡុសម៉ាត់ *ហៅ* ម៉ាន ម៉ាត់។

២២

- កុំ មេន *ហៅ*គុម មេន បានបាត់បង់ប្ដីរបស់គាត់ឈ្មោះ ស្រី យ៉េង។
- ទ្រី ង៉ិចលាង បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ខឿង មួយស័រ។
- ហេង ង៉ិចហុង បានបាត់បង់ឪពុករបស់គាត់ឈ្មោះ សុក ហេង។
- បេង ចាន់ថន បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ បេង ពុំ។
- យុន ឈឺន បានបាត់បង់ក្មួយប្រុសរបស់គាត់ឈ្មោះ យុន ឈឿន ដែលបានរស់នៅជាមួយគាត់រហូតដល់អាយុ១៥ឆ្នាំ នៅពេលដែលក្មួយរបស់គាត់បានចូលបដិវត្តន៍
- លី ឃៀក បានបាត់បង់ប្អូនស្រីរបស់គាត់ឈ្មោះ អ៊ួយ ម៉ែន *ហៅ* ម៉ៅ ។
- ពូល ពន្លឹក *ហៅ*ង៉ែត បានបាត់បង់ឪពុករបស់គាត់ឈ្មោះ ពូល ទឿន *ហៅ*ចាំង។
- ចាន់ គ្រួច បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ចាន់ នួន *ហៅ*ស៊ីនួន។
- នង គឹមលៀង បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ នង គឹមហ្គេច *ហៅ*នង គឹមវ៉េត។
- ពេញ សុខេន បានបាត់បង់បងស្រីរបស់គាត់ឈ្មោះ ពេញ សុភាព។
- កាន សាន បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ កាន កន។
- អ៊ុង វឿន *ហៅ*ហ៊ុល វឿន បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ អ៊ុង គាំ *ហៅ* ភ័ណ។
- មាស សារឿន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អ៊ុក តុប។
- សេក សៀក បានបាត់បង់បងជីដូនមួយ និងគូដណ្ដឹងរបស់គាត់ឈ្មោះ ម៉ក់ ឈឿន ដែលបានរស់នៅក្នុងគ្រួសាររបស់គាត់។
- ឆាត គឹម ឈុន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អាំ ធាត់ និងសាច់ញាតិរបស់គាត់ឈ្មោះ ពត ម៉យ *ហៅ*សាផល។
- អ៊ុក វ៉ាំសោធិន បានបាត់បង់ឪពុករបស់គាត់ឈ្មោះ អ៊ុក ជី។
- ម៉ាទីន លីហ្វីយ និង អ៊ុក នារី បានបាត់បង់ប្ដីនិងឪពុកឈ្មោះ អ៊ុក កេត។
- រ៉ូប៊ឺត ហាមីល បានបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ឃែរី ហាមីល។

៤២. ការទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលនៅសេសសល់ទាំងប៉ុន្មានទៀតត្រូវបានបដិសេធ ដោយហេតុថាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ មិនបានបង្ហាញឲ្យអង្គជំនុំជម្រះជឿថា ពួកគាត់គឺជាសាច់ញាតិជិតស្និទ្ធជាមួយនឹងជនរងគ្រោះមន្ទីរស២១

២៣

ឬស២៤ នោះទេ ឬថាពួកគាត់មិនបានបង្ហាញអំពីអត្ថិភាពនៃភាពជាសាច់ញាតិជិតស្និទ្ធ ឬចំណងនៃសេចក្តីស្រលាញ់ពិសេស ឬភាពនៅក្នុងបន្ទុករបស់ជនរងគ្រោះនៃមន្ទីរស២១ ឬស២៤ នោះទេ។ អាស្រ័យហេតុនេះ ការទាមទារសំណងរបស់ពួកគាត់ ក៏ត្រូវបានបដិសេធដែរ។

៤៣. អង្គជំនុំជម្រះក៏បានចេញសេចក្តីសម្រេចផងដែរ ទៅលើបណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើម្បីទទួលបានជោគជ័យ បណ្តឹងទាមទារទាំងនេះត្រូវតែមានលក្ខណៈជាសំណងផ្លូវចិត្ត និងជាសមូហភាព ស្ថិតក្នុងអត្ថន័យនៃវិធានផ្ទៃក្នុង២៣ អនុវិធាន១ ចំណុច(ខ) នៃវិធានផ្ទៃក្នុង និងមានលក្ខណៈច្បាស់លាស់ ឬជាក់លាក់គ្រប់គ្រាន់ ដែលអាចឲ្យអង្គជំនុំជម្រះចេញដីកាបង្គាប់ប្រឆាំងនឹងពិរុទ្ធជនបាន។

៤៤. លក្ខណៈសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺថា ការផ្តល់សំណងគឺជាបន្ទុកផ្តាច់មុខរបស់ពិរុទ្ធជន បន្ទាប់ពីមានការសម្រេចអំពីការទទួលខុសត្រូវចំពោះព្យសនកម្ម ដែលបានលើកឡើង ដោយដើមបណ្តឹងរដ្ឋប្បវេណីថាជាព្យសនកម្ម ដែលបានបណ្តាលមកពីការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ។ អ.វ.ត.ក ដែលជាតុលាការកូនកាត់អន្តរជាតិក្នុងតុលាការកម្ពុជា មិនមានសមត្ថកិច្ចអនុវត្តដោយបង្ខំចំពោះសេចក្តីសម្រេចអំពីសំណងឡើយ។ អង្គជំនុំជម្រះពុំមានយុត្តាធិការទៅលើអាជ្ញាធរកម្ពុជា ឬអាជ្ញាធរជាតិដទៃទៀត ឬស្ថាប័នអន្តរជាតិឡើយ។ អង្គជំនុំជម្រះក៏មិនអាចដាក់កាតព្វកិច្ច ឬផ្តល់សិទ្ធិដល់បុគ្គល ឬអង្គភាពនានា ដែលមិនមែនជាភាគីនៃដំណើរការនីតិវិធីបានឡើយ។ នៅក្នុងបរិបទបច្ចុប្បន្ននេះ ឧបសគ្គជាក់ស្តែងគឺថា ដើមបណ្តឹងរដ្ឋប្បវេណី បានទទួលរងនូវការបាត់បង់យ៉ាងធំធេង ហើយការបាត់បង់ទាំងនេះមិនអាចនឹងសងរួចវិញដោយពិរុទ្ធជនដែលទំនងជាអ្នកទីទ័លក្រគ្មានលទ្ធភាពនោះទេ។

៤៥. អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឲ្យបញ្ចូលឈ្មោះរបស់ពួកគាត់នៅក្នុងសាលក្រមចុងក្រោយ រួមទាំងសេចក្តីបញ្ជាក់អំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស២១។ អង្គជំនុំជម្រះក៏បានយល់ព្រមផងដែរ ទៅនឹងសំណើសុំឲ្យមានការចងក្រង និងបោះពុម្ពផ្សាយនូវពាក្យសម្តីសុំអភ័យទោសដែលបានធ្វើឡើងដោយជនជាប់ចោទក្នុងអំឡុងពេលសវនាការ។

២៤

៤៦. អង្គជំនុំជម្រះបានបដិសេធសំណើសុំផ្សេងៗទៀតទាំងអស់ របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថា សំណើសុំទាំងនោះមិនមានភាពជាក់លាក់ ឬហួសពីវិសាលភាពដែល អ.វ.ត.ក អាចសម្រេចបាន។

## ង. <u>សេចក្តីសម្រេច</u>

៤៧. ឥឡូវនេះ អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចរបស់ខ្លួន។

**ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ក្រោកឈរ។**

៤៨. ក្រោយពីបានពិចារណាលើរាល់ភស្តុតាង និងសេចក្តីសន្និដ្ឋានទាំងអស់របស់ភាគី អង្គជំនុំជម្រះ **សម្រេច** ដូចខាងក្រោមនេះ ៖

៤៩. អង្គជំនុំជម្រះរកឃើញថា កាំង ហ្គេកអ៊ាវ **មានពិរុទ្ធភាព** តាមមាត្រា៥ មាត្រា៦ និងមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ពីបទ ៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ) ដោយរួមបញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ៖
    - ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត)
    - ការធ្វើឲ្យទៅជាទាសករ
    - ការដាក់ក្នុងមន្ទីរឃុំឃាំង
    - ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី)
    - អំពើអមនុស្សធម៌ផ្សេងៗទៀត និង
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩៖
    - ការធ្វើមនុស្សឃាតដោយចេតនា
    - ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

២៥

- ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និង
- ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

៥០. តាមសំអាងហេតុដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីអញ្ញត្រកម្ម អង្គជំនុំជម្រះមិនពិចារណាអំពីពិរុទ្ធភាពរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ពីបទឧក្រិដ្ឋជាតិនៃការធ្វើមនុស្សឃាតគិតទុកជាមុន និងការធ្វើទារុណកម្ម ដែលជាការរំលោភបំពានលើមាត្រា៥០១ មាត្រា៥០៦ និងមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលអាចផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក ស្របតាមមាត្រា៣ ថ្មី នៃច្បាប់ អ.វ.ត.ក ទេ។

៥១. ដើម្បីកំណត់ទោសឲ្យបានសមរម្យ អង្គជំនុំជម្រះបានពិចារណាគ្រប់កាលៈទេសៈទាំងអស់នៃរឿងក្តី។ អង្គជំនុំជម្រះបានកត់សម្គាល់នូវស្ថានទម្ងន់ទោសនានា ដែលរួមទាំងភាពឃោរឃៅ និងសាហាវយង់ឃ្នងនៃបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តមកលើជនរងគ្រោះយ៉ាងហោចណាស់ចំនួន ១២.២៧៣ នាក់ ក្នុងអំឡុងពេលនោះ។ នៅពេលពិចារណាអំពីពិរុទ្ធភាពនៃបទល្មើសច្រើន កត្តានៃស្ថានទម្ងន់ទោសទាំងអស់នេះ ត្រូវធានាឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារក្នុងរយៈពេលមួយយ៉ាងយូរ។

៥២. អង្គជំនុំជម្រះបានសម្រេចថា មានស្ថានសម្រាលទោសមួយចំនួនដែលតម្រូវឲ្យមានការផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារដែលមានរយៈពេលកំណត់ជាក់លាក់មួយ ជាជាងការដាក់ពន្ធនាគារអស់មួយជីវិត។ ស្ថានសម្រាលទោសទាំងនេះ រួមមាន កិច្ចសហការរបស់ជនជាប់ចោទជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ខ្លួន ការសម្តែងវិប្បដិសារី ទោះបីជាមិនបានទូលំទូលាយក៏ដោយ បរិយាកាសបង្ខិតបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងលទ្ធភាពដែលថាជនជាប់ចោទអាចនឹងស្តារនីតិសម្បទាបានឡើងវិញ។

២៦

៥៣. ដោយផ្អែកលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស ដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះដោយមតិភាគច្រើន សម្រេចផ្តន្ទាទោស **កាំង ហ្គេកអ៊ាវ** ដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ ឆ្នាំ។

៥៤. អង្គជំនុំជម្រះយល់ឃើញថា ការកាត់បន្ថយទោសពីរយៈពេលផ្តន្ទាទោសខាងលើចំនួន ០៥ឆ្នាំ គឺជាការផ្តល់ជូនដ៏សមរម្យចំពោះការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងអំឡុងពេលឃុំខ្លួនខុសច្បាប់នីតិវិធីដោយតុលាការយោធាកម្ពុជា ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។

៥៥. ជនជាប់ចោទត្រូវទទួលបានការទូទាត់នូវរយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ និងរយៈពេលឃុំខ្លួនបណ្តោះអាសន្ននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់សាលក្រមនេះចូលជាស្ថាពរ។

៥៦. កាលពីមុន អង្គជំនុំជម្រះបានរាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានទទួលរងនូវព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មដែល កាំង ហ្គេកអ៊ាវ ត្រូវបានរកឃើញថាមានពិរុទ្ធភាព។ អង្គជំនុំជម្រះនឹងធ្វើការចងក្រងនូវពាក្យសម្តីសុំអភ័យទោសទាំងអស់ និងការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ នៅក្នុងអំឡុងពេលសវនាការ។ ការចងក្រងនេះត្រូវដាក់នៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក នៅក្នុងរយៈពេល១៤ថ្ងៃ ក្រោយពីពេលសាលក្រមនេះចូលជាស្ថាពរ។ អង្គជំនុំជម្រះបដិសេធការទាមទារផ្សេងៗទៀតទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

៥៧. បើកផ្លូវប្តឹងសាទុក្ខដល់ភាគីតាមការកំណត់នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ដោយសារស្ថានភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលគាត់មានពិរុទ្ធ អង្គជំនុំជម្រះត្រូវរក្សាទុកពិរុទ្ធជន កាំង ហ្គេកអ៊ាវ នៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់សាលក្រមនេះចូលជាស្ថាពរ ។

២៧

៥៨. នេះគឺជាសេចក្តីសង្ខេបនៃសាលក្រម។ ដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងរឿងក្តីនេះបានមកដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះសាលាដំបូងប្រកាសបិទសវនាការ។

**អនុរក្សមន្ទីរឃុំឃាំងនាំពិរុទ្ធជនត្រឡប់ទៅមន្ទីរឃុំឃាំង អ.វ.ត.ក វិញចុះ!**



*កាំង ហ្គេកអ៊ាវ ហៅ ឌុច និង និរសារឈ្មោះ សុខ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រូបថតប្រហែលក្នុងឆ្នាំ១៩៧៧ (ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

២៨

មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល : *dccam@online.com.kh*
គេហទំព័រ : *www.dccam.org* ឬ *www.cambodiatribunal.org*

គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ
*John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។



***ឆាយ ឈុនលី***

**ឈុនលី** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***ខី សុជាតា***

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***លីម ជ័យទ័ត្ត***

**ជ័យទ័ត្ត** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



***ចាន ប្រាថ្នា***

**ប្រាថ្នា** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។



ទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងថ្ងៃធ្វើជាសាក្សី
ក្នុងសំណុំរឿង០០២ (រូបថត : អ.វ.ត.ក)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមេសា ឆ្នាំ២០១២